## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ការបង្កើតការងារនៅជនបទ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះៈ **អ៊ុយ សុខលីន** | បណ្ឌិត **ឌុយ ចាន់ឌីណា** |
| **ឯម ដារ៉ា** | |


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា | ២០១៦ |
| ជំនាន់ទី ៤ | ឆ្នាំសរសេរសារណា | ២០២០ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **អ៊ុយ សុខលីន** និង **ឯម ដារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ឆ្នាំសិក្សា២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៖

សូមថ្លែងអំណរគុណយ៉ាងអនេកប្បការជូនចំពោះ៖

- លោកឪពុក **អ៊ុយ លី** និងអ្នកម្តាយ **អ៊ុក ហ៊ួយ**
- លោកឪពុក **អ៊ុក ធឿន** និងអ្នកម្តាយ **ឡាំង សុខា**

លោកអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីដោយបានជម្នះនូវរាល់ឧបសគ្គ និងប្រកបដោយព្រហ្មវិហារធម៌។ លោកអ្នកមានគុណទាំងពីរបានអប់រំទូន្មានប្រៀនប្រដៅ លើកទឹកចិត្ត ផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាងទាំងកម្លាំងកាយកម្លាំងចិត្ត និងបានបញ្ជូនកូនឲ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សា ដើម្បីឲ្យកូនចៀសចាកផុតពីភាពល្ងង់ខ្លៅ ដើរលើមាគ៌ាដ៏ត្រឹមត្រូវ និងមានអនាគតភ្លឺស្វាង។ កូននឹងដឹងគុណហើយតបស្នងនូវគុណនូបការៈរបស់លោកអ្នកមានគុណទាំងពីរដែលមានទំហំធំធេងមិនអាចកាត់ថ្លៃបានមួយនេះ ពេញមួយឆាកជីវិតរបស់កូន។

- ឯកឧត្តមសាកលវិទ្យាធិការ បណ្ឌិត **លុយ ចណ្ណា** ដែលបានអនុញ្ញាតឲ្យខ្ញុំទាំងពីរនាក់បានចុះឈ្មោះបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរនាក់ តាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។
- លោកសាស្ត្រាចារ្យ បណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានដឹកនាំក្នុងការសរសេរសារណា និងចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការផ្តល់ជាគំនិតយោបល់ កែសម្រួល ណែនាំ និងលើកទឹកចិត្តឲ្យការសរសេរសារណារបស់យើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកជួយថែរក្សាដល់អ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យទាំងអស់ឲ្យជួបតែសេចក្តីសុខ មានសុខភាពពេញបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍អស់រយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក យើងខ្ញុំទាំងពីរត្រូវបានគណៈគ្រប់គ្រងសាកលវិទ្យាល័យជ្រើសរើសជាបេក្ខជនក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។ ការសរសេរសារណាបញ្ចប់ការសិក្សា ជាចំណែកមួយយ៉ាងសំខាន់របស់និស្សិតក្នុងការអនុវត្តផ្ទាល់ និងដកស្រង់បទពិសោធន៍ដើម្បីឆ្លុះបញ្ចាំងអំពីទ្រឹស្តីក្រោយពីបញ្ចប់ការសិក្សា។ ដោយសង្កេតឃើញស្ថានភាពប្រជាជនកម្ពុជាបច្ចុប្បន្នភាគច្រើនរស់នៅតំបន់ជនបទ ជាមួយនឹងជីវភាពរស់នៅទាប ហើយពេលខ្លះក៏ប្រជាជនជនបទធ្វើចំណាកស្រុកមកទីប្រជុំជន ទីក្រុង ឬឆ្លងព្រំដែនទៅបរទេសស្វែងរកការងារធ្វើដើម្បីទទួលបានប្រាក់កម្រៃសម្រាប់ផ្គត់ផ្គង់គ្រួសារ និងលើកកម្ពស់ជីវភាពរស់នៅឲ្យកាន់តែប្រសើរជាងមុន។ ស្របពេលជាមួយគ្នានេះដែរ ដោយសង្កេតឃើញពីបញ្ហាខាងលើ បានជំរុញឲ្យក្រុមយើងខ្ញុំជ្រើសរើសប្រធានបទ "**ការបង្កើតការងារនៅជនបទ**" ធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សាមកធ្វើការស្រាវជ្រាវ ក្នុងគោលបំណងបង្ហាញពីស្ថានភាពរបស់ប្រជាជនកម្ពុជាដែលរស់នៅតំបន់ជនបទ ជាពិសេសចង់បង្ហាញពីកត្តាផ្សេងៗដែលចូលរួមក្នុងការបង្កើតការងារនៅជនបទក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ។ យើងខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សានេះនឹងក្លាយជាឯកសារសម្រាប់ពង្រីកចំណេះដឹងរបស់អ្នកសិក្សាស្រាវជ្រាវ និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍ និងលើកស្ទួយតំបន់ជនបទនៅប្រទេសកម្ពុជាឲ្យមានការរីកចម្រើន។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គង និងភាពកង្វះខាតនានាដែលកើតឡើងដោយអចេតនាដូចជា កំហុសឆ្គងអក្ខរាវិរុទ្ធ ពាក្យបច្ចេកទេស ខ្លឹមសារដោយការត្រួតពិនិត្យមិនបានគ្រប់ជ្រុងជ្រោយជាដើមដោយក្តីអនុគ្រោះ។ យើងខ្ញុំទាំងពីរនាក់ស្វាគមន៍រាល់មតិរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយ។

# មាតិកា


អក្សរកាត់ ............ vi
បញ្ជីតារាង ............ vii
បញ្ជីក្រាហ្វិក ............ vii


## សេចក្តីផ្តើម


១. លំនាំបញ្ហា ............ ១
២. ចំណោទបញ្ហា ............ ២
៣. គោលបំណងនៃការស្រាវជ្រាវ ............ ៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣
៥. វិធីសាស្ត្រស្រាវជ្រាវ ............ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ............ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៤


## ជំពូកទី១
## ការសិក្សាទ្រឹស្តីពាក់ព័ន្ធ


១.១. និយមន័យនៃការងារ ............ ៦
១.២. និយមន័យនៃអភិវឌ្ឍន៍ ............ ៧
១.៣. សញ្ញាណសំខាន់ៗនៃការអភិវឌ្ឍ ............ ៨
 ១.៣.១. គោលបំណងនៃការអភិវឌ្ឍ ............ ៨
 ១.៣.២. កត្តាសំខាន់ៗដែលនាំឲ្យមានការអភិវឌ្ឍ ............ ៨
  ១.៣.២.១. ដី ............ ៩
  ១.៣.២.២. ពលកម្ម ............ ៩
  ១.៣.២.៣. មូលធន ............ ៩
  ១.៣.២.៤. សហគ្រិនភាព ............ ៩
១.៤. ការងារ និងនិកម្មភាព ............ ១០
 ១.៤.១. ប្រជាជនសកម្ម ............ ១០
  ១.៤.១.១. និយមន័យនៃប្រជាជនសកម្ម ............ ១០
 ១.៤.២. តម្រូវការពលកម្ម និងការងារ ............ ១០
  ១.៤.២.១. ដំណាក់កាលប្រមូល និងប្រមាញ់ ............ ១០

១.៤.២.២. ដំណាក់កាលកសិកម្ម ១១
១.៤.២.៣. ដំណាក់កាលសិប្បកម្ម និងឧស្សាហកម្មធុនស្រាល ១១
១.៤.២.៤. ដំណាក់កាលឧស្សាហកម្មធុនធ្ងន់ ១២
១.៤.៣. និកម្មភាព ១២
១.៤.៣.១. និយមន័យ ១២
១.៤.៣.២. ទ្រឹស្តីនិកម្មភាព ១៣
ក. ទ្រឹស្តីក្លាស៊ីកនៃនិកម្មភាព ១៣
ខ. ទ្រឹស្តីកេននៃនិកម្មភាព ១៣
១.៤.៣.៣. ប្រភេទផ្សេងៗនៃនិកម្មភាព ១៤
១.៥. អត្ថប្រយោជន៍នៃការបង្កើតការងារនៅជនបទ ១៥
១.៥.១. អត្ថប្រយោជន៍ចំពោះគ្រួសារ ១៥
១.៥.២. អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច ១៦
១.៥.៣. អត្ថប្រយោជន៍ចំពោះសង្គម ១៦

## ជំពូកទី២

## ស្ថានភាពទូទៅនៃជនបទកម្ពុជាឆ្នាំ២០១៣-២០១៩

២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ១៧
២.២. ស្ថានភាពប្រជាជនជនបទ ១៨
២.២.១. ភាពក្រីក្រ ១៨
២.២.១.១. ការវាស់នៃភាពក្រីក្រ ១៩
២.២.១.២. មូលហេតុនៃភាពក្រីក្រ ២១
២.២.៣. ចំណាកស្រុក ២២
២.២.៤. មូលហេតុចំណាកស្រុក ២៣
២.៣. ការអប់រំនៅជនបទឆ្នាំ២០១៣-២០១៨ ២៤
២.៣.១. អក្ខរកម្ម ២៤
២.៣.២. ស្ថានភាពសិក្សា ២៥
២.៤. ហេដ្ឋារចនាសម្ព័ន្ធជនបទ ២៩
២.៤.១. ផ្លូវជនបទ ២៩
២.៤.២. អគ្គិសនី ៣០

២.៤.៣. ប្រព័ន្ធធារាសាស្ត្រ.................................................................................................៣០
២.៤.៣.១. ប្រព័ន្ធស្រោចស្រព...........................................................................................៣០
២.៤.៣.២. ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ.......................................................៣១
២.៥. ស្ថានភាពការងារជនបទ.......................................................................................................៣២
២.៥.១. ការបែងចែកការងារតាមវិស័យសេដ្ឋកិច្ច .........................................................៣២
២.៥.២. អត្រានិកម្មភាព.........................................................................................................៣៥
២.៥.៣. មូលហេតុនិកម្មភាព...................................................................................................៣៥
២.៦. តួនាទីរបស់ស្ថាប័ននានាក្នុងការអភិវឌ្ឍជនបទ ..........................................................៣៧
២.៦.១. តួនាទីរបស់ស្ថាប័នសាធារណៈ ...............................................................................៣៧
២.៦.២. តួនាទីអង្គការក្រៅរដ្ឋាភិបាល ...................................................................................៣៨
២.៧. គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់បង្កើតការងារនៅជនបទ.................................៣៨
២.៧.១. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ..........................................................៣៨
២.៧.២. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥.......................៣៩
២.៧.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ........... ៤០
២.៧.៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ........................................៤២
២.៧.៥. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ...........................៤៣

## ជំពូកទី៣
## ការបង្កើតការងារនៅជនបទកម្ពុជា

៣.១. ការបង្កើតការងារតាមវិស័យកសិកម្ម ......................................................................... ៤៥
៣.១.១. ការបង្កើតការងារតាមរយៈការធ្វើពិពិធកម្មដំណាំកសិកម្ម .................................. ៤៥
៣.១.១.១. ដំណាំស្រូវ........................................................................................................ ៤៦
៣.១.១.២. ដំណាំសាកវប្បកម្ម............................................................................................ ៤៧
៣.១.១.៣. ដំណាំឧស្សាហកម្ម ............................................................................................ ៤៨
៣.១.១.៤. ការអភិវឌ្ឍពិពិធកម្មដំណាំកសិកម្ម .........................................................៤៩
៣.១.២. ការបង្កើតការងារតាមការចិញ្ចឹមសត្វ និងវារីវប្បកម្ម............................................ ៥០
៣.២. ការបង្កើតការងារតាមវិស័យមិនមែនកសិកម្ម...........................................................៥៣
៣.២.១. ការវិនិយោគសាធារណៈ........................................................................................៥៣
៣.២.១.១. ប្រព័ន្ធធារាសាស្ត្រ .........................................................................................៥៣

៣.២.១.២. ផ្លូវជនបទ ..... ៥៥
៣.២.១.៣. អគ្គិសនី ..... ៥៦
៣.២.១.៤. ការបង្កើតផ្សារនៅជនបទ ..... ៥៨
៣.២.២. ការផ្តល់កម្ចីកសិកម្មជាមួយអត្រាការប្រាក់ទាប ..... ៥៨
៣.២.៣. ការបង្កើតមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម(MSMEs) ..... ៦០
៣.២.៤. ការបង្កើនការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ..... ៦២
៣.២.៤.១. ការអប់រំ ..... ៦២
៣.២.៤.២. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ..... ៦៣
៣.២.៥. ការទាក់ទាញវិនិយោគិន ..... ៦៤
៣.២.៥.១. កត្តាទាក់ទាញវិនិយោគិន ..... ៦៤
៣.២.៥.២. ការលើកទឹកចិត្តការវិនិយោគ ..... ៦៥
៣.៣. ការបង្កើតការងារតាមវិស័យទេសចរណ៍ជនបទ ..... ៦៦
៣.៣.១. ការអភិវឌ្ឍតំបន់សហគមន៍អេកូទេសចរណ៍ ..... ៦៧
៣.៣.២. ការបង្កើតតំបន់កសិទេសចរណ៍ ..... ៦៨
៣.៣.៣. ការបង្កើតរមនីយដ្ឋានទេសចរណ៍កែច្នៃ ..... ៦៩
៣.៣.៤. ការងារក្នុងវិស័យទេសចរណ៍ជនបទ ..... ៦៩

**ជំពូកទី៤**

**ការសិក្សាលើចំណុចខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ**

៤.១. ចំណុចខ្លាំង ..... ៧១
៤.២. បញ្ហាប្រឈម ..... ៧១
៤.២.១. បញ្ហាប្រឈមការបង្កើតការងារនៅជនបទក្នុងវិស័យកសិកម្ម ..... ៧១
៤.២.១.១. កង្វះដី ..... ៧១
៤.២.១.២. បញ្ហាទីផ្សារ ..... ៧២
៤.២.១.៣. ការប្រែប្រួលអាកាសធាតុ ..... ៧២
៤.២.២. កង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ..... ៧៣
៤.២.២.១. ប្រព័ន្ធធារាសាស្រ្ត ..... ៧៣
៤.២.២.២. ផ្លូវជនបទ ..... ៧៤
៤.២.២.៣. អគ្គិសនី ..... ៧៤

៤.២.៣. បញ្ហាប្រឈមក្នុងវិស័យមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ............. ៧៥
៤.២.៤. កម្ចីឥណទានមានអត្រាការប្រាក់ខ្ពស់ ............................................................. ៧៦
៤.២.៥. ការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទាប ......................... ៧៧
៤.២.៥.១. បញ្ហាប្រឈមក្នុងវិស័យអប់រំ ............................................................. ៧៧
៤.២.៥.២. បញ្ហាប្រឈមនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........... ៧៧
៤.២.៦. បញ្ហាប្រឈមនៃការវិនិយោគ ............................................................................ ៧៨
៤.៣. ដំណោះស្រាយ ......................................................................................................... ៧៨
៤.៣.១. ដំណោះស្រាយការបង្កើតការងារក្នុងវិស័យកសិកម្ម ............................................. ៧៨
៤.៣.១.១. ដំណោះស្រាយកង្វះដី ......................................................................... ៧៨
៤.៣.១.២. ដំណោះស្រាយទីផ្សារ ......................................................................... ៧៩
៤.៣.១.៣. ដំណោះស្រាយការប្រែប្រួលអាកាសធាតុ ................................................ ៨០
៤.៣.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........................................................................ ៨១
៤.៣.២.១. ប្រព័ន្ធធារាសាស្ត្រ ........................................................................... ៨១
៤.៣.២.២. ផ្លូវជនបទ ........................................................................................... ៨១
៤.៣.២.៣. អគ្គិសនី ............................................................................................. ៨២
៤.៣.៣. ដំណោះស្រាយMSMEs ................................................................................ ៨២
៤.៣.៤. វិធានការធ្វើឲ្យអត្រាការប្រាក់ធ្លាក់ចុះ ............................................................... ៨៤
៤.៣.៥. កាបង្កើនការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ................ ៨៥
៤.៣.៥.១. ដំណោះស្រាយការអប់រំ ......................................................................... ៨៥
៤.៣.៥.២. ដំណោះស្រាយការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ............ ៨៦
៤.៣.៦. ការបង្កើតបរិយាកាសអំណោយផលដល់វិនិយោគ ............................................. ៨៦

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

១. សេចក្តីសន្និដ្ឋាន ......................................................................................................... ៨៧
២. អនុសាសន៍ ..................................................................................................................... ៨៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

## ពាក្យកាត់៖

| | | |
|---|---|---|
| ដុល្លារ | ដុល្លារអាមេរិក | |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប | |
| វ.ស.ក | វិទ្យាស្ថានសភាកម្ពុជា | |
| ហ.ត | ហិកតា | |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ | |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CSES | Cambodia Socio-Economic Survey | ការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា |
| EIC | Economic Institute of Cambodia | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ILO | International Labor Organization | អង្គការពលកម្មអន្តជាតិ |
| MAFF | Ministry of Agriculture Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MFIs | Microfinance Institutions | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MSMEs | Micro, Small and Medium Enterprises | មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NGOs | Non-Government Organizations | អង្គការក្រៅរដ្ឋាភិបាល |
| NIS | National Institute Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| WB | World Bank | ធនាគារពិភពលោក |

## សញ្ញាសម្គាល់៖

| | |
|---|---|
| (%) | ភាគរយ |
| (,) | ក្បៀស ឬទសភាគ |
| (.) | កាត់ខ្ទង់('000) |
| (<) | តិចជាង |
| (>) | ច្រើនជាង |

# បញ្ជីតារាង

តារាងទី២.១៖ ចំនួនសិស្សនៅមធ្យមសិក្សាឆ្នាំសិក្សា២០១៧-១៨ និង២០១៨-១៩......................២៧
តារាងទី២.២៖ អត្រាលំហូរសិស្សរវាងឆ្នាំសិក្សា២០១៦-១៧ និង២០១៧-១៨.............................២៨
តារាងទី២.៣៖ កំណើនការងារនៅជនបទឆ្នាំ២០០៤-២០០៩........................................................ ៣២
តារាងទី៣.១៖ ចំណាត់ថ្នាក់ MSMEs នៅកម្ពុជា............................................................................ ៦០

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១.១៖ និកម្មភាពក្នុងគំរូក្លាស៊ីក........................................................................................ ១៣
ក្រាហ្វិកទី១.២៖ ការកំណត់ការងារក្នុងគំរូកេន .................................................................................. ១៤
ក្រាហ្វិកទី២.១៖ អត្រាកំណើន ផ.ស.ស ឆ្នាំ២០១០-២០១៩ ........................................................... ១៨
ក្រាហ្វិកទី២.២៖ អត្រាអក្ខរកម្មប្រជារាស្ត្រពេញវ័យ(១៥ឆ្នាំឡើង)ជនបទឆ្នាំ២០១៣-២០១៧ ......២៥
ក្រាហ្វិកទី២.៣៖ ចំនួនសិស្សបឋមសិក្សាឆ្នាំសិក្សា២០១៧-២០១៨ និង២០១៨-២០១៩.............២៦
ក្រាហ្វិកទី២.៤៖ អត្រាមានការងារធ្វើនៅតំបន់ជនបទឆ្នាំ២០១៣-២០១៧ ..................................៣៣
ក្រាហ្វិកទី២.៥៖ ការបែងចែកការងារតាមវិស័យសេដ្ឋកិច្ចនៅជនបទឆ្នាំ២០១៣-២០១៧ ............៣៤
ក្រាហ្វិកទី២.៦៖ អត្រានិកម្មភាពនៅជនបទឆ្នាំ២០១៣-២០១៧.....................................................៣៥
ក្រាហ្វិកទី៣.១៖ ផលិតកម្មដំណាំស្រូវឆ្នាំ២០១៥-២០១៩.............................................................. ៤៧
ក្រាហ្វិកទី៣.២៖ ផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៥-២០១៩ .................................................. ៤៨
ក្រាហ្វិកទី៣.៣៖ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុបឆ្នាំ២០១៥-២០១៩ ..........................................៤៩
ក្រាហ្វិកទី៣.៤៖ ផលិតកម្មសត្វជាលក្ខណៈគ្រួសារឆ្នាំ២០១៥-២០១៩.......................................... ៥១
ក្រាហ្វិកទី៣.៥៖ ផលិតផលវារីវប្បកម្មឆ្នាំ២០១៥-២០១៩ ............................................................. ៥២

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់ភ្លើងសង្គ្រាមរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍។ សង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម(កម្ពុជាប្រជាធិបតេយ្យ) ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ បានធ្វើឲ្យកម្ពុជាធ្លាក់ចុះដល់ចំណុចសូន្យ និងបានសម្លាប់ប្រជាជនខ្មែរស្លូតត្រង់ និងបញ្ញវន្ត អស់រាប់លាននាក់។ បើទោះបីរបបខ្មែរក្រហមបានដួលរលំនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ក៏ពិតមែនក៏សង្គ្រាមស៊ីវិលនៅអូសបន្លាយរហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ទើបសន្តិភាពបានលេចចេញជារូបរាងឡើងនៅក្នុងប្រទេសកម្ពុជា។ ក្រោយពីងើបចេញពីភ្លើងសង្គ្រាមអស់ជាងបីទសវត្សរ៍កន្លងមក កម្ពុជាបានចាប់ផ្តើមស្តារ និងកសាងប្រទេសជាតិពីចំណុចសូន្យឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គម ដោយធ្វើការអភិវឌ្ឍទៅលើគ្រប់វិស័យទាំងអស់។ ការអភិវឌ្ឍជនបទ ជានយោបាយស្នូលមួយដែលរាជរដ្ឋាភិបាលមិនអាចមើលរំលងបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និងការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែផលវិបាកនៃសង្គ្រាម ការបាត់បង់មូលធនរូបវន្ត ការបាត់បង់ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធសង្គម ព្រមទាំងបន្សល់ទុកកាកសំណល់សង្គ្រាម អាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ ជាឧបសគ្គរាំងស្ទះចំពោះការអភិវឌ្ឍប្រទេសជាតិ ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ជាពិសេសប៉ះពាល់ដល់វិស័យកសិកម្ម ដែលជាវិស័យមួយបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជនបទ។ បើទោះបីមានឧបសគ្គក្នុងការអភិវឌ្ឍវិស័យកសិកម្ម ក៏វិស័យនេះបានផ្តល់វិសាលភាពទូលំទូលាយក្នុងការផ្តល់ការងារជាច្រើនដល់ប្រជាជនជនបទ និងជាប្រភពដ៏សំខាន់នៃចំណូលរបស់ប្រជាជនជនបទក្រីក្រ។ ប៉ុន្តែនាពេលបច្ចុប្បន្ន ចំនួនការងារដែលបង្កើតដោយវិស័យកសិកម្មបានថយចុះ។ ចំនួនពលកម្មនៅក្នុងវិស័យកសិកម្មត្រូវបានគេប៉ាន់ស្មានកើនឡើងចំនួន ២៥០.០០០នាក់បន្ថែមជារៀងរាល់ឆ្នាំ។ ស្ថានភាពការងារកាន់តែធ្ងន់ធ្ងរឡើងៗដោយសារកង្វះធនធានធម្មជាតិ និងដីធ្លី។[1] ឧស្សាហកម្មកាត់ដេរបានក្លាយជាប្រភពមួយដ៏សំខាន់ក្នុងការបង្កើតការងារថ្មីៗ និងបង្កើនប្រាក់ចំណូលប្រជាជន តែទោះជាយ៉ាងណាក៏ដោយ ក៏ការពង្រីកដ៏ឆាប់រហ័សនៃការងារនៅក្នុងវិស័យកម្មន្តសាលមិនអាចឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងការស្រូបយកការងារ ដែលកំពុងតែថយចុះក្នុងវិស័យកសិកម្មទេ។

ជាការពិតណាស់ ប្រទេសជឿនលឿនលើពិភពលោកគេពឹងផ្អែកលើវិស័យឧស្សាហកម្មជាធំ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាដែលមានប្រជាជនជាង ៨០% រស់នៅទី

[1] ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ២០៦។

ជនបទ ហើយពឹងផ្អែកយ៉ាងខ្លាំងទៅលើការងារក្នុងវិស័យកសិកម្ម។ ម្យ៉ាងទៀតតំបន់ជនបទកម្ពុជានៅខ្វះខាតហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជា ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ អគ្គិសនី និងប្រព័ន្ធធារាសាស្ត្រជាដើម។ ចំណែកឯសហគ្រាសធុនតូច និងមធ្យមដែលផ្តល់ការងារដល់ប្រជាជននោះ ក៏ច្រើនតែប្រមូលផ្តុំគ្នានៅក្នុងទីប្រជុំជន និងទីក្រុងតែប៉ុណ្ណោះ។ ប្រសិនបើប្រជាជននៅតាមទីជនបទចង់បានការងារធ្វើចាំបាច់ត្រូវឡើងមកទីប្រជុំជន ឬទីក្រុង។

ក្នុងការអភិវឌ្ឍជនបទ(និយាយជារួម) ឬការបង្កើតការងារនៅជនបទ(និយាយដោយឡែក) រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗទៅតាមវិស័យនានាដែលមានការពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលក្នុងការជំរុញឲ្យមានការបង្កើតការងារនៅជនបទ។ ការចូលរួមពីសំណាក់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅជនបទតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ តែត្រូវមានការចូលរួមពីសំណាក់មជ្ឈដ្ឋានដទៃទៀតដូចជា អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាផងដែរ ដើម្បីអភិវឌ្ឍន៍ជនបទ ដែលជាគន្លឹះដោះស្រាយបញ្ហាយ៉ាងច្រើនដូចជា ភាពក្រីក្រ ចំណាកស្រុក និងការកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទជាដើម។ ការធ្វើបែបនេះបាន ប្រជាជននឹងមានទីពឹងដ៏រឹងមាំមួយដើម្បីអភិវឌ្ឍន៍វិស័យផ្សេងទៀត។

## ២. ចំណោទបញ្ហា

ការរីកចម្រើនផ្នែកសេដ្ឋកិច្ចជនបទ និងកំណើនប្រាក់ចំណូល ព្រមទាំងការងារមានសារៈសំខាន់ណាស់ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ក៏ប៉ុន្តែកំណើនប្រជាជននៅតែបន្តកើនឡើង ហើយការស្រូបយកកម្លាំងពលកម្មចូលក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀតក្រៅពីវិស័យកសិកម្មបានតិចតួច ដូចនេះកម្លាំងពលកម្មជនបទនឹងនៅតែបន្តកើនឡើងក្នុងរយៈពេលខ្លី និងមធ្យមដែលត្រូវស្វែងរកការងារនៅតំបន់ជនបទ។ ស្របពេលដែលមានកំណើនប្រជាជនដែលជាហេតុធ្វើឲ្យមានតម្រូវការនៃការងារ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅក្នុងតំបន់ជនបទបើសិនជាក្នុងតំបន់នោះមិនមានការងារទេ ដែលជាលទ្ធផលគឺប្រជាជនមានការចំណាកស្រុក ឬផ្លាស់ប្តូរទីលំនៅក្នុងការស្វែងរកការងារជាដើម។

តែទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងការខិតខំប្រឹងប្រែងជាពិសេសនៅតំបន់ជនបទស្ថិតក្រោមរូបភាពជាច្រើន ក្នុងទិសដៅលើកកម្ពស់ជីវភាព និងសុខុមាលភាពតាមរយៈការដាក់ចេញជាគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការបង្កើតការងារជាដើម។ ការបង្កើតការងារនៅជនបទ គឺជាទិសដៅសំខាន់ណាស់ពីព្រោះថាវាជាឫសគល់

នៃការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេស។ ក្នុងន័យនេះ តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីបង្កើតឱកាសការងារសម្រាប់ប្រជាជននៅតំបន់ជនបទនៅក្នុងវិស័យកសិកម្ម វិស័យមិនមែនកសិកម្ម និងវិស័យទេសចរណ៍? តើការបង្កើតការងារនៅជនបទផ្តល់ផលប្រយោជន៍យ៉ាងដូចម្តេចខ្លះចំពោះប្រជាជន និងសេដ្ឋកិច្ចកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានចងក្រងឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- សិក្សាពីទ្រឹស្តីពាក់ព័ន្ធនានា
- បង្ហាញពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិនានាដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតការងារនៅជនបទ
- បង្ហាញពីស្ថានភាពទូទៅនៃតំបន់ជនបទរបស់ប្រទេសកម្ពុជា
- យល់ដឹងពីដំណើរការនៃការបង្កើតការងារនៅជនបទ
- សិក្សាពីបញ្ហាប្រឈមនានា ព្រមទាំងរកដំណោះស្រាយក្នុងការបង្កើតការងារនៅតំបន់ជនបទ
- ជាការចូលរួមចំណែកមួយក្នុងការស្រាវជ្រាវ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ជនបទឲ្យមានការរីកចម្រើន
- ចងក្រងទុកជាឯកសារ សម្រាប់ជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនានារបស់និស្សិតជំនាន់ក្រោយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការបង្កើតឱកាសការងារនៅជនបទ ក្រុមខ្ញុំបាទបានសម្រេចចិត្តយកតែការបង្កើតការងារតាមរយៈវិស័យកសិកម្ម វិស័យមិនមែនកសិកម្ម និងវិស័យទេសចរណ៍ជនបទមកធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកនូវកត្តាដែលចូលរួមចំណែកសំខាន់ៗដែលនាំឲ្យមានផលប្រយោជន៍ដល់ការអភិវឌ្ឍជនបទកម្ពុជា ព្រមទាំងពិភាក្សាលើបញ្ហាប្រឈមនិងស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពខ្ពស់។ មួយវិញទៀត ការសិក្សាស្រាវជ្រាវនេះសិក្សាក្នុងអំឡុងចន្លោះឆ្នាំ២០១៣ ដល់ ២០១៩។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ជាក់ស្តែងវិធីសាស្ត្រប្រមូលទិន្នន័យកំណត់តាមប្រភេទទិន្នន័យពីរបែប គឺទិន្នន័យបឋម (Primary data) និងទិន្នន័យបន្ទាប់បន្សំ (Secondary data)។ ចំពោះការសិក្សាស្រាវជ្រាវលើប្រធាន

បទ **"ការបង្កើតការងារនៅជនបទ"** ក្រុមខ្ញុំបាទបានធ្វើការប្រមូលទិន្នន័យតែតាមរយៈប្រភពទិន្នន័យបន្ទាប់បន្សំ (Secondary data) តែប៉ុណ្ណោះក្នុងការដកស្រង់យកទិន្នន័យដែលពាក់ព័ន្ធ។ ទិន្នន័យបន្ទាប់បន្សំ (Secondary data) សំដៅទៅលើប្រភពទិន្នន័យស្រាវជ្រាវ ដែលប្រមូលបានតាមរយៈសៀវភៅឯកសារផ្សេងៗជាច្រើនដូចខាងក្រោម៖

- សៀវភៅសារណា និងរបាយការណ៍បញ្ចប់ការសិក្សានៅក្នុងបណ្ណាល័យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- ឯកសារបោះពុម្ពដែលមានលក្ខណៈផ្លូវការដូចជា សៀវភៅ កាសែត ព្រឹត្តិបត្ររបាយការណ៍នានា
- សៀវភៅគោលនយោបាយ និងផែនការយុទ្ធសាស្រ្តផ្សេងៗ
- ឯកសារបានមកពីការស្រាវជ្រាវតាមរយៈប្រព័ន្ធអ៊ីនធឺណិត(Internet)។ល។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ ការបង្កើតការងារនៅជនបទ ផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

- ចូលរួមចំណែកផ្តល់ចំណេះដឹង ប្រភពទិន្នន័យ ឬទុកជាឯកសារសម្រាប់ស្រាវជ្រាវដែលពាក់ព័ន្ធនានារបស់មិត្តនិស្សិត សិស្សប្អូនជំនាន់ក្រោយ និងអ្នកស្រាវជ្រាវទាំងឡាយជាដើម។
- ទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីជាមួយការពិគ្រោះយោបល់ពីសាស្រ្តាចារ្យណែនាំ ចាប់តាំងពីការចាប់ផ្តើមដំណើរការប្រមូលទិន្នន័យ ការចងក្រង រហូតដល់សារណាលេចចេញជារូបរាងឡើង។
- ទទួលបានបទពិសោធន៍ថ្មីក្នុងការធ្វើការជាក្រុម ទំនាក់ទំនងជាមួយសាស្រ្តាចារ្យណែនាំ ដៃគូ និងថ្នាក់ដឹកនាំដទៃទៀត។
- ចងក្រងជាឯកសារមួយក្នុងការផ្តល់ជាអនុសាសន៍ ដើម្បីចូលរួមអភិវឌ្ឍន៍ជនបទរបស់ប្រទេសកម្ពុជាឲ្យមានការរីកចម្រើន ពោលគឺលើកកម្ពស់ជីវភាពប្រជាជន និងការកាត់បន្ថយភាពក្រីក្រ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ ការបង្កើតការងារនៅជនបទ ក្រុមខ្ញុំបាទបានចែកចេញជា ៤ជំពូកដូចខាងក្រោម៖

- **សេចក្តីផ្តើម** ជាចំណុចចាប់ផ្តើមនៃប្រធានបទ ដែលនឹងធ្វើការសិក្សាទៅលើផ្នែកមួយចំនួន ដូចជា ស្ថានភាពទូទៅ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ និងវិធីសាស្ត្រស្រាវជ្រាវ ដែលជាបញ្ហាចោទដែលឈានទៅដល់ការបង្កើតការងារនៅជនបទ។
- **ជំពូកទី១៖ ការសិក្សាទ្រឹស្តីពាក់ព័ន្ធ** ក្នុងជំពូកនេះ យើងលើកយកទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួន ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការងារ និងនិកម្មភាពមកធ្វើការសិក្សា ដែលជាកត្តាយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។
- **ជំពូកទី២៖ ស្ថានភាពទូទៅនៃជនបទនៅកម្ពុជាឆ្នាំ២០១៣-២០១៩** ក្នុងជំពូកនេះ យើងបង្ហាញពីស្ថានភាពទូទៅក្នុងតំបន់ជនបទដូចជា ការអប់រំ ការទទួលបាននូវការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ស្ថានភាពការងារ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតការងារដល់ប្រជាជន និងការអភិវឌ្ឍជនបទ។
- **ជំពូកទី៣៖ ការបង្កើតការងារនៅជនបទកម្ពុជា** ក្នុងជំពូកនេះ យើងបង្ហាញពីកត្តាផ្សេងៗ ដែលមានឥទ្ធិពលក្នុងការបង្កើតការងារនៅជនបទ នៅក្នុងវិស័យកសិកម្ម វិស័យមិនមែនកសិកម្ម និងវិស័យទេសចរណ៍។
- **ជំពូកទី៤៖ ការសិក្សាលើចំណុចខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ** ក្នុងជំពូកនេះ យើងបង្ហាញពីចំណុចអំណោយផលមួយចំនួនក្នុងការបង្កើតការងារនៅជនបទ ការសិក្សាបញ្ហាប្រឈមផ្សេងៗ ដែលជះឥទ្ធិពលលើការបង្កើតការងារជនបទ ព្រមទាំងរកដំណោះស្រាយទៅលើបញ្ហាទាំងអស់នោះ។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ជាការសន្និដ្ឋានរួមទៅលើប្រធានបទ និងផ្តល់ជាមតិយោបល់សម្រាប់ជាប្រយោជន៍ក្នុងការបង្កើតការងារនៅតំបន់ជនបទ។

# ជំពូកទី១

# ការសិក្សាទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី១
# ការសិក្សាទ្រឹស្តីពាក់ព័ន្ធ

## ១.១. និយមន័យនៃការងារ

ពាក្យ ការងារ ជាទូទៅត្រូវបានគេកំណត់និយមន័យទៅតាមស្ថានភាព និងលក្ខខណ្ឌផ្សេងៗ ប៉ុន្តែស្ថិតក្នុងសកម្មភាពប្រហាក់ប្រហែលគ្នា។ យោងទៅតាមអក្សរសាស្ត្រខ្មែរ ផ្អែកលើវចនានុក្រមខ្មែរ ដែលចងក្រងដោយសម្តេចសង្ឃរាជ ជួន ណាត ពាក្យថា ការងារ សំដៅទៅលើកិច្ចការងារដែលត្រូវធ្វើតាមមុខងាររបស់បុគ្គលម្នាក់ៗ។[2]

យោងតាមអង្គការពលកម្មអន្តរជាតិ(ILO) បានកំណត់និយមន័យថា ការងារ រាប់បញ្ចូលបុគ្គលទាំងអស់ ដែលធ្វើការងារស្ថិតក្នុងអាយុពលកម្មនៅក្នុងរយៈពេលខ្លីជាក់លាក់ដូចជា មួយសប្តាហ៍ ឬមួយថ្ងៃ ក្នុងសកម្មភាពផលិតទំនិញ ឬក្នុងសកម្មភាពផ្តល់សេវាកម្មសម្រាប់ប្រាក់ចំណូល ឬប្រាក់ចំណេញ ដែលមានលក្ខណៈសម្គាល់ដូចខាងក្រោម៖

- ការងារមានប្រាក់ឈ្នួល រាប់បញ្ចូលអ្នកធ្វើការងារនៅកន្លែងធ្វើការងារ និងអ្នកធ្វើការងារមួយ ប៉ុន្តែមិនស្ថិតនៅកន្លែងធ្វើការងារ
- ការងារផ្ទាល់ខ្លួន (Self-employment) រាប់បញ្ចូលអ្នកធ្វើការងារផ្ទាល់ខ្លួននៅកន្លែងធ្វើអាជីវកម្ម និងអ្នកធ្វើការងារផ្ទាល់ខ្លួន ប៉ុន្តែមិនស្ថិតនៅកន្លែងធ្វើអាជីវកម្ម។[3]

ប្រជាជនស្ថិតនៅក្នុងអាយុពលកម្ម ជាប្រជាជនដែលស្ថិតនៅក្នុងអាយុពលកម្មស្របច្បាប់ ប៉ុន្តែយោងតាមការធ្វើស្ថិតិក្នុងសកម្មភាពសេដ្ឋកិច្ច ប្រជាជនស្ថិតក្នុងអាយុពលកម្មជាប្រជាជនដែលមានអាយុចាប់ពីអាយុអប្បបរមាដែលច្បាប់បានកំណត់ឡើងទៅ។ ដើម្បីអនុគ្រោះដល់ការប្រៀបធៀបជាអន្តរជាតិ អាយុពលកម្មស្របច្បាប់គឺចាប់ពី១៥ឆ្នាំឡើងទៅ ប៉ុន្តែអាយុពលកម្មអប្បបរមាអាចខុសគ្នាពីប្រទេសមួយ ទៅប្រទេសមួយទៀតអាស្រ័យលើច្បាប់របស់ប្រទេសនីមួយៗ ហើយក៏មានប្រទេសជាច្រើនបានកំណត់អាយុ ៦៤ឆ្នាំជាអាយុពលកម្មអតិបរមាផងដែរ។

ការងារត្រូវបានគេផ្តល់និយមន័យមួយផ្សេងទៀតថា ជាកិច្ចព្រមព្រៀងរវាងបុគ្គលម្នាក់ជាមួយបុគ្គលម្នាក់ទៀត ឬអង្គភាពមួយផ្សេងទៀត ដែលមានការកំណត់លក្ខខណ្ឌផ្សេងៗដូចជា

[2] ជួន ណាត, *វចនានុក្រមខ្មែរ*, ភាគ១ និងភាគ២ (ភ្នំពេញ, ១៩៦៧), ៣៥។

[3] អង្គការពលកម្មអន្តរជាតិ, *Statistics of work, employment and labour underutilization* [ស្ថិតិការងារ ការងារ និងការប្រើប្រាស់ពលកម្ម], Report II, (Geneva: International labour Organization, 2013), ៥។

ការទទួលខុសត្រូវ ការទូទាត់សំណង បទបញ្ញាផ្សេងៗនៅកន្លែងធ្វើការងារ ព្រមទាំងមានការទទួលស្គាល់ពីសំណាក់រដ្ឋាភិបាល។[4]

សរុបមក ការងារមានន័យថាជាសកម្មភាពដែលត្រូវបានគេកំពុងជួលដោយក្រុមហ៊ុន ឬនិយោជក។

## ១.២. និយមន័យនៃអភិវឌ្ឍន៍

ការអភិវឌ្ឍ គឺជាការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការរស់នៅ និងសមត្ថភាពរបស់បុគ្គលទាំងអស់តាមរយៈការធ្វើឲ្យកើនឡើងនូវកម្រិតជីវភាពរស់នៅ ការគោរពគ្នាទៅវិញទៅមក និងសេរីភាព។ ជាក់ស្តែងក្នុងនិយមន័យ ការអភិវឌ្ឍ មានតម្លៃស្នូលបីសំខាន់ៗដូចជា ការចិញ្ចឹមជីវិត ការគោរពគ្នា និងការទទួលបានសេរីភាពដោយគ្មានការជិះជាន់។[5]

–ការចិញ្ចឹមជីវិត៖ ជាតម្រូវការមូលដ្ឋានក្នុងការរស់នៅដូចជា ម្ហូបអាហារ សម្លៀកបំពាក់ ជម្រក ការការពារ និងសុខភាពជាតម្រូវការចាំបាច់សម្រាប់មនុស្សគ្រប់រូបនៅលើពិភពលោក ដើម្បីទទួលបានកម្រិតនៃការរស់នៅជាអតិបរមា។

–ការគោរពគ្នា៖ ការរស់នៅរបស់បុគ្គលសព្វថ្ងៃតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដូចនេះដើម្បីក្លាយជាមនុស្សត្រូវមានការគោរពគ្នា យោគយល់ ឲ្យតម្លៃ អធ្យាស្រ័យគ្នាទៅវិញទៅមក ដែលជាហេតុនាំឲ្យមនុស្សមានសុជីវធម៌ល្អ និងទទួលបានភាពរីករាយនៅក្នុងសង្គម។ ក្នុងនេះដែរ គឺអាស្រ័យនៅក្នុងសង្គម នយោបាយ ប្រព័ន្ធសេដ្ឋកិច្ច និងស្ថាប័ននានាក្នុងការជំរុញលើកទឹកចិត្តឲ្យមនុស្សមានសេចក្តីថ្លៃថ្នូរ សេចក្តីទៀងត្រង់ សិទ្ធិសម្រេចចិត្តជាដើម។

–ការទទួលបានសេរីភាពដោយគ្មានការជិះជាន់៖ នេះជាស្ថានភាពមួយនៅក្នុងសង្គមដែលទទួលបាននូវជម្រើសនៃការចំណាយផ្សេងៗទៅតាមចំណង់ និងការពេញចិត្តរបស់បុគ្គលម្នាក់ទៅតាមជម្រើសជាក់ស្តែងដោយយោងទៅតាមការស្រឡាញ់ និងការចូលចិត្ត។

- **កម្មវត្ថុបីនៃការអភិវឌ្ឍ**

១-ការកើតឡើងការចែករំលែកនៃការទទួលបាននូវតម្រូវការមូលដ្ឋានដូចជា ម្ហូបអាហារ ជម្រក សុខភាព និងការគាំពារឲ្យកាន់តែច្រើន និងមានលក្ខណៈទូលំទូលាយទៀតផង។

---

[4] ដកស្រង់គេហទំព័រ https://www.myaccountingcourse.com/accounting-dictionary/employment ចូលទស្សនាថ្ងៃទី ១២ ឧសភា ២០២០។

[5] Michael P. Todaro និង Stephen C. Smith, *Economics Development* [សេដ្ឋកិច្ចអភិវឌ្ឍន៍], 11 Edition (2011), 5។

២-ការកើនឡើងនៃកម្រិតជីវភាពរស់នៅរួមបន្ថែមលើការកើនឡើងនូវប្រាក់ចំណូល ការផ្តល់នូវការងារច្រើនជាងមុន ការអប់រំល្អប្រសើរ និងការយកចិត្តទុកដាក់ទៅលើវប្បធម៌ និងតម្លៃមនុស្ស។ អ្វីទាំងអស់នេះ មិនត្រឹមតែធ្វើឲ្យមានសុខុមាលភាពប៉ុណ្ណោះទេ តែថែមទាំងនាំឲ្យមានការចេះគោរពគ្នាទៅវិញទៅមកសម្រាប់បុគ្គលម្នាក់ៗ និងប្រទេសជាតិទាំងមូល។

៣-ការពង្រីកលំដាប់នៃជម្រើសនៅក្នុងសេដ្ឋកិច្ច និងសង្គមដែលអាចផ្តល់ឲ្យទៅបុគ្គល និងប្រទេសជាតិនូវសេរីភាពគេចចេញពីភាពជិះជាន់ និងភាពអាស្រ័យមិនត្រឹមត្រូវជាប់ពាក់ព័ន្ធនឹងមនុស្សផ្សេងទៀត និងរដ្ឋ ប៉ុន្តែវាជាកម្លាំងនៃភាពអវិជ្ជា និងទុរគតភាពរបស់មនុស្ស។[6]

## ១.៣. សញ្ញាណសំខាន់ៗនៃការអភិវឌ្ឍ

### ១.៣.១. គោលបំណងនៃការអភិវឌ្ឍ

ការអភិវឌ្ឍ គឺអាស្រ័យទៅលើគោលបំណងច្បាស់លាស់ ដើម្បីសម្រេចបានជាលទ្ធផល។ម្យ៉ាងវិញទៀត ការអភិវឌ្ឍគឺជាកត្តាជំរុញឲ្យមានការរីកចម្រើនតាមរយៈការទទួលបានចំណូលពីកម្រិតទាបឡើងទៅទទួលបានចំណូលកម្រិតខ្ពស់ ឬការទទួលបានចំណេះដឹងបន្ថែមជាដើម។ ដូច្នេះហើយទើបមានការបង្កើតការងារនៅជនបទ ដើម្បីជាជំនួយក្នុងការកាត់បន្ថយភាពក្រីក្រដោយមានការយកចិត្តទុកដាក់របស់រដ្ឋាភិបាលជាមួយនឹងការដាក់ចេញជាគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។ សកម្មភាពទាំងអស់នេះហើយបានបង្ហាញអំពីគោលបំណងនៃការបង្កើតការងារនៅជនបទដូចជា៖

- ធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាព និងគុណភាពជីវិតរស់នៅរបស់ប្រជាជននៅជនបទ
- បង្កើតការងារឲ្យបានគ្រប់គ្រាន់ ដើម្បីលុបបំបាត់ភាពក្រីក្រ
- ផ្តល់នូវសាលារៀន មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជាជំនួយសម្រាប់កាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ
- បង្កើតការវិនិយោគបន្ថែមទៅលើការងារតាមរយៈវិស័យកសិកម្ម វិស័យមិនមែនកសិកម្ម និងវិស័យទេសចរណ៍ ដែលស្ថិតក្រោមរូបភាពជាច្រើន។

### ១.៣.២. កត្តាសំខាន់ៗដែលនាំឲ្យមានការអភិវឌ្ឍ[7]

យោងតាមការសិក្សាកន្លងមក ដើម្បីឲ្យមានការអភិវឌ្ឍបាន គេត្រូវមើលលើកត្តាសំខាន់បួនមានដូចជា ដី ពលកម្ម មូលធន និងសហគ្រិនភាព។

[6] ដូច៥, ទំព័រ ២២។

[7] ម៉ម ចរិយារុធ និង ងួន ហេង, *សេដ្ឋកិច្ចនយោបាយ*, បោះពុម្ពលើកទី៥ (ភ្នំពេញ, ២០១៦), ១២-១៤។

**១.៣.២.១. ដី**

ក្នុងពាក្យប្រើប្រាស់ប្រចាំថ្ងៃ ដីសំដៅទៅលើដីដែលលាតសន្ធឹងនៅលើផ្ទៃផែនដី។ ទោះជាដូច្នេះក៏ដោយក្នុងន័យសេដ្ឋកិច្ច ដីរួមបញ្ចូលទាំងធនធានធម្មជាតិដែលបានរកឃើញនៅខាងលើ និងខាងក្រោមផ្ទៃដីដែលត្រូវបានប្រើដើម្បីផលិតទ្រព្យ និងសេវា។ ទឹក ព្រៃ និងរាល់ប្រភេទសត្វ និងរុក្ខជាតិមានជីវិតសុទ្ធតែទាក់ទងនឹងដី ហើយវាក៏មានបញ្ចូលផងដែរនូវធនធានរ៉ែ ឧស្ម័ន និងប្រេង។

**១.៣.២.២. ពលកម្ម**

ពាក្យ ពលកម្ម ជាទូទៅគិតទៅដល់រូបភាពនៃការងាររូបវន្ត។ ទោះជាដូច្នេះក៏ដោយ ក្នុងន័យសេដ្ឋកិច្ច វាមានន័យទូលាយជាង។ ពលកម្មរួមមាន ពេលវេលាធ្វើការងាររបស់មនុស្ស ការខិតខំប្រឹងប្រែង និងការស្ទាត់ជំនាញដែលបានគិតចូលទៅក្នុងការផលិតផលិតផល។ ដូច្នេះ ពលកម្មមិនគ្រាន់តែរួមមានការងារដែលធ្វើដោយកម្មកររោងចក្រ និងកម្មករសំណង់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏រួមបញ្ចូលផងដែរនូវការងារស្ថាបត្យករ សាស្ត្រាចារ្យ វេជ្ជបណ្ឌិត អ្នកលក់ដូរ និងបុគ្គលិករដ្ឋផងដែរ។

**១.៣.២.៣. មូលធន**

នៅពេលដែលអ្នកឮពាក្យ មូលធន ពេលនោះអ្នកប្រហែលជាគិតទៅដល់លុយហើយមើលទៅ។ ទោះជាដូច្នេះក៏ដោយ ក្នុងន័យសេដ្ឋកិច្ច មូលធនសំដៅទៅលើប្រភពដែលបានបង្កើតឡើង និងប្រើប្រាស់ដោយប្រជាជនដើម្បីផលិត និងចែកចាយទ្រព្យ និងសេវា។ ឧបករណ៍ ម៉ាស៊ីន និងរោងចក្រ គឺជារាល់ទម្រង់មូលធន។ វាក៏រួមបញ្ចូលផងដែរនូវកន្លែងធ្វើការ ឃ្លាំង ហាង ផ្លូវ និងយន្តហោះ។ និយាយម្យ៉ាងទៀត មូលធនគឺជារាល់ធនធានរូបវន្តរបស់ផលិតករ។ សម្រាប់ហេតុផលនេះ មូលធនមានពេលខ្លះគេហៅថា មូលធនរូបវន្ត ឬមូលធនពិត។

នៅពេលដែលអាជីវករធ្វើវិនិយោគទៅលើមូលធនពិត នោះកម្មករធ្វើវិនិយោគទៅលើមូលធនមនុស្សដែលវាមានតាំងពីការយល់ដឹង និងការស្ទាត់ជំនាញដែលទទួលបានបទពិសោធន៍ពីការអនុវត្តជាក់ស្តែង។ មូលធនមនុស្ស ក៏រួមបញ្ចូលផងដែរនូវកម្រិតវប្បធម៌ ឬកម្រិតវិជ្ជាជីវៈ។ នៅពេលដែលកម្មករ មានមូលធនមនុស្សកាន់តែច្រើននោះកម្រិតសមត្ថភាពផលិតកម្មកាន់តែធំ។

**១.៣.២.៤. សហគ្រិនភាព**

កត្តាផលិតកម្មទីបួន គឺសហគ្រិនភាព វាបញ្ចូលកត្តាបីផ្សេងទៀត។ សហគ្រិនភាព គឺជាការបញ្ចូលគ្នានៃចក្ខុវិស័យ ជំនាញវិស្វកម្មភាព(ingenuity) និងភាពសុខចិត្តទទួលយកហានិភ័យក្នុងការបង្កើត និងដំណើរការធុរៈកិច្ចថ្មី។ សហគ្រិនភាពច្រើនជាអ្នកបង្កើតថ្មី ពួកគេខិតខំប៉ាន់

ប្រមាណចំណង់ និងបំពេញចំណង់របស់អ្នកប្រើប្រាស់តាមវិធីផ្សេងៗ។ បញ្ហានេះអាចទាក់ទងទៅនឹងការបង្កើត ឬការធ្វើម៉ាឃិធីង ឬការបែងចែកផលិតផលថ្មី។ សហគ្រិនក៏ជាអ្នកប្រថុយប្រថានផងដែរនូវពេលវេលា ថាមពល ប្រឌិតញាណ និងលុយកាក់ដោយសង្ឃឹមថានឹងទទួលបានប្រាក់ចំណេញមកវិញ។ ការប្រថុយប្រថានរបស់គេ ក៏ទទួលបានភាពបរាជ័យផងដែរ។

## ១.៤. ការងារ និងនិកម្មភាព

### ១.៤.១. ប្រជាជនសកម្ម

ជាទូទៅ នៅក្នុងប្រទេសមួយគេតែងបែងចែកប្រជាជនជាប្រជាជនសកម្ម និងប្រជាជនមិនសកម្មក្នុងវិស័យសេដ្ឋកិច្ច។ ប្រជាជនសកម្ម ឬកម្លាំងពលកម្មរបស់ប្រទេសមួយ គឺផ្អែកលើកម្លាំងមនុស្សដែលចូលរួមជាក់ស្តែង ឬមានបំណងចូលរួមក្នុងការផលិតទំនិញ និងសេវាកម្ម។ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៃប្រទេសមួយអាស្រ័យលើចំនួនមនុស្សដែលសកម្មក្នុងផ្នែកសេដ្ឋកិច្ច គុណភាពការងារ និងភាពទៀងត្រង់របស់ពួកគេ។ ប្រជាជនមិនសកម្មរួមមាន មេផ្ទះ សិស្ស អ្នកនៅក្នុងបន្ទុក អ្នកទទួលប្រាក់ជួល អ្នកចូលនិវត្តន៍ ឬអ្នកទទួលប្រាក់ចំណូលដទៃទៀត និងអ្នកផ្សេងទៀតដែលអសកម្មក្នុងផ្នែកសេដ្ឋកិច្ចក្នុងអំឡុងពេលយូរ។

#### ១.៤.១.១. និយមន័យនៃប្រជាជនសកម្ម

ប្រជាជនសកម្ម ឬកម្លាំងពលកម្ម ជាអ្នកមានការងារធ្វើ និងគ្មានការងារធ្វើដោយឈរលើមូលដ្ឋានសកម្មភាពសំខាន់ៗ ដើម្បីផលិតផលិតផល និងផ្តល់សេវាកម្ម ហើយមានអាយុស្ថិតនៅចន្លោះ ១៥ឆ្នាំ ដល់ ៦៤ឆ្នាំ។[8] យោងតាមនិយមន័យខាងលើ យើងអាចកំណត់ចំនួនប្រជាជនសកម្ម ឬអ្នកនៅក្នុងកម្លាំងពលកម្មបានតាមរូបមន្តៈ

ប្រជាជនសកម្ម ឬអ្នកនៅក្នុងកម្លាំងពលកម្ម = អ្នកមានការងារធ្វើ + អ្នកគ្មានការងារធ្វើ។

### ១.៤.២. តម្រូវការពលកម្ម និងការងារ[9]

ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមមនុស្សបានជួបប្រទះនូវដំណាក់កាលផ្សេងៗគ្នា ហើយក្នុងដំណាក់កាលនីមួយៗតម្រូវការពលកម្ម និងការងារក៏ផ្សេងៗគ្នាដែរ។

#### ១.៤.២.១. ដំណាក់កាលប្រមូល និងប្រមាញ់

ដំណាក់កាលប្រមូល និងប្រមាញ់មាននៅស្ទើរគ្រប់ទីកន្លែងទាំងអស់ក្នុងពិភពលោក ដែលគេហៅថា សម័យកុម្មុយនីស្តបុព្វកាល។ នៅដំណាក់កាលនេះចាប់ផ្តើមចេញពីការផ្តាច់ខ្លួនពីសត្វ

[8] ព្រុំ ទេវី, រៀបរៀង, *សេដ្ឋកិច្ចនយោបាយ* (ភ្នំពេញ, ២០១៧), ៣០។

[9] ដូច៨, ទំព័រ ៣១។

របស់មនុស្ស ការធ្វើឲ្យប្រសើរឡើងនៃខ្លួនរបស់មនុស្ស ការកកើតឡើងនៃការងាររបស់មនុស្ស និងការអភិវឌ្ឍទំនាក់ទំនងសង្គម។ មនុស្សមិនមានប្រើអ្វីក្រៅពីដៃរបស់ខ្លួន ដើម្បីប្រមូលផលិតផលដែលមានស្រាប់នៅក្នុងធម្មជាតិ និងដុំថ្មមានរាងមុតស្រួចដើម្បីសម្លាប់សត្វយកមកធ្វើជាចំណីអាហារតែប៉ុណ្ណោះ។ ផលិតផលដែលគេអាចប្រមូលបានពីធម្មជាតិ គេក៏ពុំទាន់មានបច្ចេកទេស ឬវិធីសាស្ត្រដើម្បីថែរក្សាទុកសម្រាប់ប្រើប្រាស់ឲ្យបានយូរ ដូចនេះហើយគេត្រូវធ្វើការប្រមូល និងប្រមាញ់ជានិច្ចកាលដើម្បីចិញ្ចឹមជីវិតរបស់ពួកគេ។ លើសពីនេះទៀតមនុស្សត្រូវធ្វើការបម្លាស់ទីជម្រកញឹកញាប់ ដើម្បីរស់នៅកន្លែងដែលសម្បូរធនធានធម្មជាតិ។ ក្នុងដំណាក់កាលនេះនិយាយរួមសង្គមមនុស្សត្រូវការកម្លាំងពលកម្មច្រើន ហើយការងារក៏សម្បូរណាស់ដែរ តែដើម្បីសម្រាប់បំពេញតម្រូវការហូបចុក និងទីជម្រកងាយៗតែប៉ុណ្ណោះ។

### ១.៤.២.២. ដំណាក់កាលកសិកម្ម

ធនធានដែលមានស្រាប់នៅក្នុងធម្មជាតិ មិនអាចមានគ្រប់គ្រាន់ជារៀងរហូតសម្រាប់បំពេញតម្រូវការរបស់មនុស្សបានទេ។ ហេតុដូច្នេះហើយដើម្បីបំពេញតម្រូវការរបស់ខ្លួន មនុស្សបានចាប់ផ្ដើមចេះដាំដំណាំ និងចិញ្ចឹមសត្វ ហើយយកផលិតផលដែលគេធ្វើបាននោះមកប្រើប្រាស់ ដោះដូរដើម្បីយកវត្ថុ ឬឧបករណ៍ផ្សេងទៀតមកប្រើប្រាស់។ កសិកម្មរបៀបងាយៗនេះគេហៅថា កសិកម្មបែបប្រពៃណី។ នៅក្នុងវិស័យកសិកម្មបែបប្រពៃណី តម្រូវការកម្លាំងពលកម្ម និងការងារមានច្រើន ព្រោះទិន្នផលភាគច្រើនអាស្រ័យទៅនឹងលក្ខខណ្ឌរបស់ធម្មជាតិ ដែលកសិករម្នាក់អាចផលិតបានជាមធ្យមសម្រាប់ចិញ្ចឹមមនុស្សម្នាក់ ឬលើសពីនេះតិចតួច។

ជាមួយគ្នានឹងការរីកចម្រើននៃបច្ចេកវិទ្យា ប្រទេសអភិវឌ្ឍន៍មួយចំនួនបានប្រែក្លាយវិស័យកសិកម្មបែបប្រពៃណីនេះពីការផលិតរបស់កសិករម្នាក់ សម្រាប់បម្រើដល់ការប្រើប្រាស់មនុស្សម្នាក់ទៅជា ៥០នាក់ ឬលើសពីនេះទៅទៀត។ ការបញ្ចូលបច្ចេកវិទ្យាក្នុងវិស័យកសិកម្មមានដូចជាការប្រើប្រាស់ពូជថ្មីដែលមានទិន្នផលខ្ពស់ ត្រាក់ទ័រ ម៉ាស៊ីនច្រូតកាត់ និងម៉ាស៊ីនបោកជាដើមដែលធ្វើឲ្យការប្រើប្រាស់កម្លាំងពលកម្មថយចុះ។

### ១.៤.២.៣. ដំណាក់កាលសិប្បកម្ម និងឧស្សាហកម្មធុនស្រាល

នៅក្នុងជីវភាពប្រចាំថ្ងៃ មនុស្សមិនមែនត្រូវការតែអាហារមួយមុខនោះទេ ប៉ុន្តែគេត្រូវការឧបករណ៍ច្រើនមុខទៀត។ ផ្ដើមចេញពីតម្រូវការនេះទន្ទឹមគ្នានឹងការរកឃើញនូវរ៉ែដែក និងការចេះប្រើប្រាស់ភ្លើង មនុស្សបានបង្កើតវិស័យមួយទៀតគឺវិស័យសិប្បកម្ម និងបន្ទាប់មកទៀតវិស័យឧស្សាហកម្មធុនស្រាល។ ក្នុងវិស័យសិប្បកម្ម លទ្ធផលនៃការងារអាស្រ័យនឹងចំនួនមនុស្សដែល

គេប្រើប្រាស់ ព្រោះការងារស្ទើរតែទាំងអស់ត្រូវធ្វើដោយដៃ និងមានឧបករណ៍ជាជំនួយបន្តិចបន្តួចប៉ុណ្ណោះ។ ដំណើរការនេះប្រហាក់ប្រហែលគ្នាចំពោះវិស័យឧស្សាហកម្មធុនស្រាល ដែលវិស័យទាំងពីរនេះប្រើប្រាស់កម្លាំងពលកម្មបានគ្រប់រដូវកាល និងកាត់បន្ថយនិកម្មភាពផងដែរនៅប្រទេសកំពុងអភិវឌ្ឍន៍។

#### ១.៤.២.៤. ដំណាក់កាលឧស្សាហកម្មធុនធ្ងន់

នៅក្នុងដំណាក់កាលឧស្សាហកម្មធុនធ្ងន់ មានលក្ខណៈខុសពីឧស្សាហកម្មធុនស្រាល ព្រោះឧស្សាហកម្មធុនធ្ងន់ប្រើប្រាស់កម្លាំងពលកម្មតិច ហើយកម្លាំងពលកម្មភាគច្រើនទទួលបានការបណ្តុះបណ្តាលតាមលក្ខណៈបច្ចេកទេស ដើម្បីបញ្ជាគ្រឿងយន្តទំនើបៗ។

នាពេលបច្ចុប្បន្នឧស្សាហកម្មធុនធ្ងន់ភាគច្រើនមានតែនៅក្នុងប្រទេសអភិវឌ្ឍន៍ ឬគេហៅថាប្រទេសឧស្សាហកម្ម។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រទេសអភិវឌ្ឍន៍បាននឹងកំពុងផ្ទេរឧស្សាហកម្មធុនស្រាលមកកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឲ្យការប្រើប្រាស់កម្លាំងពលកម្មកាន់តែតិចហើយងាយស្រួលក្នុងការគ្រប់គ្រង។

ជាក់ស្តែងនៅក្នុងដំណាក់កាលនេះ បច្ចេកវិទ្យាជាកត្តាសំខាន់បំផុតដែលជួយឲ្យការផលិត និងការផ្តល់សេវាកម្មទទួលបានប្រសិទ្ធភាពខ្ពស់។ ម្ចាស់សហគ្រាស ក្រុមហ៊ុន ឬកសិដ្ឋានទូទៅប្រសិនបើគេមិនគិតពីផលប្រយោជន៍ផ្សេងទៀតដែលជាកត្តាមិនមែនសេដ្ឋកិច្ច គេតែងតែប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជំនួសកម្លាំងពលកម្មរបស់មនុស្ស។ ម្ល៉ោះហើយ គេអាចសរុបគំនិតបានថា បច្ចេកវិទ្យាកាន់តែជឿនលឿន កម្រិតនិកម្មភាពកាន់តែខ្ពស់។

### ១.៤.៣. និកម្មភាព

#### ១.៤.៣.១. និយមន័យ

និកម្មភាព គឺជាភាពគ្មានការងារធ្វើ។ និកម្មជន ឬអ្នកគ្មានការងារធ្វើជាអ្នកនៅក្នុងកម្លាំងពលកម្មមានលទ្ធភាពធ្វើការងារ បច្ចុប្បន្នគ្មានការងារធ្វើ និងកំពុងស្វែងរកការងារធ្វើក្នុងរយៈពេលមួយដែលបានកំណត់។[10] អ្នកដែលមិនរកការងារធ្វើដោយសារតែពួកគេមិនចង់ ឬបោះបង់ការស្វែងរកការងារធ្វើ ត្រូវបានចាត់ចូលក្នុងក្រុមអ្នកដែលមិនស្ថិតនៅក្នុងកម្លាំងពលកម្ម។

[10] ម៉ម ចរិយ៉ារុធ, *ម៉ាក្រូសេដ្ឋកិច្ច*, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៨), ៣០។

### ១.៤.៣.២. ទ្រឹស្តីនិកម្មភាព

#### ក. ទ្រឹស្តីក្លាស៊ីកនៃនិកម្មភាព

នៅក្នុងទ្រឹស្តីក្លាស៊ីក(Classical theory) និកម្មភាពត្រូវបានគេមើលឃើញថា ជាសញ្ញាណមួយដែលទីផ្សារកម្លាំងពលកម្មដំណើរការដោយរលូន ត្រូវបាននឹងកំពុងរាំងស្ទះដោយកត្តាមិនប្រក្រតីមួយចំនួន។[11] ទ្រឹស្តីក្លាស៊ីកលើកឡើងថា នៅចំណុចលំនឹងទីផ្សារ(E) ត្រង់កម្រិតថ្លៃឈ្នួលពលកម្ម($W_E$) និងតម្រូវការកម្លាំងពលកម្ម($L_E$) ទីផ្សារពលកម្មគ្មាននិកម្មភាពទេ ព្រោះបរិមាណផ្គត់ផ្គង់ពលកម្មស្មើនឹងបរិមាណតម្រូវការពលកម្ម។ ប៉ុន្តែទ្រឹស្តីក្លាស៊ីកសន្មតថា ប្រសិនបើម្ចាស់សហគ្រាសត្រូវបានគេទាមទារឲ្យជួលកម្លាំងពលកម្មនៅថ្លៃឈ្នួល(W*) ដែលជាថ្លៃឈ្នួលមួយខ្ពស់ជាងថ្លៃលំនឹងទីផ្សារ សេដ្ឋវិទូក្លាស៊ីកបានលើកឡើងថា ម្ចាស់សហគ្រាសនឹងជួលកម្លាំងពលកម្មតិចជាងមុន($L_D$) ខណៈដែលការផ្គត់ផ្គង់កម្លាំងពលកម្មកើនឡើងដល់($L_S$)។ នៅកម្រិតថ្លៃឈ្នួល(W*) ទីផ្សារពលកម្មនឹងមានភាពលើសនៃការផ្គត់ផ្គង់កម្លាំងពលកម្ម។ ភាពលើសនៃការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងទីផ្សារត្រូវបានគេហៅថា និកម្មភាពក្លាស៊ីកដោយស្ម័គ្រចិត្ត (Classical voluntary unemployment) (ក្រាហ្វិកទី១.១)។ តាមការបកស្រាយទ្រឹស្តីក្លាស៊ីកបានបង្ហាញថា ការកើតមានឡើងនៃនិកម្មភាពបណ្តាលមកពីការប្រែប្រួលថ្លៃឈ្នួលពលកម្មនៅក្នុងទីផ្សារការងារ។

ក្រាហ្វិកទី១.១៖ និកម្មភាពក្នុងគំរូក្លាស៊ីក




#### ខ. ទ្រឹស្តីកេនៃនិកម្មភាព

ទ្រឹស្តីកេនបានពន្យល់ថា និកម្មភាពគឺជាបាតុភូតដែលកើតឡើងដដែលៗ និងដោយអចេតនា ដែលតម្រូវការរួមមិនមានគ្រប់គ្រាន់ក្នុងអំឡុងពេលមួយនៅក្នុងវដ្តនៃអាជីវកម្មហើយនាំ

[11] Moeti Damane និង Lira P Sekansti, "The Sources of Unemployment in Lesotho" [ប្រភពនិកម្មភាពក្នុងក្រុងលេសូតូ], *Scientific Research Publishing* 9 (2018): 941។

ឲ្យកើតមានស្ថានភាពដែលគ្មានឱកាសការងារគ្រប់គ្រាន់ សម្រាប់ចំនួនមនុស្សដែលកំពុងតែស្វែងរកការងារធ្វើ។ លោក កេន បានពន្យល់ថា គ្មានថ្លៃ ឬថ្លៃឈ្នួលពលកម្មជាអ្នកកំណត់កម្រិតនៃភាពមានការងារធ្វើដូចដែលទ្រឹស្តីក្លាស៊ិកបានគិតនោះទេ តែតាមពិតគឺដោយសារតម្រូវការរួមនៃទ្រព្យ និងសេវាកម្មនៅក្នុងសេដ្ឋកិច្ច។ លោក កេន ជឿជាក់ថាប្រសិនបើថ្លៃឈ្នួលពលកម្មធ្លាក់ចុះលឿនក្នុងទីផ្សារពលកម្ម វានឹងមានឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច ពីព្រោះពលករដែលទទួលបានថ្លៃឈ្នួលទាប ពួកគេនឹងចំណាយតិច។ ប្រសិនបើពួកគេមិនចំណាយដើម្បីទិញផលិតផលច្រើនដូចមុននោះមានន័យថា វាបានកាត់បន្ថយតម្រូវការផលិតផលដែលត្រូវបាននឹងកំពុងផលិតដោយសហគ្រាសក្នុងសេដ្ឋកិច្ច។ ប្រសិនបើសហគ្រាសមិនអាចលក់ផលិតផលរបស់ពួកគេបានទេ ពួកគេនឹងកាត់បន្ថយការវិនិយោគ និងចំនួនកម្លាំងពលកម្មដែលពួកគេកំពុងជួល។ តម្រូវការរួមនៃផលិតផល និងសេវាកម្មទាបបង្កើតបានជាវដ្តនៃនិកម្មភាព ចំណូលទាប និងការចំណាយទាបនៅក្នុងសេដ្ឋកិច្ចជាថ្មីម្តងទៀត(ក្រាហ្វិកទី១.២)។ តាមការបកស្រាយខាងលើ ទ្រឹស្តីកេនបានបង្ហាញថា ដើម្បីបង្កើតការងារក្នុងគោលដៅកាត់បន្ថយនិកម្មភាពក្នុងសេដ្ឋកិច្ច ឬដើម្បីធ្វើឲ្យមានកំណើនសេដ្ឋកិច្ចត្រូវបង្កើនការវិនិយោគឲ្យបានច្រើន។

ក្រាហ្វិកទី១.២៖ ការកំណត់ការងារក្នុងគំរូកេន




### **១.៤.៣.៣. ប្រភេទផ្សេងៗនៃនិកម្មភាព**[12]

### **ក. និកម្មភាពដោយសារផ្លាស់ប្តូរការងារ**

និកម្មភាពដោយសារផ្លាស់ប្តូរការងារ គឺជានិកម្មភាពដែលកើតឡើងក្នុងស្ថានភាពដែលទីផ្សារពលកម្មដំណើរការធម្មតា។ ភាពគ្មានការងារនេះកើតឡើងដោយសារតែមានការចល័តមិនឈប់ឈររបស់ប្រជាជនពីតំបន់មួយទៅតំបន់មួយ ឬពីការងារមួយទៅការងារមួយ។ល។

[12] ដូច១០, ទំព័រ ៣១។

ទោះបីជាសេដ្ឋកិច្ចមានការងារពេញលេញក៏ដោយ ជានិច្ចកាលវាមានការប្រែប្រួលខ្លះៗ ដូចជាប្រជាជនស្វែងរកការងារធ្វើពេលដែលពួកគេបញ្ចប់ការសិក្សានៅសាលា ឬមានការផ្លាស់ប្តូរទៅរកកន្លែងថ្មី ឬស្ត្រីដែលចូលទៅក្នុងកម្លាំងពលកម្មវិញក្រោយបានសម្រាកពីការសម្រាលកូនរួច។ ដោយសារអ្នកគ្មានការងារប្រភេទនេះ ផ្លាស់ប្តូរពីការងារមួយទៅការងារមួយ ឬរកការងារថ្មីមួយដែលប្រសើរជាង ជួនកាលត្រូវបានចាត់ទុកជាអ្នកគ្មានការងារធ្វើស្ម័គ្រចិត្ត។ ទោះជាក្នុងពេលណាក៏ដោយក៏អត្រាគ្មានការងារធ្វើមិនអាចស្មើសូន្យឡើយ។

### ខ. និកម្មភាពដោយសារផ្លាស់ប្តូររចនាសម្ព័ន្ធ

និកម្មភាពដោយសារផ្លាស់ប្តូររចនាសម្ព័ន្ធ ជានិកម្មភាពដែលកើតឡើងដោយសារតែការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច។ និកម្មភាពប្រភេទនេះធ្វើឲ្យមានភាពបាត់បង់ការងារមួយចំនួនក្នុងសហគ្រាស។ ជាទូទៅវាកើតឡើងដោយសារតែតម្រូវការពលកម្មប្រភេទមួយកើតឡើង ក្នុងពេលដែលតម្រូវការពលកម្មប្រភេទមួយផ្សេងទៀតធ្លាក់ចុះ ហើយការផ្គត់ផ្គង់មិនបានកែតម្រូវទាន់ពេលវេលា។ ដូចនេះហើយយើងឃើញថា ជានិច្ចកាលមានភាពបាត់តុល្យភាពតាមការងារ ឬតាមទីកន្លែងដែលតំបន់មួយចំនួនមានការកើនឡើង ហើយតំបន់ខ្លះមានការធ្លាក់ចុះ។

### គ. និកម្មភាពខួប

និកម្មភាពខួប គឺជានិកម្មភាពដែលកើតឡើងនៅពេលដែលមានការធ្លាក់ចុះ(recession) និងមានការធ្លាក់ចុះដុនដាប(depression) នៃសេដ្ឋកិច្ច។ និកម្មភាពប្រភេទនេះកើតមាននៅពេលដែលតម្រូវការនៃពលកម្មទីផ្សារមានការធ្លាក់ចុះ។ ក្នុងខណៈដែលចំណាយរូម និងកម្រិតផលិតធាតុចេញ(output)ធ្លាក់ចុះ យើងឃើញមានភាពគ្មានការងារធ្វើកើនឡើងសឹងតែគ្រប់ទីកន្លែង។

## ១.៥. អត្ថប្រយោជន៍នៃការបង្កើតការងារនៅជនបទ

### ១.៥.១. អត្ថប្រយោជន៍ចំពោះគ្រួសារ

ប្រជាជនជនបទមួយភាគធំធ្វើការដោយប្រើកម្លាំងពលកម្ម ជាប្រភពដ៏សំខាន់នៃការស្វែងរកប្រាក់ឈ្នួលដើម្បីចិញ្ចឹមជីវិត។ ការបង្កើតការងារនៅជនបទនៅក្នុងវិស័យកសិកម្ម ទេសចរណ៍ ព្រមទាំងនៅក្នុងសហគ្រាសធុនតូច និងមធ្យមជាឧបករណ៍យ៉ាងសំខាន់ដែលធ្វើឲ្យគ្រួសារនីមួយៗអាចគេចចេញពីភាពក្រីក្រ។ ផ្ទុយទៅវិញ ភាពខ្វះខាតការងារកាត់បន្ថយលទ្ធភាពរបស់គ្រួសារក្នុងការធ្វើឲ្យប្រសើរឡើងនៃសុខុមាលភាពរបស់ពួកគេ។ លើសពីនេះទៀត ការងារភាគច្រើនដែលគ្រួសារនៅជនបទធ្វើជាការងារនៅក្នុងវិស័យកសិកម្ម ហើយចំណូលដែលបានមកពីក្នុងវិស័យកសិកម្មបានកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពគ្រួសារ។ ទោះបីការងារក្នុង

វិស័យកសិកម្មជាប្រភពចំណូលរបស់គ្រួសារជនបទយ៉ាងសំខាន់ក៏ដោយ ក៏ប៉ុន្តែការងារក្រៅពីវិស័យកសិកម្មក៏ជាប្រភពចំណូលសម្រាប់កាត់បន្ថយភាពក្រីក្របានមួយផ្នែកផងដែរ ជាពិសេសការបង្កើតឱកាសការងារដល់ស្ត្រី។ ការងារបានធ្វើឲ្យស្ត្រីមានអំណាចជាងមុននៅក្នុងគ្រួសារ និងការចូលរួមនៅក្នុងសង្គម។ ចំណូលដែលរកបានដោយស្ត្រីបន្ថែមពីលើបុរសក្នុងគ្រួសារពិតជាមានសារៈសំខាន់ក្នុងការលើកកម្ពស់ជីវភាពគ្រួសារដូចជា អាហារ សុខភាព ការអប់រំរបស់កុមារ ជាពិសេសកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។

### ១.៥.២. អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច

ការបង្កើតការងារមិនថានៅជនបទ ឬទីប្រជុំជន និងកំណើនសេដ្ឋកិច្ចគឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ការបង្កើតការងារពិតជាមានសារៈសំខាន់ណាស់ ពីព្រោះប្រជាជនមានការងារធ្វើកាន់តែច្រើន សេដ្ឋកិច្ចកាន់តែមានស្ថិរភាព។ ក្នុងន័យសេដ្ឋកិច្ច ប្រជាជនមានចំណូលដោយសារមានការងារធ្វើគ្រប់គ្នា ពួកគេនឹងចំណាយទៅលើផលិតផលប្រើប្រាស់ និងសេវាកម្មកាន់តែច្រើន។ បម្រើបម្រាស់ផលិតផល និងសេវាកម្មកាន់តែច្រើន ជាហេតុមួយនាំឲ្យម្ចាស់សហគ្រាស ឬម្ចាស់អាជីវកម្មបន្ថែមដើមទុនវិនិយោគលើអាជីវកម្មដើម្បីផលិតផលិតផល និងសេវាកម្មសម្រាប់ផ្គត់ផ្គង់ឲ្យទាន់តម្រូវការ ពោលគឺពួកគេមានតម្រូវការពលកម្មបន្ថែមទៀត។ កំណើននៃការផលិតផលិតផល និងសេវាកម្ម ធ្វើឲ្យមានកំណើនសេដ្ឋកិច្ច។ មិនតែប៉ុណ្ណោះការស្រូវយកកម្លាំងពលកម្មបែបនេះអាចកាត់បន្ថយអត្រានិកម្មភាព ដែលជាបញ្ហាចម្បងរបស់សេដ្ឋកិច្ចផងដែរ។

### ១.៥.៣. អត្ថប្រយោជន៍ចំពោះសង្គម

ការបង្កើតការងារសម្រាប់ប្រជាជនជនបទ មិនត្រឹមតែផ្ដល់អត្ថប្រយោជន៍ដល់គ្រួសារ និងសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែវាក៏បានផ្ដល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សង្គមផងដែរ។ ប្រជាជនជាកោសិកានៃសង្គម។ ដូច្នេះហើយប្រជាជនមានជីវភាពល្អប្រសើរ សង្គមក៏រីកចម្រើន ផ្ទុយទៅវិញប្រជាជនមានជីវភាពក្រីក្រ សង្គមក៏មានបញ្ហាដូចគ្នាដែរ។ ជាទូទៅជីវភាពប្រជាជនល្អប្រសើរឬដុនដាបអាស្រ័យនឹងប្រាក់ចំណូលរបស់គ្រួសារ។ ម្យ៉ាងទៀត និកម្មភាព ឬភាពគ្មានការងារធ្វើជាប្រភពនៃបញ្ហារបស់សង្គមដូចជា ការបង្កភាពអសន្តិសុខ អំពើហិង្សា ឧក្រិដ្ឋកម្មក្នុងសង្គមជាដើម។ ដូចនេះ ការបង្កើតឲ្យមានឱកាសការងារនៅជនបទជាវិធីសាស្ត្របង្កើតប្រាក់ចំណូល ដែលអាចនាំឲ្យគ្រួសារជនបទមានជីវភាពល្អប្រសើរ និងឈានទៅដល់ការកាត់បន្ថយបញ្ហាសង្គម។

# ជំពូកទី២
# ស្ថានភាពទូទៅនៃជនបទ
# កម្ពុជាឆ្នាំ២០១៣-២០១៩

# ជំពូកទី២

# ស្ថានភាពទូទៅនៃជនបទកម្ពុជាឆ្នាំ២០១៣-២០១៩

## ២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

ក្នុងអំឡុងពេលជាងពីរទសវត្សរ៍ ប្រទេសកម្ពុជាមានការផ្លាស់ប្តូរីកចម្រើនគួរឲ្យកត់សម្គាល់ដោយឈានទៅទទួលបានឋានៈ ជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ និងមានប្រាថ្នាថានឹងសម្រេចឲ្យបាននូវឋានៈ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។[13] បើទោះបីជាស្ថានភាពពិភពលោកកំពុងជួបប្រទះនូវបញ្ហាប្រឈម និងមានភាពមិនប្រាកដប្រជាជាច្រើន ជាពិសេសភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម បញ្ហាចលាចលនៅទីក្រុងហុងកុងនិងអស្ថិរភាពទីផ្សារហិរញ្ញវត្ថុសាកលលោកដែលបានធ្វើឲ្យសេដ្ឋកិច្ចចិន សហរដ្ឋអាមេរិក និងប្រទេសដទៃទៀតក្នុងតំបន់មានកំណើនថមថយក្តី សេដ្ឋកិច្ចកម្ពុជានៅតែអាចរក្សាបានកំណើនរឹងមាំក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ក្នុងឆ្នាំ២០១៨កន្លងទៅ កម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ។ កំណើននេះត្រូវបានគាំទ្រដោយកំណើនខ្ពស់លើសពីការរំពឹងទុកនៃអនុវិស័យកាត់ដេរ កំណើនរឹងមាំនៃអនុវិស័យសំណង់ និងអនុវិស័យអចលនទ្រព្យ អនុវិស័យមិនមែនកាត់ដេរស្របនឹងកំណើនល្អប្រសើរនៃអនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូននិងគមនាគមន៍ និងអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន។ សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៩ ត្រូវបានប៉ាន់ស្មានថានឹងបន្តកំណើនខ្ពស់ក្នុងរង្វង់ ៧,១% ដែលគាំទ្រដោយការកើនឡើងខ្ពស់នៃអនុវិស័យសំណង់ អនុវិស័យអចលនទ្រព្យ និងអនុវិស័យដឹកជញ្ជូននិងគមនាគមន៍ ស្របនឹងកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ អនុវិស័យមិនមែនកាត់ដេរ អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងអនុវិស័យលក់ដុំ-រាយ ខណៈពេលវិស័យកសិកម្មត្រូវបានរំពឹងថានឹងបន្តកំណើនយឺត។ ក្នុងនោះវិស័យឧស្សាហកម្មបានដើរតួយ៉ាងសំខាន់ជាវិស័យជំរុញកំណើន និងកើនឡើងក្នុងអត្រាប្រមាណ ១១,០% ដោយសារកំណើនរឹងមាំនៃអនុវិស័យសំណង់ និងអនុវិស័យមិនមែនកាត់ដេរ បើទោះបីជាកំណើនអនុវិស័យកាត់ដេរមានការថមថយបន្តិចក៏ដោយ។ ដោយឡែកវិស័យសេវាកម្មនៅតែបន្តកំណើនល្អប្រសើរក្នុងអត្រាប្រមាណ ៦,៧% ដែលគាំទ្រដោយការកើនឡើងនៃអនុវិស័យអចលនទ្រព្យ អនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ និងអនុវិស័យសណ្ឋាគារ និង

[13] ធនាគារពិភពលោក, *ធនាគារពិភពលោកនៅកម្ពុជា៖ ទិដ្ឋភាពទូទៅ*, https://www.worldbank.org/km/country/cambodia/overview ចូលទស្សនាថ្ងៃទី ១៣ ឧសភា ២០២០។

ភោជនីយដ្ឋាន។ វិស័យកសិកម្មនៅបន្តកំណើនយឺត ពោលគឺក្នុងអត្រា ១,0% ដោយសារការថមថយកំណើននៃអនុវិស័យដំណាំ បើទោះបីជាអនុវិស័យចិញ្ចឹមសត្វ អនុវិស័យនេសាទអាចរក្សាបានកំណើនប្រហាក់ប្រហែលឆ្នាំ២០១៨ក្តី។ ជាមួយកំណើនរឹងមាំក្នុងឆ្នាំ២០១៩នេះ ផលិតផលក្នុងស្រុកសរុប(ផ.ផ.ស) ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ១០៨.២៩៨ប៊ីលានរៀលដែលធ្វើឲ្យ ផ.ផ.ស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១.៦៧៩ដុល្លារ។[14] ក្នុងក្របខណ្ឌខាងលើនេះ កម្ពុជាត្រូវធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំដោយបរិយាបន្ន និងចីរភាព ដែលជាមូលដ្ឋានសម្រាប់ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យព្រមទាំងការបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជន។

ក្រាហ្វិកទី២.១៖ អត្រាកំណើន ផ.ស.ស ឆ្នាំ២០១០-២០១៩




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ២.២. ស្ថានភាពប្រជាជនជនបទ

### ២.២.១. ភាពក្រីក្រ

ភាពក្រីក្រមានច្រើនទម្រង់ដែលពោរពេញទៅដោយភាពប្រទាក់ក្រឡា និងគ្មានកត្តាណាមួយជាមូលហេតុពិតប្រាកដនោះទេ។ មូលហេតុជាច្រើនដែលបណ្តាលឲ្យមានភាពក្រីក្រកើតឡើងដូចជា កត្តាប្រវត្តិសាស្ត្រនយោបាយ គ្រោះមហន្តរាយធម្មជាតិ បញ្ហាដីកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត (ស្ថាប័នធារាសាស្ត្រ និងផ្លូវថ្នល់) ការអប់រំ និងភាពមានការងារធ្វើ។

[14] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ការវាយតម្លៃកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០១៩*, https://www.mef.gov.kh/ ចូលទស្សនាថ្ងៃទី ១៣ ឧសភា ២០២០។

ប្រវត្តិសាស្ត្រនយោបាយដូចជា ការប្រល័យពូជសាសន៍ សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ និងអស្ថិរភាពនយោបាយ គឺជាលក្ខខណ្ឌបឋមដែលបណ្តាលឲ្យមានអត្រាខ្ពស់នៃភាពក្រីក្រនៅតំបន់ជនបទ។ គ្រោះធម្មជាតិ រួមផ្សំនឹងឥទ្ធិពលរបស់ការឡើងកម្តៅលើផែនដី និងការថយចុះនៃធនធានធម្មជាតិបានដាក់សម្ពាធកាន់តែខ្លាំងទៅលើប្រជាជនក្រីក្រនៅតាមជនបទ ដែលពឹងផ្អែកយ៉ាងខ្លាំងលើរបរកសិកម្ម។ ម្យ៉ាងវិញទៀត ដីកសិកម្មដែលមានទំហំតូច ក៏ជាបញ្ហាដែលកើតមានយូរមកហើយ ដោយវាប៉ះពាល់ដល់លទ្ធភាពកសិកម្ម ដែលអាចបណ្តាលឲ្យភាពក្រីក្រអាចកើតមានឡើងកាន់តែច្រើន។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាកត្តាមួយយ៉ាងសំខាន់នៅក្នុងការគណនានៃភាពក្រីក្រ ព្រោះថាស្ថាប័នដែលទន់ខ្សោយអាចបង្អាក់ដំណើរការអភិវឌ្ឍ។ ប្រព័ន្ធធារាសាស្ត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ ប៉ុន្តែ ប្រជាកសិករកម្ពុជាធ្វើកសិកម្មតាមបែបប្រពៃណី ការធ្វើស្រែចម្ការដោយមិនប្រើប្រាស់គ្រឿងយន្តកសិកម្ម គ្មានបច្ចេកទេសគ្រប់គ្រាន់ ពោលគឺពឹងផ្អែកលើអាកាសធាតុ ខណៈដែលកសិករនៅជនបទត្រូវពឹងផ្អែកលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត ហើយឱកាសការងារផ្សេងទៀតនៅតំបន់ជនបទដែលជាប្រភពចំណូលចម្បងគឺមានកំណត់។[15]

ភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះ បើទោះបីការធ្លាក់ចុះមានភាពយឺតយ៉ាវជាងកាលពីមុនក្តី។ អត្រានៃភាពក្រីក្ររបស់ប្រជាជនបានថយចុះពី ៥៣,៣% នៅក្នុងឆ្នាំ២០០៤ មកត្រឹម ១៣,៥% នៅក្នុងឆ្នាំ២០១៤។ ឧបសគ្គចម្បងៗក្នុងការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺការអភិវឌ្ឍយឺតនៃផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងអតុល្យភាពក្នុងការទទួលបាន និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

#### ២.២.១.១. ការវាស់នៃភាពក្រីក្រ

ភាពក្រីក្រ ត្រូវបានវាស់វែងដោយមានការកំណត់ត្រឹមត្រូវច្បាស់លាស់ ដោយធ្វើការបង្ហាញពីការរស់នៅរបស់ប្រជាជនតាមតំបន់ជនបទ។ ជាក់ស្តែង យោងតាមធនាគារពិភពលោក (WB) គឺបានធ្វើការវាស់ភាពក្រីក្រដោយគិតតាមរយៈការរកចំណូលរបស់មនុស្សម្នាក់តិចជាង ១,៩០ដុល្លារអាមេរិកក្នុងមួយថ្ងៃ មានន័យថាគឺស្ថិតក្នុងខ្សែបន្ទាត់នៃភាពក្រីក្រ។[16]

---

[15] វិទ្យាស្ថានសភាកម្ពុជា, *មូលហេតុនៃភាពក្រីក្រ និងគោលនយោបាយពាក់ព័ន្ធទីជនបទកម្ពុជា* (ភ្នំពេញ៖ វ.ស.ក, ២០១៥), ១-២, https://www.pic.org.kh/images/2015Research/20160422_Causes%20of%20Rural%20Poverty%20in%20Cambodia_KH.pdf ថតចម្លងថ្ងៃទី ២០ ឧសភា ២០២០។

[16] ធនាគារពិភពលោក, *Principles and Practice In Measuring Global Poverty* [គោលការណ៍ និងការអនុវត្តក្នុងការវាស់ភាពក្រីក្រជាសាកល], https://www.worldbank.org/en/news/feature/2016/01/13/principles-and-practice-in-measuring-global-poverty ចូលទស្សនាថ្ងៃទី១៩ មេសា ២០២០។

តាមបច្ចុប្បន្នភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា បានធ្វើការវាស់វែងភាពក្រីក្រតាមរយៈ បន្ទាត់នៃភាពក្រីក្រអាហារថ្នាក់ជាតិតែមួយ (ដោយផ្អែកលើរបបអាហារមិនផ្លាស់ប្តូរ) និងការចំណាយមិនមែនអាហារនៅក្នុងតំបន់ទាំង៣។ បន្ទាត់នៃភាពក្រីក្ររបស់ប្រទេសកម្ពុជាត្រូវបានឲ្យនិយមន័យថា ជាកម្រិតនៃការចំណាយលើអាហារ និងមិនមែនអាហារប្រចាំថ្ងៃរបស់មនុស្សម្នាក់ក្នុងតម្លៃបច្ចុប្បន្ននៅតាមតំបន់នីមួយៗ(ភ្នំពេញ ប្រជុំជន និងជនបទ)។

បន្ទាត់នៃភាពក្រីក្រត្រូវបានឲ្យនិយមន័យ ជាស្ថានភាពរស់នៅក្នុងភាពក្រីក្រនៅពេលប្រាក់ចំណូលរបស់គ្រួសារ ឬមនុស្សម្នាក់ស្ថិតនៅក្រោមកម្រិតមួយកំណត់។ បន្ទាត់នៃភាពក្រីក្ររបស់មនុស្សម្នាក់ត្រូវបានកំណត់ដោយរដ្ឋាភិបាល ដោយផ្អែកលើការចំណាយដើម្បីទទួលបានអាហារចាំបាច់ក្នុងបរិមាណ ២.១០០គីឡូកាឡូរី រួមផ្សំទាំងមុខចំណាយដែលមិនមែនអាហារ (ផ្ទះសម្បែង សម្លៀកបំពាក់ជារបស់របរផ្ទាល់ខ្លួន និងការលំហែផ្សេងៗជាដើម) ក្នុងកម្រិតអប្បបរមាអាស្រ័យទៅតាមស្ថានភាពអភិវឌ្ឍន៍របស់ឃុំ-សង្កាត់។[17]

ក្នុងនេះ រូបមន្តសម្រាប់គណនារកខ្សែបន្ទាត់នៃភាពក្រីក្រត្រូវបានកំណត់ដូចខាងក្រោម៖

| ខ្សែបន្ទាត់នៃភាពក្រីក្រ = ការចំណាយម្ហូបអាហារ+ការចំណាយមិនមែនម្ហូបអាហារ |
|---|

បន្ទាត់នៃភាពក្រីក្រម្ហូបអាហារសម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ គណនាដោយយោងលើបរិមាណម្ហូបអាហារសរុបដែលផ្តល់ថាមពល ២.២០០គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ។ បន្ទាប់មកយើងគណនាថា ដើម្បីបានថាមពល ២.២០០គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃគេត្រូវចំណាយប្រាក់អស់ប៉ុន្មានរៀល?

ចំណែកឯការគណនាបន្ទាត់នៃភាពក្រីក្រមិនមែនម្ហូបអាហារវិញ យើងយកស្មើនឹងអត្រាចំណាយលើទំនិញ និងសេវាមិនមែនម្ហូបអាហាររបស់ក្រុមពលរដ្ឋណាដែលបានចំណាយសរុបលើការប្រើប្រាស់ស្មើនឹងបន្ទាត់នៃភាពក្រីក្រម្ហូបអាហារ។

ប្រជាពលរដ្ឋនៅជនបទណា ដែលបានចំណាយប្រចាំថ្ងៃក្រោមបន្ទាត់នៃភាពក្រីក្រត្រូវបានចាត់ជាប្រជាពលរដ្ឋក្រីក្រ ហើយប្រជាពលរដ្ឋណាដែលបានចំណាយលើបន្ទាត់នៃភាពក្រីក្រមិនត្រូវបានចាត់ជាប្រជាពលរដ្ឋក្រីក្រទេ។[18]

[17] ហាង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ៣៥៣។

[18] ធនាគារពិភពលោក, *តើប្រជាពលរដ្ឋក្រីក្រទៅទីណាអស់ហើយ? ការវាយតម្លៃភាពក្រីក្រឆ្នាំ២០១៣* (ភ្នំពេញ៖ ធនាគារពិភពលោក, ២០១៣), ៨។

### ២.២.១.២. មូលហេតុនៃភាពក្រីក្រ

ភាពក្រីក្រមានការប្រែប្រួល និងវិវឌ្ឍទៅតាមពេលវេលា ដែលជាការលំបាកក្នុងការកំណត់មូលហេតុនៃភាពក្រីក្រ។ ប៉ុន្តែគេសង្កេតឃើញមានកត្តាសំខាន់មួយចំនួនដែលបានកើតមានឡើងចំពោះប្រជាជននៅជនបទដូចជា៖

-កត្តាដីកសិកម្ម៖ ជាកត្តាមួយដ៏សំខាន់នៅក្នុងដំណើរការផលិតកម្មកសិកម្ម ពីព្រោះវាកំណត់នូវកម្រិតផលិតភាពកសិកម្ម និងភាពក្រីក្រ។ ការវាយតម្លៃថ្មីៗនេះ បានកត់សម្គាល់អំពីការកើតអ្នកដែលគ្មានដី ហើយអ្នកដែលខ្វះខាតដីក្នុងចំណោមប្រជាជនក្រីក្រនៅតំបន់ជនបទ។ គ្រួសារក្រីក្រ គឺពឹងអាស្រ័យជីវិតរបស់ពួកគេទៅលើដីកសិកម្ម ហើយឯកសារវាយតម្លៃភាពក្រីក្របានកំណត់ថា ការទទួលបានដីធ្លី និងមានដីគឺជាទ្រព្យដ៏សំខាន់បំផុតរបស់ពួកគេ។ ទោះជាយ៉ាងនេះក្តីអត្រាគ្រួសារកសិករដែលកំពុងរស់នៅតំបន់ជនបទ ជាពិសេសតំបន់ទំនាបដែលកាន់កាប់ដីកសិកម្មតិចជាង ១ហិកតា បានកើនឡើងពី ៥៦% (ឆ្នាំ២០០៩) ដល់ ៧៣% (ឆ្នាំ២០១១) ជាងនេះទៅទៀត ប្រជាជនតែប្រមាណ ២០% ប៉ុណ្ណោះដែលកាន់កាប់ដីកសិកម្មក្នុងចន្លោះពី ១ហិកតា និង២ហិកតា។ ដីកសិកម្មដែលមានទំហំតូច ក៏បានឆ្លុះបញ្ចាំងពីអត្រាខ្ពស់នៃភាពក្រីក្រនៅតាមបណ្តាតំបន់ជនបទ និងវិសមភាពរយៈពេលវែងដែរ។

-កត្តាហេតុការណ៍ដែលមិនបានព្រៀងទុកនៃភាពក្រីក្រ៖ ជារួមប្រជាជនក្នុងតំបន់ជនបទភាគច្រើនលើសលុបធ្វើការងារក្នុងវិស័យកសិកម្ម និងចិញ្ចឹមជីវិតដោយពឹងផ្អែកលើដីកសិកម្មដដែល ហើយដីកសិកម្មមានទំហំតូចងាយប្រឈមនឹងហេតុការណ៍ដែលមិនបានព្រៀងទុកមានដូចជា ការធ្លាក់ចុះនៃគុណភាពដីដែលកាន់តែគ្មានជីជាតិបណ្តាលឲ្យទទួលបាននូវទិន្នផលទាប ឬក៏កត្តាធនធានធម្មជាតិដែលបានកើតឡើងមានដូចជា ទីមួយគឺគ្រោះមហន្តរាយធម្មជាតិទឹកជំនន់ ឬភាពរាំងស្ងួត ទីពីរគឺការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តរភាព។[19]

-កត្តាមួយចំនួនទៀតដូចជា៖ ទីមួយ គឺកត្តាបុគ្គល ក្នុងន័យនេះចង់បង្ហាញពីជំនាញទាប កង្វះខាតទ្រព្យធន អក្ខរកម្មទាប គ្រួសារមានទំហំធំ ហើយក៏អាចមានកត្តាជនជាតិភាគតិច និងយេនឌ័រទៀតផង។ ទីពីរ គឺកត្តាទីតាំងដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមកិច្ច (ផ្លូវថ្នល់ ទឹកភ្លើង ការថែទាំសុខភាព ការអប់រំជាដើម)។ កត្តាទីបី គឺកត្តារចនាសម្ព័ន្ធដូចជា កង្វះព័ត៌មានទីផ្សារ សេវាហិរញ្ញវត្ថុ និងឥណទាន។

[19] ដូច១៨, ទំព័រ ១។

### ២.២.៣. ចំណាកស្រុក

ប្រជាជននៅតំបន់ជនបទតែងតែកើតមានឡើងការធ្វើចំណាកស្រុក ដោយហេតុថាប្រាក់ចំណូលដែលរកបានពុំទាន់គ្រប់គ្រាន់ក្នុងការបំពេញសេចក្តីត្រូវការរបស់ខ្លួន ឬពុំមានការងារធ្វើពេញលេញនៅជនបទ ទើបប្រជាជនជាច្រើនត្រូវបានជំរុញឲ្យធ្វើការចំណាកស្រុកមករស់នៅ និងធ្វើការងារនៅទីក្រុង ឬត្រូវចំណាកស្រុកទៅក្រៅប្រទេសជាដើម ដោយមានក្តីរំពឹងថាពួកគាត់នឹងអាចរកបាននូវប្រាក់កម្រៃច្រើនជាងនៅជនបទ ជាពិសេសចាកផុតពីភាពក្រីក្រ និងមានជីវភាពប្រសើរឡើង។ មានប្រជាជនខ្លះធ្វើការចាកចេញពីស្រុកតែម្នាក់ឯង ដោយបន្សល់ទុកនូវសមាជិកគ្រួសារដទៃទៀតនៅឯស្រុកឲ្យរង់ចាំ និងទទួលបានប្រាក់បញ្ញើពីខ្លួន។ ចំណែកប្រជាជនខ្លះទៀតបានសម្រេចចិត្តធ្វើការចំណាកស្រុកជាលក្ខណៈគ្រួសារតែម្តង។ ដោយសារប្រជាជនកម្ពុជាមានវ័យក្មេងដ៏ច្រើនបានឈានជើងចូលក្នុងទីផ្សារការងារ ជាមួយនឹងឱកាសការងារនៅមានកម្រិតហើយប្រាក់ឈ្នួល ដែលកាន់តែមានភាពទាក់ទាញនៅក្រៅប្រទេសបានធ្វើឲ្យប្រជាជនមានគំនិតឬធ្វើចំណាកស្រុក ក្នុងនេះដែរមានការប៉ាន់ប្រមាណថាកម្លាំងពលកម្មវ័យក្មេងចំនួន ៣០០.០០០ នាក់ បានចូលក្នុងទីផ្សារការងារក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ហើយភាគច្រើនពួកគេគ្មានជំនាញឡើយ។[20] ជាក់ស្តែងគេសង្កេតឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំការចំណាកស្រុកក្នុងប្រទេសពីជនបទមកទីក្រុងភ្នំពេញមិនមានការថយចុះទេ។ ផ្ទុយទៅវិញ វាមាននិន្នាការកើនឡើងជាលំដាប់។ នៅទីក្រុងភ្នំពេញ អ្នកធ្វើចំណាកស្រុកពីតំបន់ជនបទទទួលបានការងារនៅក្នុងវិស័យមួយចំនួនរួមមាន វិស័យសំណង់ វិស័យកាត់ដេរ វិស័យសេវាកម្មលក់ម្ហូបអាហារ សេវាកម្មសប្បាយ សេវាកម្មលាងរថយន្ត សេវាកម្មបម្រើការតាមផ្ទះ និងការងារនៅតាមក្រុមហ៊ុនតូចធំជាដើម។ល។ ការងាររបស់ពួកគេទោះបីមិនទទួលបានកម្រៃច្រើនមែន ប៉ុន្តែវាប្រសើរជាងការងារនៅជនបទ។[21] ទាំងអស់នេះបានបញ្ជាក់ឲ្យឃើញថា កំណើនសេដ្ឋកិច្ចដែលមានកន្លងមក និងតាមរយៈការធ្វើវិនិយោគបន្តពុំទាន់បានចូលរួមក្នុងការបង្កើតការងារឲ្យសមស្រប ដែលអាចស្រូបយកកម្លាំងពលកម្មនៅក្នុងទីផ្សារការងារនៅឡើយ ជាពិសេសនៅតំបន់ជនបទ។

[20] ថៃ សុម៉ារី និងឡា ស៊ីឡៃ, "ការធ្វើចំណាកស្រុក", (របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩), ៤០។

[21] ខ្លឹ១, "ចំណាកស្រុកពីជនបទចូលទៅទីក្រុងភ្នំពេញ", ០៩ មេសា ២០១៧, https://thmeythmey.com/?page=detail&id=51308 ចូលទស្សនាថ្ងៃទី ២០ ឧសភា ២០២០។

### ២.២.៤. មូលហេតុចំណាកស្រុក

ការធ្វើចំណាកស្រុក គឺជាបញ្ហាសាកលដែលត្រូវបានជំរុញដោយសាកលភាវូបនីយកម្ម សង្គមនយោបាយ និងការអភិវឌ្ឍខាងសេដ្ឋកិច្ច។ ក្នុងនេះដែរមូលហេតុនៃការធ្វើចំណាកស្រុកត្រូវបានចែកចេញជាពីរកត្តាដូចជា "កត្តាទាក់ទាញ" និង "កត្តាជំរុញ"។[22] កត្តាជំរុញ គឺអ្វីដែលមិនអំណោយផល និងអនុគ្រោះដល់ទីតាំងដែលគេរស់នៅ ឬវាពាក់ព័ន្ធនឹងលក្ខខណ្ឌដែលជំរុញឲ្យមានការសម្រេចចិត្តធ្វើចំណាកស្រុកនៅក្នុងប្រទេស ឬក្រៅប្រទេសផ្សេងដើម្បីស្វែងរកជីវភាពឲ្យប្រសើរជាងមុន។ រីឯកត្តាទាក់ទាញ គឺជាអ្វីដែលធ្វើឲ្យគេជាប់ចិត្តទៅនឹងតំបន់នោះ ឬសំដៅទៅលើលក្ខខណ្ឌដែលទាក់ទាញមនុស្សពីកន្លែងផ្សេងមករស់នៅក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅកាន់តែប្រសើរឡើង។

កត្តាជំរុញ៖ ការងារមិនគ្រប់គ្រាន់ ឱកាសការងារតិចតួច លក្ខខណ្ឌជំបូង គ្រោះទុរ្ភិក្ស ឬគ្រោះរាំងស្ងួត ការភ័យខ្លាចផ្នែកនយោបាយ ភាពជាទាសករ ឬការបង្ខំឲ្យធ្វើការ សេវាកម្មថែទាំសុខភាពខ្វះខាត ការបាត់បង់សុខដុមរមនា គ្រោះធម្មជាតិ ការគំរាមកំហែងដល់ជីវិត កង្វះខាតសេរីភាពនយោបាយឬសាសនា បញ្ហាបំពុល ខ្វះទីលំនៅ បញ្ហាកម្មសិទ្ធិដីធ្លី ម្ចាស់ដី ការសម្លុតគំរាម ការប្រកាន់ពូជសាសន៍ ឱកាសក្នុងការរៀបអាពាហ៍ពិពាហ៍ ថ្កោលទោសនិងសង្គ្រាមជាពិសេសគេសង្កេតឃើញនៅតំបន់ជនបទ។

កត្តាទាក់ទាញ៖ ឱកាសការងារមានច្រើន លក្ខខណ្ឌរស់នៅល្អ សេរីភាពផ្នែកនយោបាយ និងសាសនា ការងារ ការអប់រំ សេវាថែទាំសុខភាពល្អ បរិយាកាសទាក់ទាញ សន្តិសុខមានសុវត្ថិភាពទំនាក់ទំនងគ្រួសារ ឧស្សាហកម្ម និងឱកាសល្អក្នុងការរៀបអាពាហ៍ពិពាហ៍ជាដើម។ ប៉ុន្តែការសិក្សាជាច្រើនបានបង្ហាញឃើញថា ការជាប់ជំពាក់បំណុលក៏ជាមូលហេតុមួយជំរុញឲ្យប្រជាជនធ្វើចំណាកស្រុកដែរ។ ភាពកង្វះជំនាញដែលធ្វើឲ្យមនុស្សពិបាកស្វែងរកការងារធ្វើនៅក្នុងប្រទេសបានធ្វើឲ្យពួកគេធ្វើចំណាកស្រុកផងដែរ។ ភាពកង្វះខាតដីដែលអំណោយផល ក៏ជាកត្តាដ៏សំខាន់មួយដែលជំរុញឲ្យប្រជាជនចាកចេញពីសហគមន៍របស់ពួកគេ និងចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេងទៀត។ ស្ថានភាពទាំងអស់នេះបានឆ្លុះបញ្ចាំងពីការកើនឡើងនៃចំនួនអ្នកគ្មានដីធ្លីក្នុងចំណោមអ្នកក្រីក្រនៅតំបន់ជនបទ។ ការសិក្សាផ្សេងទៀតបានបង្ហាញពីហេតុផលពាក់ព័ន្ធ ការខូចខាតផលដំណាំ ដែលជំរុញឲ្យប្រជាជននៅតំបន់ជនបទផ្លាស់ទីលំនៅចេញពី

[22] សុង ឧស្សាហ៍, "ទេសន្តរប្រវេសន៍ពលករខ្មែរ", (និក្ខេបបទថ្នាក់បណ្ឌិត, រាជបណ្ឌិតសភាកម្ពុជា, ២០១៦), ១១។

សហគមន៍។ ដូច្នេះការរួមផ្សំនៃកត្តាទាំងអស់នេះបានធ្វើឲ្យមានការចំណាកស្រុកនៅកម្ពុជាជាពិសេសនៅតំបន់ជនបទ។

## ២.៣. ការអប់រំនៅជនបទឆ្នាំ២០១៣-២០១៨

### ២.៣.១. អក្ខរកម្ម

អក្ខរកម្ម គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងជាគ្រឹះសម្រាប់ការសិក្សាពេញមួយជីវិត។ អក្ខរកម្មមានតួនាទីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ព្រមទាំងជួយធ្វើឲ្យជីវិតមានការផ្លាស់ប្តូរ។ អត្រាអក្ខរកម្មសម្រាប់ប្រជារាស្ត្រពេញវ័យត្រូវបានកំណត់ជាចំណែកប្រជារាស្ត្រដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង ហើយមានសមត្ថភាពអាចចេះអាន និងចេះសរសេរលិខិតងាយៗបានជាភាសាមួយបាន។[23]

តាមរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៧-២០១៨ និងទិសដៅឆ្នាំសិក្សា២០១៨-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡាបានបង្ហាញថា អត្រាអក្ខរកម្មសម្រាប់ប្រជារាស្ត្រពេញវ័យ (អាយុចាប់ពី១៥ឆ្នាំឡើង) បានប្រែប្រួលពី ៨០,៥% នៅឆ្នាំ២០១៥ ដល់ ៨៤,៥% នៅឆ្នាំ២០១៦ និងនៅឆ្នាំ២០១៧ មាន ៨២,៥%។[24] អត្រាអក្ខរកម្មសម្រាប់ប្រជារាស្ត្រពេញវ័យ (អាយុចាប់ពី១៥ឆ្នាំឡើង) បានកើនឡើង ២,០% ចាប់តាំងពីឆ្នាំ២០១៥ មកដល់ឆ្នាំ២០១៧។ ការកើនឡើងនៃអត្រាអក្ខរកម្មនេះបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការកែទម្រង់ប្រព័ន្ធអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ការចូលរួមពីស្ថាប័នពាក់ព័ន្ធ អង្គការឃុំណោស្កូ និងដៃគូអភិវឌ្ឍន៍។

អក្ខរកម្មប្រជារាស្ត្រពេញវ័យ(អាយុ១៥ឆ្នាំឡើង) នៅជនបទបានបង្ហាញថា នៅឆ្នាំ២០១៣ មានការប្រែប្រួលពី ៧៧,៣% មកត្រឹម ៧៣,៩% នៅឆ្នាំ២០១៤។ អត្រានេះបានកើនឡើងមក ៧៦,៨% នៅឆ្នាំ២០១៥ ហើយបានកើនឡើងបន្តទៀត ៨១,៦% នៅឆ្នាំ២០១៦ និង ៧៩,៣% នៅឆ្នាំ២០១៧ សម្រាប់អក្ខរកម្មប្រជារាស្ត្រពេញវ័យទាំងពីរភេទ។ អក្ខរកម្មប្រជារាស្ត្រពេញវ័យ(អាយុ១៥ឆ្នាំឡើង) នៅជនបទមានការកើនឡើង ២,០% សម្រាប់ប្រជារាស្ត្រពេញវ័យទាំងពីរភេទចាប់តាំងពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧។ ការកើនឡើងនេះមានកម្រិតអត្រាខ្ពស់សម្រាប់បុរសជាងស្ត្រី ប៉ុន្តែមិនមានភាពខុសគ្នាដែលគួរឲ្យកត់សម្គាល់ឡើយ(ក្រាហ្វិកទី២.២)។

[23] វិទ្យាស្ថានជាតិស្ថិតិ, *ការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៤* (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៥), ៦៥។

[24] ក្រសួងអប់រំ យុវជន និងកីឡា, *របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៧-២០១៨* (ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩), ៨៨។

ក្រាហ្វិកទី២.២៖ អត្រាអក្ខរកម្មប្រជារាស្ត្រពេញវ័យ(១៥ឆ្នាំឡើង)ជនបទឆ្នាំ២០១៣-២០១៧




*ប្រភព៖ ដកស្រង់ពី CSES ឆ្នាំ២០១៣ ដល់២០១៧*

## ២.៣.២. ស្ថានភាពសិក្សា

### ក. ការអប់រំបឋមសិក្សា

អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាខ្ពស់ជាង ៩៥% និងអត្រាពិតនៃការសិក្សាលើស ៩៨% ចន្លោះឆ្នាំសិក្សា២០១៣-២០១៤ ដល់ឆ្នាំសិក្សា២០១៧-២០១៨។ អត្រាបោះបង់ការសិក្សាបានថយចុះពី ១០,៥% ឆ្នាំសិក្សា២០១៣-២០១៤ មកត្រឹម ៤,១% ឆ្នាំសិក្សា២០១៧-២០១៨ និងអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនពី ៧៦,៨% ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៨៦% ឆ្នាំសិក្សា២០១៧-២០១៨។[25]

នៅឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សារដ្ឋមាន ៧.២២៣ កើន ៣៩ ធៀបនឹងឆ្នាំសិក្សា២០១៧-២០១៨។ សាលារៀនមិនគ្រប់កម្រិតមាន ៤៦៤ ថយ ៦៨។ សាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍន៍មាន ៥.៥៥២ កើន ២៣០។ សាលាបឋមសិក្សាឯកជនមាន ៤៨៨ នៅគ្រប់រាជធានី-ខេត្ត។ សិស្សបឋមសិក្សារដ្ឋមាន ២.០៤០.២៥៧នាក់ ស្រី ៩៧៨.៨០០នាក់ ស្មើនឹង ៤៨,០% កើន ១១.៥៦៣នាក់ ស្រីកើន ៣.២៣៧នាក់។ សិស្សបឋមសិក្សាឯកជនមាន ១២២.៨៨៦នាក់ ស្រី ៦១.១៣៦នាក់ ស្មើ ៤៩,៨%។ អត្រាពិតចូលរៀនថ្មីសរុប ៩៧,៥% ស្រី

[25] ក្រសួងអប់រំ យុវជន និងកីឡា, *ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២០២៣* (ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩), ៣៧។

៩៧,៥% កើន ២,៣% ស្រីកើន ២,៥% ក្នុងនោះឯកជនកើន ១,១% ស្រីកើន ១,១% និងរដ្ឋកើន ១,២% ស្រីកើន ១,៣%។[26]

ក្រាហ្វិកទី២.៣៖ ចំនួនសិស្សបឋមសិក្សាឆ្នាំសិក្សា២០១៧-២០១៨ និង២០១៨-២០១៩




*ប្រភព៖ ស្ថិតិ និងសូចនាករអប់រំសោធារណៈឆ្នាំ២០១៨-២០១៩*

នៅឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សរៀននៅបឋមសិក្សាសរុបចំនួន ២.០៤០.២៥៧ នាក់ ដែលក្នុងនោះសិស្សនៅតំបន់ជនបទមានចំនួន ១.៧០០.៩៣១នាក់ ដែលនៅឆ្នាំសិក្សា ២០១៧-២០១៨ សិស្សដែលរៀននៅបឋមសិក្សា ២.០២៨.៦៩៤នាក់ ដែលក្នុងនោះនៅតំបន់ជនបទមានសិស្សប្រមាណ ១.៧២៦.៩៦៩នាក់។ តាមទិន្នន័យខាងលើយើងសង្កេតឃើញថាអត្រានៃការចុះឈ្មោះចូលរៀនរបស់សិស្សនៅបឋមសិក្សានៅតំបន់ជនបទមានការកើនឡើងជាងឆ្នាំសិក្សា២០១៧-២០១៨ (ក្រាហ្វិកទី២.៣)។

**ខ. ការអប់រំមធ្យមសិក្សា**

ការអប់រំមធ្យមសិក្សា ពិសេសមធ្យមសិក្សាទុតិយភូមិបំពេញតួនាទីយ៉ាងសំខាន់ចន្លោះពីការអប់រំបឋមសិក្សា និងទីផ្សារការងារ។ ការអប់រំកម្រិតនេះ គឺជាកំណត់ពីឱកាសអប់រំ និងឱកាសការងារនាពេលអនាគតសម្រាប់យុវជន។

ឆ្នាំសិក្សា២០១៨-២០១៩ គ្រឹះស្ថានមធ្យមសិក្សារដ្ឋមានចំនួន ១.៧៧១ កើន ២៣ ក្នុងនោះ អនុវិទ្យាល័យ ១.២៤៦ កើន ៩ និងវិទ្យាល័យ ៥២៥ កើន ១៤។ គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ២២៥ កើន ២៧ ក្នុងនោះអនុវិទ្យាល័យ ៧៨ កើន ១២ និងវិទ្យាល័យ ១៤៧ កើន២៥។ អត្រារួមនៃ

[26] ដូច២៤, ទំព័រ ៤១។

ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥៩,១% ថយ ០,១% ស្រី ៦៣,៨% កើន ០,៥% ក្នុងនោះគ្រឹះស្ថានសិក្សារដ្ឋ ៥៦,៥% ស្រី ៦១,១% និងឯកជន ២,៦% ស្រី ២,៧%។ អត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិ ២៩,៧% ស្រី ៣២,៩% ក្នុងនោះគ្រឹះស្ថានសិក្សារដ្ឋមាន ២៨,១% ស្រី ៣១,២% និងឯកជន ១,៦% ស្រី ១,៧%។[27]

តារាងទី២.១៖ ចំនួនសិស្សនៅមធ្យមសិក្សាឆ្នាំសិក្សា២០១៧-១៨ និង២០១៨-១៩

| បរិយាយ | | មធ្យមសិក្សាបឋមភូមិ(រដ្ឋ) | មធ្យមសិក្សាទុតិយភូមិ(រដ្ឋ) |
|---|---|---|---|
| ២០១៨-១៩ | សិស្សសរុប | ៦១០.២៦១ | ៣២១.១៩៥ |
| | ប្រជុំជន | ១២០.៤៨៣ | ៩៦.១០៩ |
| | ជនបទ | ៤៨៩.៧៧៨ | ២២៥.០៣៦ |
| ២០១៧-១៨ | សិស្សសរុប | ៦០៤.៩៩១ | ៣០៣.៩៤៧ |
| | ប្រជុំជន | ១០៨.៤៧២ | ៨៨.៤១៩ |
| | ជនបទ | ៤៩៦.៥១៩ | ២១៥.៥២៨ |

*ប្រភព៖ ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ២០១៨-១៩*

នៅឆ្នាំសិក្សា២០១៧-២០១៨ មានសិស្សរៀននៅមធ្យមសិក្សាបឋមភូមិសាធារណៈសរុបមានចំនួន ៦០៤.៩៩១នាក់ ដែលក្នុងនោះសិស្សនៅតំបន់ជនបទមានចំនួន ៤៩៦.៥១៩នាក់ និងនៅឆ្នាំសិក្សា២០១៨-២០១៩ សិស្សដែលរៀននៅមធ្យមសិក្សាបឋមភូមិសាធារណៈសរុបចំនួន ៦១០.២៦១នាក់ ដែលក្នុងនោះនៅតំបន់ជនបទមានសិស្សចំនួន ៤៨៩.៧៧៨នាក់ ដែលចំនួននេះមានការថយចុះបន្តិចបើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។ ចំណែកសិស្សរៀននៅមធ្យមសិក្សាទុតិយភូមិសាធារណៈនៅឆ្នាំសិក្សា២០១៧-២០១៨ មានសិស្សសរុបចំនួន ៣០៣.៩៤៧នាក់ ដែលក្នុងនោះសិស្សនៅតំបន់ជនបទមានចំនួន ២១៥.៥២៨នាក់ និងនៅឆ្នាំសិក្សា២០១៨-២០១៩ សិស្សសរុបមានចំនួន ៣២១.១៩៥នាក់ ក្នុងនោះសិស្សនៅជនបទមានចំនួន ២២៥.០៣៦នាក់។ ចំនួននេះមានការកើនឡើងបន្តិចធៀបនឹងឆ្នាំកន្លងទៅ។

### គ. អត្រាលំហូរសិស្ស

អត្រាឡើងថ្នាក់មធ្យមសិក្សាបឋមភូមិប្រែប្រួលពី ៨២,១% នៅឆ្នាំសិក្សា២០១៦-២០១៧ មក ៨១,៧% នៅឆ្នាំសិក្សា២០១៧-២០១៨ ពោលគឺថយ ០,៥% ចំពោះតំបន់ជនបទបានថយចុះ ០,៧% គឺពី ៨១,៤% មកត្រឹម ៨០,៧% ចំណែកមធ្យមសិក្សាទុតិយភូមិ អត្រាឡើងថ្នាក់បានកើន

[27] ដូច២៣, ទំព័រ ៥៦។

១,៨% ពី ៧៩,៣% ទៅ ៨១,១% និងតំបន់ជនបទបានកើនឡើង ២,៧% ពី ៧៨,១% ទៅ ៨០,៨% ។ អត្រាត្រួតថ្នាក់មធ្យមសិក្សាបឋមភូមិបានប្រែប្រួលពី ២,៦% នៅឆ្នាំសិក្សា២០១៦-២០១៧ មក ២,៥% នៅឆ្នាំសិក្សា២០១៧-២០១៨ ចំពោះតំបន់ជនបទបានថយចុះពី ២,៤% មក ២,៣% ចំណែកមធ្យមសិក្សាទុតិយភូមិបានថយចុះ០,៤% ពី ២,៤% មក ២,០% និងជនបទបានថយចុះពី ២,៣% មកត្រឹម ១,៧%។ ប្រការនេះបញ្ជាក់ឲ្យឃើញថា កំណែទម្រង់វិស័យអប់រំបានជះឥទ្ធិពលវិជ្ជមានដល់ការសិក្សាអប់រំ ជាពិសេសការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន វិធីសាស្ត្របង្រៀន និងការបង្កើតក្លឹបសិក្សាជាដើម។

តារាងទី២.២៖ អត្រាលំហូរសិស្សរវាងឆ្នាំសិក្សា២០១៦-១៧ និង២០១៧-១៨

| បរិយាយ | | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៧-១៨ | ថ្នាក់ជាតិ | ៨៩,៤ | ៦,២ | ៤,៤ | ៨១,៧ | ២,៥ | ១៥,៥ | ៨១,១ | ២,០ | ១៦,៩ |
| | ប្រជុំជន | ៩១,៩ | ៤,៤ | ៣,៧ | ៨៥,៧ | ៣,២ | ១១,០ | ៨១,៩ | ២,៥ | ១៥,៦ |
| | ជនបទ | ៨៨,៩ | ៦,៦ | ៤,៥ | ៨០,៧ | ២,៣ | ១៧,០ | ៨០,៨ | ១,៧ | ១៧,៥ |
| ២០១៦-១៧ | ថ្នាក់ជាតិ | ៨៩,៤ | ៦,៥ | ៤,១ | ៨២,១ | ២,៦ | ១៥,៤ | ៧៩,៣ | ២,៤ | ១៨,៣ |
| | ប្រជុំជន | ៩៣,១ | ៤,៤ | ២,៥ | ៨៤,៦ | ៣,១ | ១២,២ | ៨១,៩ | ២,៦ | ១៥,៥ |
| | ជនបទ | ៨៨,៦ | ៦,៩ | ៤,៤ | ៨១,៤ | ២,៤ | ១៦,១ | ៧៨,១ | ២,៣ | ១៩,៧ |

*ប្រភព៖ ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ២០១៧-២០១៨ និង២០១៨-២០១៩*

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិបានប្រែប្រួលពី ១៥,៤% នៅឆ្នាំសិក្សា ២០១៦-២០១៧ មក ១៥,៥% នៅឆ្នាំសិក្សា២០១៧-២០១៨ ពោលគឺកើនឡើងបន្តិច ០,១% ចំពោះតំបន់ជនបទបានថយចុះ ០,៦% គឺពី ១៦,១% មកត្រឹម ១៥,៥% ចំណែកឯមធ្យមសិក្សាទុតិយភូមិ អត្រាបោះបង់ការសិក្សាបានថយចុះ ១,៤% ពី ១៨,៣% មក ១៦,៩% និងតំបន់ជនបទបានថយចុះពី ១៩,៧% ទៅ ១៧,៥% ពោលគឺបានថយចុះ ២,២%។ បើទោះបីនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិនៅតំបន់ជនបទមានអត្រាបោះបង់ការសិក្សាថយចុះក៏ដោយ ប៉ុន្តែអត្រាបោះបង់ការសិក្សានៅមានកម្រិតខ្ពស់នៅឡើយ ដែលបណ្តាលមកពីសាលារៀននៅឆ្ងាយពីផ្ទះ កង្វះគ្រូបង្រៀនដែលមានសមត្ថភាព កង្វះសៀវភៅសិក្សាគោល សម្ភារៈសិក្សា កង្វះបច្ចេកទេសបង្រៀនរបស់គ្រូ និងកង្វះអាហារូបករណ៍របស់សិស្សដែលគ្រួសារមានជីវភាពទាប ឬសិស្សកំព្រាគ្មានទីពឹង ជាពិសេសអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់នៅជនបទ ដោយសារសិស្សត្រូវបង្ខំចិត្តបោះបង់ការសិក្សាដើម្បីជួយធ្វើការងារកសិកម្មរបស់ម្តាយឪពុក ឬរកប្រាក់

ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម ឬបណ្តាលមកពីតំបន់ជនបទមិនទាន់មានសេវាអប់រំគ្រប់គ្រាន់។

## ២.៤. ហេដ្ឋារចនាសម្ព័ន្ធជនបទ

### ២.៤.១. ផ្លូវជនបទ

ការដឹកជញ្ជូនតាមផ្លូវថ្នល់ ជាមធ្យោបាយមួយសម្រាប់ចរាចរផលិតផល និងមនុស្សនៅកម្ពុជា។ ផ្លូវថ្នល់ មានសារៈសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជាពិសេសក្នុងតំបន់ដែលផ្លូវថ្នល់ជាមធ្យោបាយដឹកជញ្ជូន ក៏ប៉ុន្តែនាពេលបច្ចុប្បន្នកម្ពុជានៅពុំទាន់មានផ្លូវថ្នល់គ្រប់គ្រាន់នៅឡើយទេ។ ផ្លូវជនបទ ជាផ្លូវថ្នល់មួយប្រភេទដែលមានលក្ខណៈដូចជា៖ (ទី១)-ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក-ខណ្ឌ ទីប្រជុំជនឃុំ-សង្កាត់ និងទីភូមិ។ (ទី២)-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក-ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក-ខណ្ឌ។ (ទី៣)-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក-ខណ្ឌ ទៅកាន់ក្រុង ទីប្រជុំជនឃុំ-សង្កាត់។ (ទី៤)-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ-សង្កាត់ ទៅកាន់ទីប្រជុំជនឃុំ-សង្កាត់ (ទី៥)-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ-សង្កាត់ ទៅកាន់ភូមិ (ទី៦)-ផ្លូវដែលភ្ជាប់ពីភូមិ ទៅកាន់ភូមិ។ (ទី៧)-ផ្លូវក្នុងភូមិ។[28] បច្ចុប្បន្នប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែង ៦១.៥៣៨គីឡូម៉ែត្រ។ ក្នុងនោះផ្លូវជនបទមានប្រវែង ៤៥.២៤២គីឡូម៉ែត្រ ដែលស្មើនឹងប្រមាណ ៧៤% នៃប្រវែងផ្លូវថ្នល់សរុប។ គិតត្រឹមឆ្នាំ២០១៧ ផ្លូវជនបទប្រហែល ៥% ក្រាលកៅស៊ូ ឬបេតុង និងផ្នែកនៅសល់ជាផ្លូវដី ឬក្រួសក្រហម។[29]

ការអភិវឌ្ឍផ្លូវជនបទចាំបាច់ត្រូវប្រែក្លាយពីផ្លូវដី ឬផ្លូវក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងក្នុងការពង្រីករាល់សកម្មភាពរវាងមជ្ឈមណ្ឌលសេដ្ឋកិច្ចជនបទនិងទីប្រជុំជន និងធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រសិទ្ធភាពសេដ្ឋកិច្ច។ កម្ពុជាទទួលបានជំនួយហិរញ្ញវត្ថុពីស្ថាប័នអន្តរជាតិជាច្រើនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) អង្គការក្រៅរដ្ឋាភិបាល(NGOs) ធនាគារពិភពលោក (WB) និងជំនួយរបស់រដ្ឋាភិបាលដែលជាដៃគូអភិវឌ្ឍន៍ជាច្រើនក្នុងការអភិវឌ្ឍផ្លូវជនបទឲ្យប្រសើរឡើង និងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទដើម្បីទីផ្សារកសិករ ពាណិជ្ជូបនីយកម្មកសិកម្ម និងវិស័យផ្សេងទៀតដែលពាក់ព័ន្ធ។

---

[28] *ថ្មីៗ*, "ភាពខុសគ្នារវាង ផ្លូវថ្នល់ ផ្លូវជនបទ ផ្លូវខេត្ត និងផ្លូវជាតិ", ២២ ឧសភា ២០១៧, https://thmeythmey.com/?page=detail&id=52675 ចូលទស្សនាថ្ងៃទី ១៤ ឧសភា ២០២០។

[29] ធនាគារអភិវឌ្ឍន៍អាស៊ី, *Transport sector assessment, strategy, and road map* [ការវាយតម្លៃវិស័យដឹកជញ្ជូន យុទ្ធសាស្ត្រ និងផែនទីផ្លូវ] (ធនាគារអភិវឌ្ឍន៍អាស៊ី, ២០១៩), ៤-៥, https://www.adb.org/sites/default/files/institutional-document/529231/cambodia-transport-assessment-strategy-road-map.pdf ចូលថតចម្លងថ្ងៃទី ១៨ ឧសភា ២០២០។

### ២.៤.២. អគ្គិសនី

អគ្គិសនី ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង៤ (ផ្លូវ ទឹក ភ្លើង និងមនុស្ស) ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណគ្រប់ដំណាក់កាលដើម្បីជំរុញការអភិវឌ្ឍប្រទេស។ ការទទួលបានថាមពលអគ្គិសនីប្រើប្រាស់ ភាគច្រើនមាននៅរាជធានីភ្នំពេញ និងនៅទីប្រជុំជន ចំណែកតំបន់ជនបទ ការទទួលបានថាមពលអគ្គិសនីប្រើប្រាស់នៅមានកម្រិតនៅឡើយ។ ជាក់ស្តែងការទទួលការប្រើប្រាស់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ និងនៅទីប្រជុំជនមានប្រមាណ ៩៩% យ៉ាងណាមិញគិតត្រឹមឆ្នាំ២០១៧ ប្រជាជននៅតំបន់ជនបទប្រមាណ ៨៦% ទទួលបានថាមពលអគ្គិសនីប្រើប្រាស់តាមរយៈទម្រង់ផ្សេងៗ។[30] ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងការបង្កើតសុខដុមរមនីយភាពនៃការរស់នៅរបស់ប្រជាជននៅជនបទ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងរ៉ែ និងថាមពលបានជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទបន្តទៀតដើម្បីធ្វើយ៉ាងណាឲ្យសម្រេចនូវគោលដៅចំនួនពីរគឺ៖

១-ដល់ឆ្នាំ២០២០ គ្រប់ភូមិទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពផ្សេងៗ និង

២-ដល់ឆ្នាំ២០៣០ យ៉ាងហោច ៧០% នៃគ្រួសារទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីដែលមានគុណភាពដូចជាអគ្គិសនីពីខ្សែបណ្តាញជាតិប្រើប្រាស់។

### ២.៤.៣. ប្រព័ន្ធធារាសាស្រ្ត

#### ២.៤.៣.១. ប្រព័ន្ធស្រោចស្រព

ប្រទេសកម្ពុជា ជាប្រទេសសម្បូរទៅដោយធនធានទឹក និងប្រព័ន្ធទន្លេដូចជា ទន្លេមេគង្គ បឹងទន្លេសាប ទន្លេសាប ស្ទឹង និងដៃទន្លេនានា។ ប្រភពធនធានទឹកទាំងអស់នេះ គឺជាប្រភពធនធានមូលដ្ឋានសម្រាប់បម្រើឲ្យដល់ការអភិឌ្ឍសេដ្ឋកិច្ចជាតិដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសិប្បកម្ម ថាមពលអគ្គិសនី នាវាចរណ៍ វប្បធម៌ ទេសចរណ៍ និងបម្រើឲ្យការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ។ បើទោះបីប្រទេសកម្ពុជាសម្បូរដោយធនធានទឹក និងប្រព័ន្ធទន្លេ ប៉ុន្តែជារៀងរាល់ឆ្នាំប្រជាជនកម្ពុជាភាគច្រើនតែងតែជួបប្រទះនូវភាពខ្វះខាតទឹកនៅរដូវប្រាំង និងកូនរដូវប្រាំងដែលតែងតែកើតឡើងនៅក្នុងរដូវវស្សា ដោយសារតែហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនៅមានកម្រិតនៅឡើយ និងប្រព័ន្ធធារាសាស្ត្រមួយចំនួនមានសភាពចាស់ទ្រុឌទ្រោមដែលមាន

[30] រ.ស.ក, *Status and Challenges of Rural Electrification in Cambodia and Renewable Energy Option* [ស្ថានភាព និងបញ្ហាប្រឈមនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជនបទ និងជម្រើសថាមពលកើតឡើងវិញ] (ភ្នំពេញ៖ រ.ស.ក, ២០១៩), ១-២។

ការលំបាកដល់ការរក្សាទឹកទុក ការបែងចែកទឹក និងការផ្តល់ទឹកសម្រាប់វិស័យកសិកម្ម និងវិស័យផ្សេងទៀត ព្រមទាំងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទផង។ នាពេលបច្ចុប្បន្ន កម្ពុជាមានប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងធំប្រហែល ២.៤០០ប្រព័ន្ធ ដែលអាចផ្តល់សក្តានុពលទឹកស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលចំនួន ១,០៩៦លានហិកតា (៥៨២.០៨៥ហិកតានៅរដូវវស្សា និង២៩៦.២៨៨ហិកតានៅរដូវប្រាំង)។ ចំនួនប្រព័ន្ធធារាសាស្ត្រមានសមត្ថភាពស្រោចស្រពលើផ្ទៃដីដាំដុះទាំងរដូវវស្សា និងរដូវប្រាំងបានត្រឹមតែ ២៧% ទៅ ៤០% ប៉ុណ្ណោះលើផ្ទៃដីដំណាំស្រូវ ដែលការគ្របដណ្តប់នេះនៅមានកម្រិតនៅឡើយ។[31] អវត្តមាននៃប្រព័ន្ធធារាសាស្ត្រ មានន័យថាកសិករត្រូវពឹងផ្អែកលើទឹកភ្លៀងដែលធ្លាក់មិនទៀងទាត់ និងមិនអាចវិនិយោគលើធាតុចូលកសិកម្មដូចជា គ្រាប់ពូជ និងជីជាដើម។

### ២.៤.៣.២. ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទក៏ ជាផ្នែកមួយក្នុងការលើកកម្ពស់ជីវភាពប្រជាជនជនបទដែរ។ សម្រាប់ប្រទេសកម្ពុជា លទ្ធភាពក្នុងការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតត្រូវបានកំណត់ទៅតាមការធ្វើឲ្យប្រសើរឡើងនូវប្រភពទឹកស្អាតដែលមានស្រាប់។ ការធ្វើឲ្យប្រសើរឡើងនូវប្រភពទឹកស្អាតមិនសំដៅទៅលើប្រភពទឹកដែលមានសុវត្ថិភាពនោះទេ ក៏ប៉ុន្តែសំដៅទៅលើប្រភពទឹកទំនងជាអាចផ្តល់នូវទឹកស្អាតយកមកប្រើប្រាស់។ ប្រភេទនៃប្រភពទឹកស្អាតរួមមានបណ្តាញទឹកម៉ាស៊ីនចូលក្នុងលំនៅឋានឬក្នុងបរិវេណលំនៅឋាន ទឹកសាធារណៈឬបំពង់ទឹកសាធារណៈ អណ្តូងស្នប់ឬអណ្តូងខួង អណ្តូងជីកមានលូការពារ និងទឹកភ្លៀងដែលមានការកែលម្អ។ នៅឆ្នាំ២០១៦ ស្ថានភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាពលរដ្ឋនៅជនបទមានការកើនឡើង ៥៣% ខណៈដែលស្ថានភាពអនាម័យជនបទសម្រេចបាន ៥៦%។ ចំនួននេះមានការកើនឡើងបើប្រៀបធៀបនឹងឆ្នាំ២០១៥ ដែលមានអត្រាគ្របដណ្តប់អនាម័យជនបទ ៤៦,២% និងការប្រើប្រាស់ទឹកស្អាតមានអត្រា ៥២%។[32] ក្នុងការបន្តលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននៅតំបន់ជនបទ រាជរដ្ឋាភិបាលបានប្តេជ្ញានឹងធ្វើឲ្យសម្រេចបាននូវគោលដៅក្នុងឆ្នាំ២០២៥ ឲ្យប្រជាពលរដ្ឋជនបទ ១០០% មានទឹកស្អាតប្រើប្រាស់ និងមានអនាម័យស្អាត។

---

[31] ធនាគារពិភពលោក, *The Agriculture, Irrigation, and Rural Roads Sectors: Public Expenditure Review* [វិស័យកសិកម្ម ប្រព័ន្ធធារាសាស្ត្រ និងផ្លូវជនបទ៖ ការចំណាយសាធារណៈ] (វ៉ាស៊ីនតោន ឌីស៊ី៖ ធនាគារពិភពលោក), ១៣។

[32] ភ្នំពេញប៉ុស្តិ៍, "ការប្រើប្រាស់ទឹកស្អាតនិងការលើកកម្ពស់អនាម័យជនបទ", ៣១ មីនា ២០១៧, https://www.phnompenhpost.com/national/rural-access-water-sanitation-improves ចូលទស្សនាថ្ងៃទី ២០ ឧសភា ២០២០។

## ២.៥. ស្ថានភាពការងារជនបទ

### ២.៥.១. ការបែងចែកការងារតាមវិស័យសេដ្ឋកិច្ច

ចំនួនការងារសរុបក្នុងវិស័យកសិកម្ម និងឧស្សាហកម្មបានកើនឡើងនៅចន្លោះឆ្នាំ២០០៤ ដល់ ២០០៩ ខណៈដែលការងារក្នុងវិស័យសេវាកម្មបានធ្លាក់ចុះ។ វិស័យកសិកម្ម ជាវិស័យសំខាន់ជាងគេក្នុងការបង្កើតការងារសម្រាប់ប្រជាជននៅជនបទ ដែលបានផ្តល់ការងារបានប្រមាណ ៦៨% នៃការងារជនបទ (ជាង៤លាននាក់ក្នុងឆ្នាំ២០០៩)។ ចំនួននេះបានកើនឡើងបន្តិចចន្លោះឆ្នាំ២០០៤ ដល់ ២០០៩។ ចំណែកការងារដែលបានផ្តល់ដោយវិស័យឧស្សាហកម្ម ក៏មានការកើនឡើងបន្តិចផងដែរ គឺពី ១៤% ក្នុងឆ្នាំ២០០៤ ទៅ ១៥% ក្នុងឆ្នាំ២០០៩ ដែលផ្តល់ការងារជូនប្រជាជននៅជនបទជាង ៩០៧.២០០នាក់។ ផ្ទុយទៅវិញ ការផ្តល់ការងារដោយវិស័យសេវាកម្មបានធ្លាក់ចុះពី ២១% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៧% ក្នុងឆ្នាំ២០០៩ ជាមួយនឹងការជួលមនុស្សត្រឹមតែជាង ១លាននាក់។ រីឯវិស័យឧស្សាហកម្មក៏ជាវិស័យដឹកនាំក្នុងការបង្កើតការងារនៅជនបទផងដែរ។ ប្រភពការងាររបស់វិស័យឧស្សាហកម្មនៅតំបន់ជនបទរួមមាន ឧស្សាហកម្មផលិតស្អុរស សម្លៀកបំពាក់ និងស្បែកជើង វាយនភណ្ឌ ផលិតផលលោហៈ ផលិតផលម្ហូបអាហារ និងសាធាតុគីមី។ បើទោះបីការបង្កើតការងារសរុបរបស់វិស័យនេះហាក់នៅកម្រិតទាបក៏ដោយ ក៏វិស័យនេះបង្កើតការងារបាន ១៦២.៧៣៦នាក់ នៅចន្លោះឆ្នាំ២០០៤ ដល់ ២០០៩។ តួលេខនេះបានកើនឡើង ២២% ក្នុងអំឡុងពេលនោះ(២០០៤-២០០៩) ដែលមានអត្រាកើនឡើងជាមធ្យម ៤% ក្នុងមួយឆ្នាំ(តារាងទី២.៣)។[33]

តារាងទី២.៣៖ កំណើនការងារនៅជនបទឆ្នាំ២០០៤-២០០៩

| វិស័យ | ២០០៤ | | ២០០៩ | | អត្រាបម្រែបម្រួល ២០០៤-០៩ | អត្រាបម្រែបម្រួលក្នុងមួយឆ្នាំ |
|---|---|---|---|---|---|---|
| | កម្លាំងពលកម្ម | % | កម្លាំងពលកម្ម | % | | |
| កសិកម្ម | ៣.៥៥៨.១០០ | ៦៥ | ៤.១១២.៦៤០ | ៦៨ | ១៦ | ៣ |
| ឧស្សាហកម្ម | ៧៤៤.៤៦៤ | ១៤ | ៩០៧.២០០ | ១៥ | ២២ | ៤ |
| សេវាកម្ម | ១.១៧១.៤៣៦ | ២១ | ១.០២៨.១៦០ | ១៧ | -១២ | -២ |
| **សរុប** | **៥.៤៧៤.០០០** | **១០០** | **៦.០៤៨.០០០** | **១០០** | **១០** | **២** |

*ប្រភព៖ អង្គការពលកម្មអន្តរជាតិ(ILO)*

[33] អង្គការពលកម្មអន្តរជាតិ, *Rural development and employment opportunities in Cambodia* [ការអភិវឌ្ឍជនបទ និងឱកាសការងារនៅប្រទេសកម្ពុជា] (អង្គការពលកម្មអន្តរជាតិ, ២០១៣), ១៣, http://ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_228280.pdf ថតចម្លងថ្ងៃទី ២៥ ឧសភា ២០២០។

នាពេលបច្ចុប្បន្ន តំបន់ជនបទកម្ពុជានៅតែមានប្រជាជនរស់នៅច្រើនលើសលុប ដែលមានចំនួនប្រមាណជាង ៨០% នៃប្រជាជនសរុប។ ការងារដែលប្រជាជនជនបទធ្វើ ភាគច្រើនជាការងារនៅក្នុងវិស័យកសិកម្ម និងមួយផ្នែកតូចស្ថិតនៅក្នុងវិស័យឧស្សាហកម្មកម្មន្តសាលសិប្បកម្ម និងសេវាកម្ម។ ជាក់ស្តែង អត្រាភាពមានការងារធ្វើនៅតំបន់ជនបទនៅក្នុងឆ្នាំ២០១៣ មានប្រមាណ ៨៥,២% តួលេខនេះបានធ្លាក់ចុះបន្តិចមកត្រឹម ៨៣,៩% ក្នុងឆ្នាំ២០១៤ ប៉ុន្តែអត្រាភាពមានការងារធ្វើនៅតំបន់ជនបទមានការប្រែប្រួលវិជ្ជមានគួរឲ្យកត់សម្គាល់ឡើងវិញ ពោលគឺ អត្រាភាពមានការងារធ្វើនៅតំបន់ជនបទបានកើនឡើងមក ៨៤,២% ក្នុងឆ្នាំ២០១៥ និង ៨៥,៤% ក្នុងឆ្នាំ២០១៦ ហើយបន្តការកើនឡើងរហូតដល់ ៨៦,៦% ក្នុងឆ្នាំ២០១៧ (ក្រាហ្វិកទី២.៤)។ កំណើននៃអត្រាភាពមានការងារធ្វើរបស់ប្រជាជនតំបន់ជនបទនេះ បានបង្ហាញពីការខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងស្ថាប័នពាក់ព័ន្ធនានារួមជាមួយអង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍជនបទ។

ក្រាហ្វិកទី២.៤៖ អត្រាមានការងារធ្វើនៅតំបន់ជនបទឆ្នាំ២០១៣-២០១៧




*ប្រភព៖ ដកស្រង់ពី CSES ឆ្នាំ២០១៣ ដល់២០១៧*

វិស័យកសិកម្មនៅឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ មានការប្រែប្រួលក្នុងការផ្តល់ការងារទៅឲ្យប្រជាកសិករ ឬប្រជាជននៅជនបទ។ ជាក់ស្តែងយើងឃើញថាក្នុងឆ្នាំ២០១៣ កម្លាំងពលកម្មចូលក្នុងវិស័យកសិកម្មក្នុងអត្រា ៦០,៥% ក្នុងនេះដែរវាក៏មានការធ្លាក់ចុះវិញនៅឆ្នាំបន្ទាប់មកត្រឹមអត្រា ៥៦,៩% ក្នុងឆ្នាំ២០១៤ និងអត្រា ៥៣,០% ក្នុងឆ្នាំ២០១៥។ ប៉ុន្តែកម្លាំងពលកម្មចូលក្នុងវិស័យកសិកម្មដដែលនៅក្នុងឆ្នាំ២០១៦ មានការកើនឡើងវិញក្នុងអត្រា ៦៤,៤% ហើយបន្តចុះវិញ

នៅឆ្នាំ២០១៧ ក្នុងអត្រា ៤៦,៥%។ ការប្រែប្រួលនេះមិនមែនមានតែនៅក្នុងវិស័យកសិកម្មនោះទេ តែវាប្រែប្រួលឡើងចុះគ្រប់វិស័យ។

ចំណែកឯវិស័យឧស្សាហកម្មនៅជនបទក្នុងឆ្នាំ២០១៣-២០១៧ ក៏មានការប្រែប្រួលមិនខុសពីវិស័យកសិកម្មដែរ នៅឆ្នាំ២០១៣ កម្លាំងពលកម្មនៅជនបទបានចូលក្នុងវិស័យឧស្សាហកម្មក្នុងអត្រា ១៩,២% ហើយវាបន្តកើនឡើងនៅឆ្នាំ២០១៤ ក្នុងអត្រា ២៣,៥% និងឆ្នាំ២០១៥ ក្នុងអត្រា ២៥,២%។ ទោះជាយ៉ាងណាក៏វាមានការធ្លាក់ចុះវិញក្នុងឆ្នាំ២០១៦ ក្នុងអត្រា ១៩,២% ប៉ុន្តែក្នុងឆ្នាំ២០១៧ យើងឃើញកម្លាំងពលកម្មចូលក្នុងវិស័យឧស្សាហកម្មមានការកើនឡើងវិញក្នុងអត្រា ២៧,២%។

ជាចុងក្រោយយើងធ្វើការសង្កេតមើលទៅលើវិស័យសេវាកម្មនៅជនបទ ក្នុងឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០១៧ដដែល។ ជាក់ស្តែងវិស័យសេវាកម្មបានផ្តល់ការងារសម្រាប់ប្រជាជននៅតំបន់ជនបទក្នុងឆ្នាំ២០១៣ ក្នុងអត្រា ២០,៤% ប៉ុន្តែនៅឆ្នាំ២០១៤ មានការធ្លាក់ចុះមកត្រឹមអត្រា ១៩,៦% វិញបើធៀបជាមួយឆ្នាំ២០១៣។ ផ្ទុយទៅវិញក្នុងឆ្នាំ២០១៥ ការងារក្នុងវិស័យសេវាកម្មគឺមានការកើនឡើងវិញជាមួយអត្រា ២១,៧% ហើយក៏បន្តធ្លាក់ក្នុងឆ្នាំ២០១៦ ក្នុងអត្រា ១៩,២%។ តែទោះជាយ៉ាងណាក៏ដោយគឺមានការកើនឡើងវិញក្នុងឆ្នាំ២០១៧ ជាមួយក្នុងអត្រា ២៦,៣% (ក្រាហ្វិកទី២.៥)។

ក្រាហ្វិកទី២.៥៖ ការបែងចែកការងារតាមវិស័យសេដ្ឋកិច្ចនៅជនបទឆ្នាំ២០១៣-២០១៧




*ប្រភព៖ ដកស្រង់ពី CSES ឆ្នាំ២០១៣ ដល់២០១៧*

ដូច្នេះយើងឃើញថា ការបែងចែកការងារតាមវិស័យសេដ្ឋកិច្ចនៅជនបទក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ រួមមានវិស័យទាំងបីដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម មានការប្រែប្រួលទៅតាមឆ្នាំ។ ក្នុងឆ្នាំ២០១៧ ដោយកម្លាំងពលកម្មចូលក្នុងវិស័យកសិកម្មនៅជនបទមានការធ្លាក់ចុះបើប្រៀបធៀបជាមួយនឹងវិស័យឧស្សាហកម្ម និងសេវាកម្ម។ ជាក់ស្តែងមូលហេតុ ដែលមានការធ្លាក់ចុះបណ្តាលមកពីកម្លាំងពលកម្មនៅជនបទរត់ចេញពីវិស័យកសិកម្មចូលទៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មវិញ។

### ២.៥.២. អត្រានិកម្មភាព

អត្រានិកម្មភាពត្រូវបានបង្ហាញតាមឆ្នាំដែលបានកំណត់។ ក្នុងនេះដែរអត្រានិកម្មភាពនៅតំបន់ជនបទក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ យើងឃើញថាក្នុងឆ្នាំ២០១៣ គឺមាននិកម្មភាពនៅជនបទក្នុងអត្រា ០,៣% នេះបើយោងតាមការសង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ(NIS) នៅកម្ពុជា។ ប៉ុន្តែអត្រានិកម្មភាពនៅជនបទបានធ្លាក់ចុះមកត្រឹម ០,១% ប៉ុណ្ណោះក្នុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ (ក្រាហ្វិកទី២.៦)។

ក្រាហ្វិកទី២.៦៖ អត្រានិកម្មភាពនៅជនបទឆ្នាំ២០១៣-២០១៧




*ប្រភព៖ ដកស្រង់ពី CSES ឆ្នាំ២០១៣ ដល់២០១៧*

### ២.៥.៣. មូលហេតុនិកម្មភាព

យោងតាមនិយមន័យរបស់ ILO ឬតាមនិយមន័យរបស់រដ្ឋាភិបាលនៃប្រទេសនីមួយៗក៏ដូចជាកម្ពុជា អត្រានិកម្មភាព(Unemployment rate) សំដៅដល់ភាគរយនៃកម្លាំងពលកម្មសរុបដែលគ្មានការងារធ្វើ ប៉ុន្តែស្ថិតក្នុងស្ថានភាពរួចរាល់សម្រាប់ការងារ ឬក៏កំពុងរង់ចាំស្វែងរកការងារធ្វើតែម្តង។ គេវាស់កម្លាំងពលកម្មសរុបដោយបូកបញ្ចូល មនុស្សដែលមានអាយុចាប់ពី១៥ឆ្នាំ

ឡើងទៅ និងអាចផ្គត់ផ្គង់កម្លាំងពលកម្មបាននៅលើទីផ្សារការងារមិនថាការងារពេញម៉ោង ឬមិនពេញម៉ោង និងបូកបញ្ចូលមនុស្សដែលអត់ការងារធ្វើ ប៉ុន្តែកំពុងស្វែងរក។ ក្នុងន័យនេះ មិនមែនគ្រប់មនុស្សដែលធ្វើការសុទ្ធតែរាប់បញ្ចូលក្នុងកម្លាំងពលកម្មសរុបនោះទេ។ ឧទាហរណ៍ បុគ្គលិកមិនទទួលបានប្រាក់ឈ្នួល សមាជិកធ្វើការងារក្នុងគ្រួសារ និងសិស្សានុសិស្សមិនត្រូវបានគេរាប់បញ្ចូល។[34] ជាក់ស្តែងមូលហេតុដែលបណ្តាលឲ្យមាននិកម្មភាពនៅតំបន់ជនបទនៅកម្ពុជាមានដូចខាងក្រោម៖

–កំណើនប្រជាជន៖ បន្ទាប់ពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាម និងទទួលបានសន្តិភាពមកចំនួនប្រជាជនមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំជាពិសេសនៅជនបទ។ បច្ចុប្បន្នមានប្រជាជនប្រមាណ ៧៦,៦១% ដែលកំពុងរស់នៅជនបទ(២០១៨) នេះបើយោងតាមធនាគារពិភពលោក។ ស្របពេលកំណើនប្រជាជននៅជនបទកាន់តែខ្ពស់ប៉ុន្តែទីផ្សារការងារមានភាពខ្វះខាត ឬគ្មានការងារគ្រប់គ្រាន់ ជាមូលហេតុដែលនាំឲ្យប្រជាជនគ្មានការងារធ្វើ។ នេះក៏ជាមូលហេតុបង្ខំចិត្តឲ្យពួកគាត់ធ្វើចំណាកស្រុកទៅរកការងារធ្វើជាដើម។[35]

–ប្រជាជនខ្វះចំណេះដឹងឬជំនាញ៖ ទោះបីជាវិស័យអប់រំមានការអភិវឌ្ឍពិតមែនក៏នៅតាមជនបទនៅមានភាពខ្វះខាតចំណេះដឹងនៅឡើយ។ ជាការពិតណាស់ វិស័យអប់រំមានសារៈសំខាន់ណាស់ចំពោះប្រជាជន ជាពិសេសតំបន់ជនបទ ព្រោះថាបើកាលណាកម្រិតនៃការយល់ដឹងគាត់តែខ្លាំង ឱកាសនៃការមានការងារធ្វើកាន់តែច្រើន។

–ប្រជាជនពឹងផ្អែកលើកសិកម្ម៖ កម្ពុជាមានប្រជាជនប្រមាណ ៨៥% ពឹងផ្អែកលើវិស័យកសិកម្មនិងភាគច្រើនប្រកបរបរធ្វើស្រែចម្ការ។ ត្រង់នេះចង់បង្ហាញថា កម្លាំងពលកម្មភាគច្រើនពឹងផ្អែកលើវិស័យកសិកម្ម ដែលជាប្រភេទការងារនេះមានភាពផុយស្រួយខ្លាំង មានពេលខ្លះមិនទៀងទាត់ និងអាស្រ័យខ្លាំងទៅដូចកាលអំណោយផលឬអត់។ ជាក់ស្តែងប្រជាកសិករនៅតំបន់ជនបទធ្វើកសិកម្មបែបប្រពៃណីមិនមានការអភិវឌ្ឍគួរឲ្យកត់សម្គាល់។ មួយវិញទៀតនៅរដូវសម្រាកពីការប្រមូលផល ប្រជាកសិករមួយចំនួនគ្មានរបរ ឬអាជីពអ្វីនោះទេ។

–ការវិនិយោគបរទេសនៅមានកម្រិត៖ ការវិនិយោគពីបរទេសនាំមកនូវប្រយោជន៍ជាច្រើនសម្រាប់ប្រជាជននៅជនបទ ប៉ុន្តែការបណ្តាក់ទុនបរទេសមិនទាន់ដល់ចំណុចមួយគ្រប់គ្រាន់ដល់ការផ្តល់ជាការងារសម្រាប់ប្រជាជននៅជនបទនោះទេ។ ក្នុងនេះចង់បង្ហាញថា បើកាលណាមាន

[34] ដកស្រង់គេហទំព័រ http://www.rfi.fr/km ចូលទស្សនាថ្ងៃទី ២៨ ឧសភា ២០២០។

[35] ដកស្រង់គេហទំព័រ http://derlinsela.blogspot.com/p/blog-page_21.html ចូលទស្សនាថ្ងៃទី ២៨ ឧសភា ២០២០។

ការបណ្តាក់ទុនកាន់តែច្រើនជាហេតុធ្វើឲ្យមានការងារ កាត់បន្ថយនិកម្មភាព កាត់បន្ថយភាពក្រីក្រ ឬចំណាកស្រុកជាដើម។ ដូច្នេះ ការវិនិយោគមានសារៈសំខាន់ណាស់សម្រាប់ប្រជាជននៅជនបទ បើគ្មានការវិនិយោគនោះទេ គឺនិកម្មភាពនៅជនបទនៅតែបន្តចោទជាបញ្ហានៅឡើយ។

## ២.៦. តួនាទីរបស់ស្ថាប័ននានាក្នុងការអភិវឌ្ឍជនបទ

### ២.៦.១. តួនាទីរបស់ស្ថាប័នសាធារណៈ

ស្ថាប័នសាធារណៈ ជាស្ថាប័នដែលមានសក្តានុពលក្នុងការអភិវឌ្ឍតំបន់ដាច់ស្រយាល និងតំបន់ជនបទឲ្យមានការប្រែប្រួលជាវិជ្ជមានជាលំដាប់។ ក្នុងការអភិវឌ្ឍជនបទ ឬការបង្កើតការងារជូនប្រជាជនជនបទ ស្ថាប័នសាធារណៈពាក់ព័ន្ធមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយគ្នា។ ស្ថាប័នពាក់ព័ន្ធ និងការទទួលខុសត្រូវរួមមាន៖

- ក្រសួងអភិវឌ្ឍន៍ជនបទ មានទំនួលខុសត្រូវលើការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងលើកកម្ពស់អនាម័យជនបទ។
- ក្រសួងធនធានទឹក និងឧតុនិយម មានតួនាទីគ្រប់គ្រងធនធានទឹក ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ប្រព័ន្ធស្រោចស្រព ព្រមទាំងព្យាករណ៍ និងផ្តល់ព័ត៌មានអំពីបម្រែបម្រួលអាកាសធាតុជូនកសិករឲ្យបានទាន់ពេលវេលា។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) មានតួនាទីសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ អប់រំ ផ្តល់និងកែលម្អបច្ចេកទេសកសិកម្ម ព្រមទាំងស្វែករកទីផ្សារជូនកសិករ។
- ក្រសួងរ៉ែ និងថាមពល មានតួនាទីបន្តការអភិវឌ្ឍសមត្ថភាពផលិត បញ្ជូន ចែកចាយ និងការតភ្ជាប់បណ្តាញអគ្គិសនីដល់តំបន់ជនបទ ដែលជាប្រយោជន៍សម្រាប់ប្រជាជនជនបទ ព្រមទាំងឧស្សាហកម្ម សិប្បកម្ម រោងចក្រសហគ្រាស និងអាជីវកម្មផ្សេងៗ។
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានតួនាទីលើកទឹកចិត្តដល់ការវិនិយោគ ការបង្កើតកម្រងឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស ការបង្កើតរោងចក្រសហគ្រាសកម្មន្តសាលធុនតូច មធ្យម និងសិប្បកម្មនៅគ្រប់ទីកន្លែងក្នុងប្រទេស ជាពិសេសតំបន់ជនបទ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីអភិវឌ្ឍន៍ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ប្រជាជនទាំងអស់ ព្រមទាំងធ្វើឲ្យប្រសើរឡើងផ្នែកលក្ខខណ្ឌការងារ។

### ២.៦.២. តួនាទីអង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាល(NGOs) ជាអង្គការមិនស្វែងរកប្រាក់ចំណេញ ដែលមានឯករាជ្យភាព មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ អង្គការក្រៅរដ្ឋាភិបាលបាននឹងកំពុងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ជាពិសេសក្នុងសកម្មភាពអភិវឌ្ឍន៍ជនបទ។ ប្រជាជនជនបទដែលក្រីក្រកំពុងពឹងផ្អែកលើប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការទទួលបានការងារធ្វើ និងបង្កើនប្រាក់ចំណូល។ អង្គការក្រៅរដ្ឋាភិបាលមានតួនាទីដូចជា៖

- បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្សេងៗដល់កសិករ កម្មករ ដើម្បីមានឱកាសទទួលបានការងារធ្វើ និងទទួលបានប្រាក់ចំណូលសមរម្យ។
- ផ្តល់ជាជំនួយផ្នែកហិរញ្ញវត្ថុ សម្រាប់កសិករ អាជីវករ ក្នុងការបង្កើតជាកសិដ្ឋាន អាជីវកម្មដែលមានលក្ខណៈគ្រួសារ។
- សហការជាមួយស្ថាប័នសាធារណៈ ក្នុងការស្វែងរកទីផ្សារផលិតផលសម្រាប់កសិករដោះដូរផលិតផលកសិកម្មជាដើម។

## ២.៧. គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់បង្កើតការងារនៅជនបទ

### ២.៧.១. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់នីតិកាលទី៥ (២០១៨-២០២៣) បានកំណត់ចេញនូវផែនទីបង្ហាញផ្លូវដ៏មានមហិច្ឆតាមួយ ដើម្បីសម្រេចនូវទស្សនៈវិស័យ ជាស្ថានភាពមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងស្ថានភាពប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ដែលមានចតុកោណ៤គឺ (១)-ការអភិវឌ្ឍធនធានមនុស្ស (២)-ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣)-ការអភិវឌ្ឍវិស័យឯកជន និងការងារ និង(៤)-ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន(ឧបសម្ព័ន្ធ១)។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកគោលដៅយុទ្ធសាស្ត្រ៤គឺ (១)-ធានាឲ្យបានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ (២)-បង្កើតការងារឲ្យបានកាន់តែច្រើនទាំងបរិមាណ និងគុណភាពជូនប្រជាពលរដ្ឋកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន (៣)-សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឲ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% និង(៤)-បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

បន្ថែមលើនេះរាជរដ្ឋាភិបាលក៏បានកំណត់យកវិស័យអាទិភាព៤ រួមមាន ផ្លូវ ទឹក ភ្លើង និងមនុស្ស ដើម្បីជំរុញការអភិវឌ្ឍប្រទេសដែលលំដាប់នៃសារៈសំខាន់របស់អាទិភាពទាំងនេះត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ។ ក្នុងគោលដៅនេះ យុទ្ធសាស្ត្រចតុកោណត្រូវបានរៀបចំកែសម្រួលឡើងវិញឲ្យឆ្លុះបញ្ចាំងវិស័យអាទិភាព៤ និងកិច្ចការមួយចំនួនទៀតដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជាក៏ដូចជាការអភិវឌ្ឍជនបទ។

### ២.៧.២. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

គោលនយោបាយជាស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ គឺជាផែនទីចង្អុលផ្លូវរបស់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ស្ថាប័នទីផ្សារការងារ និងធានាឲ្យមានឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។ គោលនយោបាយនេះ ជាវិធានការសមស្រប និងទាន់ពេលវេលាដើម្បីសម្រេចបាននូវប្រយោជន៍ ដែលកើតចេញពីស្ថានភាពប្រជាសាស្ត្ររបស់កម្ពុជានាពេលបច្ចុប្បន្ន ពោលគឺមានប្រជាពលរដ្ឋជាច្រើនដែលមានវ័យក្មេង និងជវភាព (ភាពស្វាហាប់) នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដែលមានពិពិធកម្មខ្ពស់ ហើយម្យ៉ាងទៀតដើម្បីផ្តល់បទពិសោធន៍ការងារដ៏មានគុណភាព និងការរៀបចំកន្លែងធ្វើការងារដ៏សមរម្យសម្រាប់យុវជន កម្ពុជាដែលអាចក្លាយទៅជាកម្លាំងពលកម្មដ៏មានសមត្ថភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ គោលនយោបាយនេះ បានស្នើឡើងនូវវិធានការដែលគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលគោលបំណងចម្បងចំនួន៣គឺ៖

គោលបំណងទី១៖ ការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់

គោលបំណងទី២៖ ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស

គោលបំណងទី៣៖ ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។

ដើម្បីសម្រេចបានគោលបំណងទី១ ការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

- លើកស្ទួយការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់នៅក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។
- លើកស្ទួយការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ។
- លើកកម្ពស់ការងារសមរម្យ និងមានផលិតភាពការងារខ្ពស់តាមរយៈការបង្កលក្ខណៈឲ្យមានការប្រែក្លាយកម្មករនិយោជិត និងអង្គភាពសេដ្ឋកិច្ចពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុង

សេដ្ឋកិច្ចផ្លូវការ ដោយធានាបាននូវការកែលម្អ និងរក្សាបាននូវជីវភាពរស់នៅ ក្នុងអំឡុងពេលនៃដំណើរការប្រែក្លាយនេះ។

ដើម្បីសម្រេចបានគោលបំណងទី២ ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស គោលនយោបាយនេះ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

- ពង្រឹង និងពង្រីកការអភិវឌ្ឍជំនាញទន់។
- ពង្រឹងគុណភាពឲ្យស្របតាមស្តង់ដាជាតិ អន្តរជាតិ និងក្របខណ្ឌអាស៊ាន និងលទ្ធភាពទទួលបានការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ធ្វើឲ្យប្រសើរឡើងនូវភាពឆ្លើយតបនៃការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យស្របតាមតម្រូវការទីផ្សារ។

ដើម្បីសម្រេចបានគោលបំណងទី៣ ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

- ពង្រឹងមូលដ្ឋានទិន្នន័យ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ។
- ពង្រឹងប្រសិទ្ធភាពសេវាការងារ និងពង្រីកវិសាលភាព។
- ធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងការពារកម្មករនិយោជិត។
- ធ្វើសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងយន្តការកំណត់ប្រាក់ឈ្នួល។
- សិក្សាឈានទៅបង្កើតសេវារបបនិកម្មភាព។
- គ្រប់គ្រង និងការពារពលករទេសន្តរប្រវេសន៍ក្នុងការទទួលបានការងារសមរម្យ និងការទទួលស្គាល់ជំនាញ។[36]

### ២.៧.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសឲ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជាផ្លូវការនៅឆ្នាំ២០១៥កន្លងទៅ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន បង្កើតការងារ ការបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច និងការបង្កើនប្រាក់ចំណូលសមរម្យ ដែលផ្តោតទៅលើការអភិវឌ្ឍក្នុងវិស័យកម្មន្តសាល កសិឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម។

[36] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា,២០១៥), ៥-៦។

នៅក្នុងគោលនយោបាយនេះ រាជរដ្ឋាភិបាលបានផ្តោតសំខាន់លើការរៀបចំ និងអនុវត្តនូវក្របខណ្ឌគោលនយោបាយមួយច្បាស់លាស់ ដែលមានការសម្របសម្រួលប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមក ដោយចាប់ផ្តើមពីការកែទម្រង់និងការកែសម្រួលយន្តការស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ ក្របខណ្ឌគោលនយោបាយនេះរួមមាន៖

ទី១-ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងការកៀរគរវិនិយោគឯកជនក្នុងស្រុកសម្រាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ការអភិវឌ្ឍនិងពង្រីកទីផ្សារនាំចេញនិងការជំរុញការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា។

ទី២-ការអភិវឌ្ឍ និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ដើម្បីពង្រីកនិងពង្រឹងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល ការធ្វើទំនើបកម្មនិងចុះបញ្ជីសហគ្រាសជាផ្លូវការ ការជំរុញការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា និងការពង្រឹងការតភ្ជាប់ឧស្សាហកម្មរវាងសហគ្រាសក្នុងស្រុក ជាមួយសហគ្រាសបរទេស ពិសេសនៅក្នុងវិស័យកសិឧស្សាហកម្ម។

ទី៣-ការកែលម្អបរិស្ថាននិយតកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង តាមរយៈការលើកកម្ពស់បរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ការផ្តល់ព័ត៌មានអំពីទីផ្សារ និងការកាត់បន្ថយចំណាយចម្លងការអាជីវកម្ម។

ទី៤-ការសម្របសម្រួលគោលនយោបាយគាំទ្រ រួមមានការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការកែលម្អទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការរៀបចំដែនដីនគរូបនីយកម្មនិងផែនការប្រើប្រាស់ដីស្របតាម គោលនយោបាយដីធ្លី និង គោលនយោបាយជាតិស្តីពីការរៀបចំដែនដី ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរួមមាន ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនឡូជីស្ទីក និងការតភ្ជាប់ឌីជីថល ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត ព្រមទាំងសេវាគាំទ្រផ្សេងទៀតដូចជា សេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។

យុទ្ធសាស្ត្រខាងលើ មានមុខព្រួញសំខាន់ពីរដែលបំពេញគ្នាទៅវិញទៅមកក្នុងនោះ ទីមួយ គឺមានគោលបំណងកៀរគរទុនវិនិយោគដើម្បីបង្កើតឧស្សាហកម្មថ្មីៗ ទ្រង់ទ្រាយធំ ដែលមានចរិតជាឧស្សាកម្មនាំមុខ និងបម្រើឲ្យគោលដៅជៀសចូលទីផ្សារតំបន់ និងអន្តរជាតិ ក៏ដូចជាការតភ្ជាប់ជាមួយខ្សែចង្វាក់តម្លៃសាកល។ ទីពីរ គឺសំដៅពង្រឹងនិងកសាងមូលដ្ឋានឧស្សាហកម្មក្នុងស្រុកមានស្រាប់ដោយផ្តោតលើសហគ្រាសធុនតូចនិងមធ្យម ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម

គាំទ្រ និងចង្កោមឧស្សាហកម្មក្នុងខ្សែចង្វាក់ផលិតកម្មនិងខ្សែចង្វាក់តម្លៃសំខាន់ៗ ដែលអាចផ្សារភ្ជាប់ និងចូលរួមសកម្មភាពផលិតកម្មជាមួយនឹងឧស្សាហកម្មប្រភេទនីមួយៗ។[37]

ដូច្នេះក្រសួងបានបង្ហាញថា វានឹងធ្វើឲ្យជះឥទ្ធិពលទៅដល់ហេដ្ឋារចនាសម្ព័ន្ធបន្ថែមក្នុងប្រទេសក៏ដូចជាតំបន់ជនបទ ក្នុងន័យនេះឆ្លុះបញ្ចាំងឲ្យឃើញនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែមមានដូចជា ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ ប្រព័ន្ធបញ្ចេញកាកសំណល់និងទឹកសម្អុយ សេវាសុខាភិបាល និងសេវាអប់រំជាដើម ដើម្បីធានាបាននូវចង្វាក់ផ្គត់ផ្គង់ដែលអាចទុកចិត្តបាន និងទាន់ពេលវេលា។

### ២.៧.៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ជាផែនទីបង្ហាញផ្លូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងការអភិវឌ្ឍជនបទក្នុងរយៈពេល ៥ឆ្នាំបន្តទៀត។ ក្រសួងអភិវឌ្ឍន៍ជនបទដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានអនុវត្តប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៤-២០១៨ ដោយបាននាំមកនូវភាពប្រែប្រួលជាវិជ្ជមានអំពីស្ថានភាពជីវភាពរស់នៅ សុខភាព អនាម័យ និងសេវាសាធារណៈផ្សេងៗដោយសុខដុមរមនាក្នុងសង្គមគ្រួសារនៅតំបន់ជនបទ។ ទោះបីជាក្រសួងសម្រេចបានជោគជ័យជាច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៤-២០១៨ ក៏ដោយក៏នៅមានបញ្ហាមួយចំនួនពុំទាន់ដោះស្រាយអស់នៅឡើយដូចជា ការកើនឡើងយ៉ាងគំហុកនូវតម្រូវការប្រើប្រាស់ផ្លូវជនបទ ការដឹកជញ្ជូនលើសទម្ងន់ដែលច្បាប់កំណត់ ការអភិវឌ្ឍនៅទីដាច់ស្រយាល ការកើនឡើងនៃការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ ចំណេះជំនាញមូលដ្ឋាននៅពុំទាន់គ្រប់គ្រាន់ ការយល់ដឹងពីបញ្ហារស់នៅស្អាត សុខភាពអនាម័យនៅខ្វះចន្លោះជាច្រើន ពិសេសនៅតំបន់ជនបទដាច់ស្រយាល។ កត្តាប្រែប្រួលអាកាសធាតុនៅតែជាបញ្ហាប្រឈមមួយផងដែរ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត។ ប្រភពហិរញ្ញប្បទានសម្រាប់យកទៅអភិវឌ្ឍន៍នៅមានកម្រិតនៅឡើយ ហើយការចូលរួមរបស់ស្ត្រីក្នុងការងារអភិវឌ្ឍន៍ក៏ទាមទារឲ្យមានការជំរុញ និងយកចិត្តទុកដាក់បន្ថែមទៀត។

ដើម្បីដោះស្រាយបញ្ហាប្រឈមនានាខាងលើប្រកបដោយប្រសិទ្ធភាព ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសម្រាប់រយៈពេល ៥ឆ្នាំបន្តទៀត

[37] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០១៥), ១៨-១៩។

២០១៩-២០២៣ ដើម្បីបន្តការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទមានជាអាទ៍៖

ទី១-ការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សគឺជា មូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និង កំណែទម្រង់ដទៃទៀតឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ទី២-បង្កើតការស្ថាបនា កសាង និងជួសជុល លើកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈបន្ថែមទៀតដល់គ្រប់ច្រកល្ហកនៃតំបន់ជនបទ ជាពិសេសនៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់។

ទី៣-ការលើកកម្ពស់សុខភាព ការអប់រំ និងលក្ខខណ្ឌនៃការរស់នៅស្អាត ហូបស្អាត ភូមិឃុំមានបរិស្ថានរស់នៅស្អាត ភូមិឃុំមានសុវត្ថិភាព គឺជាផ្នែកមួយជួយជំរុញឲ្យមានលក្ខខណ្ឌនៃរបៀបរស់នៅបែបទំនើបនៅតំបន់ជនបទ។

ទី៤-ការបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ច ក្នុងការចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ បង្កើតប្រាក់ចំណូលគ្រួសារដែលជាកត្តាសំខាន់បំផុតពុំអាចខ្វះបាននៅតាមជនបទ។[38]

ក្នុងបរិបទបង្កើតការងារ ផែនការយុទ្ធសាស្ត្រនេះក៏បានជំរុញការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាជន ជំរុញការបង្កើតទីផ្សារសហគមន៍ សាងសង់ផ្សារជនបទ ដែលជាកន្លែងដោះដូរផលិតផល និងកសិផល។ ម៉្យាងទៀត ការជំរុញការផ្តល់សេវាប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យ សម្រាប់ការអភិវឌ្ឍសិប្បកម្ម មុខជំនួញ សហគ្រាសធុនតូច និងមធ្យម និងការជំរុញការបង្កើតធនាគារមិនមែនសាច់ប្រាក់ដូចជា ធនាគារស្រូវ ធនាគារមាន់ ធនាគារជី ជាការចូលរួមក្នុងការបង្កើតការងារដល់ប្រជាជនជនបទ។

### ២.៧.៥. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដែលចាត់ទុកជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍ

[38] ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣* (ភ្នំពេញ៖ ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៩), ១-២។

សេដ្ឋកិច្ចជនបទ។ MAFF បានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងកសិ-ពាណិជ្ជកម្មដោយបានជំរុញការអនុវត្តនូវវិធានការចាំបាច់មួយចំនួនរួមមាន ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើតការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើតទិន្នផលដំណាំ និងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង និងបង្កើនជីវជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការគ្រប់គ្រង និងអភិវឌ្ឍន៍ដំណាំកៅស៊ូ ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព ការប្រកួតប្រជែងខ្ពស់បរិយាបន្ន និងនិរន្តរភាព។

ទន្ទឹមនឹងនេះ MAFF ក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងលើការប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ក្នុងនេះដែរ MAFF បានដាក់ចេញគោលនយោបាយតាមវិធីសាស្ត្រចំនួន៥៖

កម្មវិធីទី១៖ បង្កើតផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

កម្មវិធីទី២៖ ជំរុញផលិតកម្មសត្វ និងសុខភាព

កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

កម្មវិធីទី៤៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព

កម្មវិធីទី៥៖ ពង្រឹងស្ថាប័ន បង្កើតប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស។[39]

ជាការពិតណាស់ គោលនយោបាយខាងលើនឹងជួយលើកកម្ពស់ផលិតភាពកសិកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីបង្កើនការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ធ្វើឲ្យប្រសើរឡើងនូវអាហារូបត្ថម្ភ បង្កើនការនាំចេញផលិតផលកសិកម្ម ជំរុញការអភិវឌ្ឍជនបទ កំណើនសេដ្ឋកិច្ចសំដៅលើកកម្ពស់ជីវភាពរបស់កសិកររស់នៅតំបន់ជនបទ និងកាត់បន្ថយភាពក្រីក្រជាចម្បង។

[39] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៩), ៨០។

# ជំពូកទី៣

# ការបង្កើតការងារនៅ

# ជនបទកម្ពុជា

# ជំពូកទី៣

# ការបង្កើតការងារនៅជនបទកម្ពុជា

## ៣.១. ការបង្កើតការងារតាមវិស័យកសិកម្ម

វិស័យកសិកម្មនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដូចជាតាមរយៈការបង្កើតការងារដល់ប្រជាជនតាមទីជនបទ ក៏ដូចជាការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ការកើនឡើងនៃចំនួនកម្លាំងពលកម្មប្រមាណជាង ២៥០.០០០នាក់ ទៅ ៣០០.០០០នាក់ ក្នុងមួយឆ្នាំៗនៅក្នុងប្រទេសកម្ពុជា ទាំងនេះបានបង្ហាញថាតម្រូវការនៃការងារគឺមានការកើនឡើងជានិច្ច។ ជាការពិតណាស់ អាកាសធាតុនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈក្តៅនិងសើម ហើយប្រជាកសិករនៅតាមទីជនបទប្រកបការងារដោយពឹងផ្អែកលើការធ្វើកសិកម្ម។ ការដាំដុះដំណាំនៅតាមទីជនបទរបស់ប្រជាកសិករ គឺពឹងផ្អែកទៅលើធនធានធម្មជាតិ ហើយឆ្នាំខ្លះជួបប្រទះជាមួយនឹងការខ្វះខាតទឹកភ្លៀង ឬជួបប្រទះនឹងភាពរាំងស្ងួត ដែលជាហេតុផលធ្វើឲ្យប្រជាកសិករបាត់បង់ប្រាក់ចំណូល និងការងារធ្វើ។ ប៉ុន្តែបើទោះបីជាប្រជាកសិករ ឬប្រជាជននៅតាមជនបទមានការងារធ្វើក៏ដោយ ក៏ប្រភពចំណូលដែលបានមកពីការធ្វើកសិកម្មគឺមានចំណូលទាប។ ពលកម្មក្នុងវិស័យកសិកម្មបាននឹងកំពុងធ្លាក់ចុះគួរឲ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មនៅឆ្នាំ២០១០ មានចំនួន ៥៤,២% នៃកម្លាំងពលកម្មសរុប ហើយបន្តថយចុះមកត្រឹមតែ ៤៨,៧% នៅឆ្នាំ២០១៤។ ឆ្នាំ២០១៧ កម្លាំងពលកម្មក្នុងវិស័យកសិកម្មមានចំនួនត្រឹមតែ ៣៧% ប៉ុណ្ណោះ ហើយចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។[40] ដូចនេះតម្រូវឲ្យយើងបង្កើតការងារជាច្រើនសម្រាប់ប្រជាកសិករនៅទីជនបទឲ្យបានពីរ ឬច្រើនតាមដែលអាចធ្វើទៅបានតាមរយៈការធ្វើពិពិធកម្មដំណាំកសិកម្ម ការចិញ្ចឹមសត្វ និងវារីវប្បកម្មជាដើម។

### ៣.១.១. ការបង្កើតការងារតាមរយៈការធ្វើពិពិធកម្មដំណាំកសិកម្ម

ការធ្វើពិពិធកម្មដំណាំកសិកម្ម សំដៅដល់ការអនុវត្តកសិកម្មដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុព្រមទាំងធានាសន្តិសុខស្បៀងតាមរយៈការដាំដំណាំជាច្រើនប្រភេទផ្សេងៗ ដែលអាចសម្របខ្លួនទៅនឹងអាកាសធាតុ និងដី។ ពិពិធកម្មដំណាំកសិកម្មត្រូវបានបង្កើតឡើងជាយុទ្ធសាស្ត្រសំខាន់ ដើម្បីធានាស្ថិរភាពប្រាក់ចំណូល និងបង្កើតឱកាសការងារសម្រាប់ប្រជាជន

[40] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០១៩), ៤៦។

នៅជនបទ។[41] ដំណាំនោះរួមមាន ដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំកសិឧស្សាហកម្ម។ នៅពេលកសិករដាំដំណាំតែមួយមុខ ពួកគេងាយស្រួលប្រឈមនឹងហានិភ័យខ្ពស់ក្នុងករណីស្ថានភាពអាកាសធាតុ ដែលមិនបានព្រៀងទុកអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរលើផលិតកម្មកសិកម្ម ដូចជា ការលេចឡើងនៃសត្វល្អិតចង្រៃ ឬភាពរាំងស្ងួត។ល។ គោលបំណងនៃការធ្វើពិពិធកម្មដំណាំ គឺដើម្បីបង្កើនការទទួលខុសត្រូវលើការដាំដុះ ដែលកសិករមិនចាំបាច់ផ្អែកលើដំណាំតែមួយមុខ ក្នុងការបង្កើតប្រាក់ចំណូល។

#### ៣.១.១.១. ដំណាំស្រូវ

ដំណាំស្រូវ ជាដំណាំលេចធ្លោជាងគេនៅក្នុងកសិកម្មកម្ពុជា។ ប្រជាជនក្រីក្រជាង ៩០% ហើយ ៨០% នៃអ្នកក្រីក្រនៅជនបទពឹងផ្អែកលើដំណាំស្រូវ។ ដំណាំស្រូវត្រូវបានដាំដុះលើផ្ទៃដីដាំដំណាំជាង ៩០% ថ្វីត្បិតតែប្រទេសកម្ពុជាមានអាកាសធាតុសមស្របសម្រាប់ដំណាំផ្សេងៗទៀតជាច្រើនមុខក៏ដោយដូចជា ពោត សណ្តែកសៀង ដំឡូងមី និងពួកសណ្តែកផ្សេងៗ រួមទាំងបន្លែបង្ការ និងដើមឈើយកផ្លែជាដើម។ ស្រូវបាននឹងកំពុងដើរតួនាទីជាចម្បងក្នុងការបង្កើតការងារ បង្កើនប្រាក់ចំណូល កាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ជាពិសេសបានធានាសន្តិសុខស្បៀងសម្រាប់គ្រួសារ និងប្រទេសជាតិ។ យោងតាមរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០ របស់ MAFF បានបង្ហាញថា តម្លៃពលកម្មប្រចាំថ្ងៃជាមធ្យមបានកើនឡើងពី៣.៥០០រៀលក្នុងឆ្នាំ២០០៣ ទៅ ៧.៨០០រៀលក្នុងឆ្នាំ២០០៨ និង ១៧.២០០រៀលក្នុងឆ្នាំ២០១៥ រួចបន្តកើនឡើងជាលំដាប់រហូតដល់ ២២.២០០រៀលក្នុងឆ្នាំ២០១៨។[42] ផលិតកម្មដំណាំស្រូវក្នុងឆ្នាំ២០១៩ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសចំនួន ៣,៣២៨ លានហិកតា ក្នុងនោះស្រូវវស្សាមានចំនួន ២,៧៣១លានហិកតា និងរដូវប្រាំងមានចំនួន ០,៥៩៧ លានហិកតា ដែលមានការថយចុះបើប្រៀបធៀបជាមួយឆ្នាំ២០១៨។ ផ្ទៃដីប្រមូលផលសរុបចំនួន ៣,២៦៣លានហិកតា ក្នុងនោះស្រូវវស្សាមានចំនួន ២,៦៧១លានហិកតា និងស្រូវប្រាំងមានចំនួន ០,៥៩២លានហិកតា។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១០,៨៨៥លានតោន ដែលក្នុង

[41] ដកស្រង់គេហទំព័រ http://www.mekongcommons.org/cambodias-farmers-try-diversify-farming-systems-protect-food-security/ ចូលទស្សនាថ្ងៃទី ១១ មិថុនា ២០២០។

[42] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០២០), ២៧។

នោះស្រូវវស្សាទទួលបានទិន្នផល ៣,០៩៥តោន/ហិកតា និងទិន្នផលស្រូវប្រាំងទទួលបាន ៤,៩១៨តោន/ហិកតា។[43]

ក្រាហ្វិកទី៣.១៖ ផលិតកម្មដំណាំស្រូវឆ្នាំ២០១៥-២០១៩




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)*

### ៣.១.១.២. ដំណាំសាកវប្បកម្ម

ការដាំដុះដំណាំសាកវប្បកម្មមានសារៈសំខាន់ចំពោះមនុស្ស ការអភិវឌ្ឍសេដ្ឋកិច្ច និងបានចូលរួមធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រដោយបង្កើតការងារ និងប្រភពថ្មីនៃប្រាក់ចំណូលរបស់កសិករនៅជនបទដែលមានទំហំដីតូចតាច។ ផលិតកម្មសាកវប្បកម្មក៏បានចូលរួមគាំទ្រកសិពាណិជ្ជកម្មផងដែរដោយបង្កើតឱកាសសេដ្ឋកិច្ច និងឱកាសពាណិជ្ជកម្ម ជាពិសេសសម្រាប់ស្ត្រី។ ផលិតកម្មដំណាំសាកវប្បកម្មបានចូលរួមធ្វើពិពិធកម្មចំណូល និងបង្កើតប្រាក់ចំណូលសម្រាប់កសិករ ដែលជាធម្មតាមានកម្រិតច្រើនជាងផលិតកម្មផ្សេងទៀត។

នៅឆ្នាំ២០១៩ ផ្ទៃដីផលិតកម្មដំណាំសាកវប្បកម្ម ឬដំណាំរួមផ្សំ (ពោត ដំឡូងជ្វា បន្លែ ម្ទេស ឪឡឹក) សម្រេចបានចំនួន ៩៤.៥៤១ហិកតា លើសឆ្នាំ២០១៨ ចំនួន ៩.១៩៦ហិកតា ស្មើនឹង ១១% ក្នុងនោះផ្ទៃដីដាំដុះរដូវវស្សាមានចំនួន ៥៦.៩១៥ហិកតា និងផ្ទៃដីដាំដុះរដូវប្រាំងមានចំនួន ៣៧.៦២៦ហិកតា។ បរិមាណសរុបទទួលបានចំនួន ៨៧៩.៩១៥តោន លើសឆ្នាំ២០១៨ចំនួន

[43] ដូច៤២, ទំព័រ ១៨។

៨២.១៣៧តោន ដែលក្នុងនោះបរិមាណផលដំណាំសាកវប្បកម្មរដូវវស្សាមានចំនួន ៥១២.៧០១ តោន និងបរិមាណផលដំណាំសាកវប្បកម្មរដូវប្រាំងមានចំនួន ៣៦៧.១២០តោន(ឧបសម្ព័ន្ធ៤)។[44]

ក្រាហ្វិកទី៣.២៖ ផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៥-២០១៩




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)*

### ៣.១.១.៣. ដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្ម (ភាគច្រើនជាកៅស៊ូ) ជាដំណាំយុទ្ធសាស្ត្រមួយប្រភេទដែលផ្តល់ផលប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមជាតិទាំងមូលនិងបរិស្ថានជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូល សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារ ចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារ និងមុខរបរមានស្ថិរភាពជូនប្រជាជននៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក លើសពីនេះផ្តល់ឈើសម្រាប់ប្រើប្រាស់ផលិតគ្រឿងសង្ហារិម ជាឈើតន្នូនៈចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការការពារការហូរច្រោះដី និងជាគម្របបៃតង ដើម្បីចូលរួមថែរក្សាលំនឹងបរិស្ថានដោយឧស្ម័នផ្ទះកញ្ចក់ និងការកាត់បន្ថយបម្រែបម្រួលអាកាសធាតុជាបញ្ហាពិភពលោកដ៏ចម្បងមួយក្នុងពេលបច្ចុប្បន្ន និងអនាគត។

ផ្ទៃដីដាំដំណាំឧស្សាហកម្មរយៈពេលខ្លី (ពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកដីសណ្តែកសៀង ល្ង អំពៅ ក្រចៅ ថ្នាំជក់ ឈូក) សម្រេចបានចំនួន ៩៩៤.៦៤៧ហិកតា ក្នុងនោះផ្ទៃដីដាំដំណាំឧស្សាហកម្មរដូវវស្សាមានចំនួន ៨៨៥.៣៧៣ហិកតា និងដំណាំឧស្សាហកម្មរដូវប្រាំងមានចំនួន ៧៩.២៧៤ហិកតា។ បរិមាណផលដំណាំឧស្សាហកម្មសរុបទទួលបានចំនួន

[44] ដូច៤២, ទំព័រ ១៩។

១៥.១៣៩.៦៧២តោន ថយជាងឆ្នាំមុនចំនួន ៧០៨.១៣១តោន ដែលបរិមាណផលរដូវវស្សាចំនួន ១៤.២៧៧.៩២១តោន និងបរិមាណផលរដូវប្រាំងមានចំនួន ៨៦១.៧៥១តោន(ឧបសម្ព័ន្ធ៤)។[45]

ក្រៅពីនេះឆ្នាំ២០១៩ ផ្ទៃដីដាំកៅស៊ូសរុបមានចំនួន ៤០៥.៦៧១ហិកតា។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា ២ផ្នែកគឺ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្មមានចំនួន ២៤៤.៥៦៨ហិកតា និងកៅស៊ូគ្រួសារមានចំនួន ១៦១.១០៣ហិកតា។ ផ្ទៃដីចៀរជ័រអនុវត្តបានចំនួន ២៥០.៤៧៧ហិកតា និងផលិតផលកៅស៊ូសម្រេចបានចំនួន ២៨៧.៦៣៨តោន។ ទិន្នផលមធ្យមមានចំនួន ១.១៤៨គីឡូក្រាម/ហិកតា។[46]

ក្រាហ្វិកទី៣.៣៖ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុបឆ្នាំ២០១៥-២០១៩




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)*

### ៣.១.១.៤. ការអភិវឌ្ឍពិពិធកម្មដំណាំកសិកម្ម

ទោះបីជាមានការកើនឡើងទាំងបរិមាណផ្ទៃដីដាំដុះ ហើយទិន្នផលដំណាំកសិកម្មក៏ដោយ ក៏មិនអាចបំពេញតម្រូវការនៃការងារបានឡើយសម្រាប់ប្រជាជននៅជនបទ។ ដូច្នេះយើងត្រូវបង្កើតគោលដៅឬយុទ្ធសាស្រ្តជាច្រើន ដើម្បីចូលរួមចំណែកក្នុងការបង្កើតការងារតាមរយៈវិស័យកសិកម្ម និងកាត់បន្ថយភាពក្រីក្ររួមមាន៖[47]

---

[45] ដូច៤២, ទំព័រ ២០។

[46] ដូច៤២, ទំព័រ ៣៤-៣៥។

[47] ហាង ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ២១៥។

ទី១-ការតម្រង់ទិសវិនិយោគសាធារណៈ និងការលើកទឹកចិត្តដល់ការវិនិយោគឯកជននៅក្នុងវិស័យកសិកម្ម និងត្រូវលើកកម្ពស់គុណភាពកសិផលឲ្យស្របតាមស្តង់ដាអន្តរជាតិ។

ទី២-ការកែលម្អផលិតភាពកសិកម្ម ជាការជំរុញផលិតភាពដំណាំស្រូវឲ្យខ្ពស់ថែមទៀតតាមរយៈការអនុវត្តតាមផលិតកម្មសរីរាង្គចំពោះដីស្រែតូចៗ និងជាលក្ខណៈគ្រួសារ។ កត្តាទាំងនេះរួមបញ្ចូលទាំងការកែលម្អគុណភាពពូជ ការប្រើប្រាស់ជី ការគ្រប់គ្រងជំងឺ ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឲ្យមានប្រសិទ្ធភាព ការពង្រឹង ឬពង្រីកបច្ចេកទេសក្រោយពេលប្រមូលផល និងការប្រើប្រាស់ប្រព័ន្ធដាំដុះថ្មីៗដូចជា ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងប្រព័ន្ធផលិតកម្មចម្រុះ។ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម គឺជាកត្តាគន្លឹះល្អបំផុតដើម្បីអាចទទួលបានជោគជ័យក្នុងការធ្វើប្រពលវប្បកម្ម។

ទី៣-ការកែលម្អប្រព័ន្ធផ្គត់ផ្គង់ធាតុដើម ជាការបង្កើតការប្រើប្រាស់ពូជដែលមានទិន្នផលខ្ពស់ និងពូជកែលម្អ ត្រូវដើរទន្ទឹមគ្នានឹងកំណើនក្នុងការប្រើប្រាស់ជី។ ទោះបីជាកសិករយល់ដឹងពីការប្រើប្រាស់ជីក៏ដោយក៏ឧបសគ្គចម្បងបំផុត គឺការផ្គត់ផ្គង់មិនគ្រប់គ្រាន់ កង្វះនូវការធានាគុណភាព និងថ្លៃជីខ្ពស់ពេក។

ទី៤-ការជំរុញ និងការពង្រីកលទ្ធភាពប្រើប្រាស់ឧបករណ៍កសិកម្ម និងកត្តាផលិតកម្មផ្សេងទៀត។

ទី៥-ការលើកស្ទួយដំណាំសាកវប្បកម្ម និងឧស្សាហកម្ម ជាការលើកកម្ពស់ទៅលើប្រភេទដំណាំដែលមានអាយុកាលវែងដូចជា ដំឡូងមី ស្វាយ ស្វាយចន្ទី ចេក និងកៅស៊ូជាដើមដែលជាប្រភេទដំណាំទទួលបានទិន្នផលខ្ពស់ និងជាប្រភពការងារដែលមានរយៈពេលយូរ និងជាការងារបន្ថែមបន្ទាប់ពីការធ្វើស្រែចម្ការ។ ម្យ៉ាងទៀតការដាំដំណាំរួមផ្សំមួយចំនួនដែលមានរយៈពេលខ្លីក៏ជាប្រភពបង្កើតការងារ និងចំណូលបន្ថែមទៀតសម្រាប់ប្រជាកសិករដូចជាដំណាំបន្លែជាដើម។

ដូច្នេះ ការធ្វើពិពិធកម្មដំណាំកសិកម្មមិនត្រឹមតែជាប្រភពចំណូលសម្រាប់កសិករនៅជនបទទេ ថែមទាំងជួយបង្កើតការងារយ៉ាងច្រើនសម្រាប់ប្រជាកសិករថែមទៀត។

### ៣.១.២. ការបង្កើតការងារតាមការចិញ្ចឹមសត្វ និងវារីវប្បកម្ម

ជាការពិតណាស់ ការបង្កើតការងារតាមរយៈការចិញ្ចឹមសត្វ និងវារីវប្បកម្ម ជាផ្នែកមួយនៃកសិកម្មបន្ទាប់ពីពិពិធកម្មដំណាំកសិកម្ម។ ប្រជាកសិករអាចមានការងារធ្វើបន្ថែមបានលុះត្រាតែបង្កើត ឬជំរុញតាមរយៈការចិញ្ចឹមសត្វ និងវារីវប្បកម្ម។ ភាគច្រើននៃការចិញ្ចឹមសត្វដូចជា គោក្របីជ្រូក មាន់ ទាត្រូវបានចិញ្ចឹមដោយកសិករខ្នាតតូចដើម្បីសម្រាប់ហូបតាមគ្រួសារ។ ជាក់ស្តែងការ

ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបក្នុងឆ្នាំ២០១៩នេះ មានចំនួន ៣២,០៤លានក្បាល ក្នុងនោះ មានគោចំនួន ២,៧៧លានក្បាល ក្របីចំនួន ៤៩៧ពាន់ក្បាល ជ្រូកចំនួន ១,០៣លានក្បាល បក្សីចំនួន ២៧,៧៦លានក្បាល សេះចំនួន ៩ពាន់ក្បាល ចៀមចំនួន ៦៩៨ក្បាល ពពែចំនួន ២៨ពាន់ក្បាល និងដំរីចំនួន ១៨ក្បាល។ បើប្រៀបធៀបឆ្នាំ២០១៨ ស្ថិតិសត្វសរុបថយចុះ ៦,៧% ក្នុងនោះ គោ ក្របីថយ ៥,៩% ជ្រូកថយ ៤៦,៧% និងបក្សីថយ ៤,១%។

ក្រាហ្វិកទី៣.៤៖ ផលិតកម្មសត្វជាលក្ខណៈគ្រួសារឆ្នាំ២០១៥-២០១៩




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)*

ត្រីគឺជាមុខអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ត្រីបានផ្គត់ផ្គង់ជាមធ្យម ៣៩% នៃប្រូតេអ៊ីនក្នុងរបបអាហាររបស់ប្រជាជនកម្ពុជា ហើយជាសន្តិសុខស្បៀងរបស់មនុស្សរាប់លាននាក់ផ្សេងទៀតជាពិសេសក្នុងតំបន់ជនបទ ឬជនបទដាច់ស្រយាល។ ក្នុងនេះបង្ហាញថាវារីវប្បកម្មគឺជាផ្នែកមួយដែលចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយពង្រឹងសន្តិសុខស្បៀង និងការលើកកម្ពស់ជីវភាពរស់នៅ។ សម្រាប់គ្រួសារណាដែលធ្វើវារីវប្បកម្ម ត្រីមានតម្លៃស្មើនឹងគណនីធនាគារមួយ ព្រោះការចិញ្ចឹមត្រីបានបង្កើតចំណូលជាច្រើន។ វារីវប្បកម្មមាន ៨% នៃផលិតផលត្រីប្រចាំឆ្នាំ និងបានដើរតួនាទីដ៏សំខាន់មួយក្នុងការអភិវឌ្ឍតំបន់ជនបទ។ ដូច្នេះ វារីវប្បកម្មមិនត្រឹមតែអាចឲ្យគ្រួសារជនបទទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ និងកសិករតូចតាចអាចចិញ្ចឹមជីវិតបានប្រសើរបើប្រមូលផលមិនបានល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការងារ និង

ជួយបង្កើតកម្រិតប្រាក់ចំណូលក្នុងសហគមន៍ថែមទៀត។[48] យើងឃើញថា វារីវប្បកម្មមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពោលក្នុងឆ្នាំ២០១៩ មាន ៣០៧.៤០៨តោន ហើយឆ្នាំ២០១៨ មានចំនួន ២៥៤.០៤៨តោន ដែលមានការកើនឡើងស្មើនឹង ២១,០%។ ប៉ុន្តែទោះជាមានការឡើងក៏មិនទាន់បំពេញតម្រូវការការងារសម្រាប់ប្រជាជននៅជនបទនៅឡើយ។

ក្រាហ្វិកទី៣.៥៖ ផលិតផលវារីវប្បកម្មឆ្នាំ២០១៥-២០១៩




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)*

បើទោះបីជាការចិញ្ចឹមសត្វមានការកើនឡើងក៏ពិតមែន ប៉ុន្តែក្នុងឆ្នាំ២០១៩ មានការធ្លាក់ចុះនៃការចិញ្ចឹមសត្វ ហើយតម្រូវការនៃការងារក៏មានការកើនឡើងជារៀងរាល់ឆ្នាំ។ ដូច្នេះយើងត្រូវបង្កើត ឬចាត់វិធានការរយៈពេលខ្លី និងមធ្យមដើម្បីគាំទ្រការចិញ្ចឹមសត្វរួមមាន៖[49]

ការអភិវឌ្ឍប្រព័ន្ធចិញ្ចឹមសត្វចម្រុះ៖ រួមមាន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធឲ្យបានគ្រប់គ្រាន់ ការចាត់វិធានការប្រឆាំងនឹងជំងឺរាតត្បាតដើម្បីបង្កើនគុណភាពគោក្របី និងការគ្រប់គ្រងជំងឺ ការពង្រឹងនាយកដ្ឋានត្រួតពិនិត្យសុខភាព និងអធិការកិច្ច ផលិតកម្មចំណីសត្វ និងចំណីត្រី ព្រមទាំងការកែច្នៃសាច់សត្វ និងសាច់ត្រីឲ្យទៅជាផលិតផល ការបង្កើនចំនួនបុគ្គលិកពេទ្យសត្វ ដើម្បីកាត់បន្ថយអត្រាងាប់ ការឆ្លងរោគ ការធ្វើប្រព្រឹត្តកម្ម និងការកែច្នៃអនុផលសត្វ។

ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ៖ រួមមាន ផ្នែកបច្ចេកទេសពិសេសជំងឺមួយចំនួនបន្តមានអត្ថិភាពប្រចាំ កង្វះខាតស្មៅ និងប្រភពទឹក (អនុផលកសិកម្ម និងចំណីសត្វមិនអាចបំពេញ

[48] ហាង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ១៩៧-១៩៨។

[49] ដដែល, ទំព័រ ២២៦។

តួនាទីជំនួសស្មៅបានដោយសារតែតម្លៃខ្ពស់) និងផ្នែកហិរញ្ញវត្ថុទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ការវិនិយោគសាធារណៈទៅលើផ្នែកចិញ្ចឹមសត្វនេះនៅមានតិចតួចណាស់។

ការពង្រីក និងការស្តារឡើងវិញនៃឧស្សាហកម្មសូត្រ៖ ការយកចិត្តទុកដាក់ត្រូវធ្វើឡើងតាមរយៈការដាក់ឲ្យប្រើប្រាស់បច្ចេកទេសទំនើបក្នុងការចិញ្ចឹមដង្កូវនាង និងឧបករណ៍តម្បាញដែលល្អប្រសើរជាងមុន។

ដូច្នេះការបង្កើតការងារតាមរយៈការចិញ្ចឹមសត្វ និងវារីវប្បកម្មមិនត្រឹមតែបានបង្កើតចំណូលបន្ថែមនោះទេ ជាពិសេសបានបង្កើតការងារយ៉ាងច្រើនទៅដល់ប្រជាកសិករ ឬប្រជាជននៅជនបទនិងបានកាត់បន្ថយភាពក្រីក្រថែមទៀតផង។

## ៣.២. ការបង្កើតការងារតាមវិស័យមិនមែនកសិកម្ម

### ៣.២.១. ការវិនិយោគសាធារណៈ

ការវិនិយោគសាធារណៈ ជាផ្នែកមួយដ៏សំខាន់ដែលអាចជួយសម្រួលដល់ការបង្កើតការងារជូនប្រជាជននៅជនបទ និងការកាត់បន្ថយភាពក្រីក្រ។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធគួបផ្សំជាមួយលទ្ធភាពកាន់តែច្រើនរបស់អ្នកក្រីក្រដើម្បីចូលទៅក្នុងទីផ្សារ ការទទួលបានឥណទាន ការអប់រំ សុខាភិបាលនិងធានាបានថាឥទ្ធិពលនៃកំណើនវិជ្ជមាននឹងកើនឡើងសន្សឹមៗដល់អ្នកក្រីក្រ។ ក្នុងការលើកកម្ពស់ជីវភាពគ្រួសារនៅតំបន់ជនបទ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងសស្រាក់សស្រាំនៅក្នុងការវិនិយោគសាធារណៈដូចជា ប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ អគ្គិសនី និងការបង្កើតផ្សារនៅគ្រប់ទីកន្លែង។ ទាំងអស់នេះសបញ្ជាក់ថា ក្រៅពីការយកចិត្តទុកដាក់លើវិស័យកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាក៏យកចិត្តទុកដាក់ផងដែរលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលមិនត្រឹមតែជាផ្នែកមួយសម្រួលដល់ការបង្កើនការងារក្នុងវិស័យកសិកម្មទេ ប៉ុន្តែវាក៏បានសម្រួលដល់ការងារក្នុងវិស័យមិនមែនកសិកម្មផងដែរ។

#### ៣.២.១.១. ប្រព័ន្ធធារាសាស្ត្រ

ជាការពិតណាស់ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ជាសរសៃឈាមដ៏មានសារៈសំខាន់រាល់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ជាពិសេសនៅក្នុងការអភិវឌ្ឍលើវិស័យកសិកម្ម។ ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្របានល្អប្រសើរជាធាតុមួយក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច។ កង្វះខាតប្រព័ន្ធស្រោចស្រពធ្វើឲ្យកសិករប្រើប្រាស់ប្រព័ន្ធស្រោចស្រពដូចជាម៉ាស៊ីនបូមទឹកដែលកសិករប្រើសម្រាប់បូមទឹកពីទន្លេ ពីអាងស្តុកទឹកបម្រុងដែលជាហេតុមួយដែលកសិករចំណាយខ្ពស់ និងជាកត្តាមួយបង្អាក់ការធ្វើឲ្យប្រសើរឡើងជីវភាព។

ដូចបានលើកឡើងក្នុងជំពូកទី២ លើផ្ទៃដីដាំដុះស្រូវទាំងរដូវវស្សា និងរដូវប្រាំងបានត្រឹមតែ ២៧% ទៅ ៤០% ប៉ុណ្ណោះ ដែលមានប្រព័ន្ធស្រោចស្រព។ ការណ៍នេះសបញ្ជាក់ថា ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតនៅឡើយ និងផ្ទៃដីដាំដុះដែលការគ្របដណ្តប់ដោយប្រព័ន្ធធារាសាស្ត្រក៏នៅមានបរិមាណតិច។ ហេតុផលដែលការវិនិយោគលើធារាសាស្ត្រមិនសូវមាន និងប្រព័ន្ធស្រោចស្រពប្រើមិនអស់លទ្ធភាព គឺជាផលវិនិយោគផ្នែកហិរញ្ញវត្ថុពីគម្រោងធារាសាស្ត្រមានអត្រាទាប។ ដើម្បីបង្កើនការងារដាំដុះ ប្រព័ន្ធធារាសាស្ត្រប្រៀបបាននឹងទំនិញសាធារណៈ ដែលត្រូវផ្តល់ការវិនិយោគដោយរាជរដ្ឋាភិបាល។

ប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យប្រសើរឡើងកាន់តែខ្លាំងនូវផលិតកម្មស្រូវ ជាពិសេសនៅរដូវប្រាំង និងសម្រាប់កសិកម្មលក្ខណៈជំនួញ។ ការទទួលបានទឹក និងប្រព័ន្ធធារាសាស្ត្រ គឺជាកត្តាជំរុញចម្បងរបស់ផលិតភាពដី និងស្ថិរភាពនៃទិន្នផល។ ផលិតភាពដីដែលមានប្រព័ន្ធធារាសាស្ត្រមានចំនួន ២ដងច្រើនជាងប្រសិទ្ធភាពដីដែលផ្គត់ផ្គង់ដោយទឹកភ្លៀង។[50] ប្រព័ន្ធធារាសាស្ត្រក៏សំខាន់ផងដែរដើម្បីធានាថា គ្រួសារកសិករទុកចិត្តក្នុងការដាំដំណាំនៅក្នុងរដូវវស្សា និងពិពិធកម្មដំណាំកសិកម្មនៅក្នុងរដូវប្រាំង។ យោងតាមវិទ្យាស្ថានគ្រប់គ្រងធនធានទឹកអន្តរជាតិ(IWMI) ស្រូវដែលមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់នៅរដូវប្រាំងផ្តល់ទិន្នផល ៥-៦តោនក្នុងមួយហិកតាខ្ពស់ជាងទិន្នផលនៅក្នុងរដូវវស្សា។[51] ក្រៅពីដំណាំស្រូវកសិករក៏អាចប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រសម្រាប់ដាំដំណាំផ្សេងទៀតដូចជា ដំណាំហូបផ្លែ និងកសិដ្ឋានបន្លែ ជាពិសេសពិពិធកម្មដំណាំកសិកម្ម។ល។ ប្រព័ន្ធធារាសាស្ត្រផ្តល់លទ្ធភាពដល់កសិករផ្លាស់ប្តូរពីការដាំដុះ ១ដងក្នុងមួយឆ្នាំ (រដូវវស្សា) ទៅ ២ ឬ ៣ដងក្នុងមួយឆ្នាំ និងប្រសិទ្ធភាពនៃការប្រើប្រាស់កម្លាំងពលកម្មមានការកើនឡើងដោយសារមានប្រព័ន្ធធារាសាស្ត្រ។

ជារួមការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ជាការបង្កើតឱកាសការងារដល់ប្រជាជននៅតំបន់ជនបទ ពោលគឺអាចឲ្យកសិករដាំដុះនៅនៅរដូវប្រាំង និងប្តូរពីការដាំដុះតែមួយដងក្នុងរដូវវស្សាទៅជាការដាំដុះបាន ២ ទៅ ៣ដងក្នុងមួយឆ្នាំដោយមានប្រភពទឹកគ្រប់គ្រាន់។

---

[50] ធនាគារពិភពលោក, *កសិកម្មសម្រាប់ការអភិវឌ្ឍ* (វ៉ាស៊ីនតោន ឌីស៊ី៖ ធនាគារពិភពលោក, ២០០៨), ១៧។

[51] វិទ្យាស្ថានគ្រប់គ្រងធនធានទឹកអន្តរជាតិ, *Agricultural Water Management Planning in Cambodia* [គម្រោងគ្រប់គ្រងទឹកសម្រាប់កសិកម្មនៅកម្ពុជា] (វិទ្យាស្ថានគ្រប់គ្រងធនធានទឹកអន្តរជាតិ, ២០១៣), ៦។

### ៣.២.១.២. ផ្លូវជនបទ

ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទនិងគមនាគមន៍ ជាធាតុមួយមិនអាចខ្វះបានសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចព្រមទាំងពង្រឹងការប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ជាពិសេសសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។[52]

ដូចបានលើកឡើងក្នុងជំពូកទី២ បណ្ដាញផ្លូវថ្នល់នៅកម្ពុជាមានផ្លូវជនបទប្រហែល ៧៥% ក្នុងនោះមានតែប្រហែល ៥% ប៉ុណ្ណោះដែលបានត្រួសត្រាយ និងផ្នែកដែលនៅសល់ជាផ្លូវក្រួសក្រហម និងផ្លូវដី។ កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់បានបង្កឧបសគ្គយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍតំបន់ជនបទដោយសារតែបញ្ហានៃការស្តុកទុក និងការដឹកជញ្ជូនផលិតផល។ រីឯថ្លៃដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ធៀបនឹងតំបន់។ ថ្លៃខ្ពស់នៃការដឹកជញ្ជូនតាមផ្លូវថ្នល់ធ្វើឲ្យកសិករកម្ពុជាមិនអាចប្រកួតប្រជែងឈ្នះប្រទេសជិតខាងដូចជា ថៃ និងវៀតណាម ដែលនៅប្រទេសនោះហេដ្ឋារចនាសម្ព័ន្ធមានគុណភាពល្អជាង។[53]

ការអាចដឹកជញ្ជូនទំនិញ និងការផ្តល់មធ្យោបាយធ្វើដំណើរដល់ប្រជាជនកាន់តែរហ័ស និងមានតម្លៃថោកអាចជួយបង្កើតការងារ បង្កើនបរិមាណជំនួញ កាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទកាន់តែប្រសើរឡើង។ ជាក់ស្តែង វិស័យទេសចរណ៍ជាពិសេសទេសចរណ៍ជនបទត្រូវពឹងផ្អែកលើផ្លូវថ្នល់ជាចាំបាច់។ វិស័យសំណង់ និងវិស័យឧស្សាហកម្មធុនតូចនិងមធ្យមត្រូវការផ្លូវថ្នល់ដើម្បីទទួលបានវត្ថុធាតុដើម។ ដូចគ្នាដែរវិស័យកសិកម្មពឹងផ្អែកលើផ្លូវថ្នល់ដើម្បីដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ។ ប្រសិនបើផ្លូវជនបទមានមិនគ្រប់គ្រាន់ មានភាពយឺតយ៉ាវ និងត្រូវចំណាយច្រើន ជាកត្តាមួយដែលប្រជាជនមានភាពក្រីក្រ និងគ្មានការងារធ្វើនៅតំបន់ជនបទ។

អាស្រ័យហេតុនេះ ការវិនិយោគលើផ្លូវជនបទឲ្យបានគ្រប់គ្រាន់មានភាពចាំបាច់ ដើម្បីលើកស្ទួយសុខុមាលភាពប្រជាជននៅតំបន់ជនបទ។ ការកសាងផ្លូវជនបទនឹងជួយបង្កើនផលិតកម្មកសិកម្មទាំងតាមរយៈការពង្រីកផ្ទៃដីដាំដុះ ឬការធ្វើប្រពលវប្បកម្មនៃការប្រើប្រាស់ដីដែលមានស្រាប់អនុញ្ញាតឲ្យកសិករទទួលបានផលិតផលពីទីផ្សារថ្មីៗ និងច្របាច់បញ្ចូលគ្នានូវទំនាក់ទំនងនានារវាងសកម្មភាពកសិកម្ម និងមិនមែនកសិកម្មនៅក្នុងតំបន់ជនបទ ព្រមទាំងរវាង

[52] ក្រសួងអភិវឌ្ឍន៍ជនបទ, *របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០* (ភ្នំពេញ៖ ក្រសួងអភិវឌ្ឍន៍ជនបទ, ២០២០), ៨។

[53] ហាង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ២០៨។

តំបន់ជនបទ និងទីក្រុង។ ដើម្បីបង្កើតការងារនៅតំបន់ជនបទ និងកាត់បន្ថយចំណាយដឹកជញ្ជូន រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ត្រូវបង្កើនការវិនិយោគឲ្យបានច្រើនក្នុងការកែលម្អផ្លូវជនបទ ផ្លូវខេត្ត និងផ្លូវជាតិឲ្យមានគុណភាពល្អប្រសើរ និងគ្រប់គ្រាន់។

**៣.២.១.៣. អគ្គិសនី**

ការផ្គត់ផ្គង់ថាមពលអគ្គិសនី គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយសារប្រជាពលរដ្ឋត្រូវការថាមពលអគ្គិសនីជាតម្រូវការដ៏ចាំបាច់នៅក្នុងសង្គមទំនើប និងជាកត្តាផលិតកម្មមួយដែលមិនអាចខ្វះបាន ហើយការចំណាយលើថាមពលអគ្គិសនីបានជះឥទ្ធិពលលើការប្រកួតប្រជែងរបស់ប្រទេសក្នុងការផលិតទំនិញនិងផ្តល់សេវាដ៏សម្បូរបែប និងចូលរួមជាធាតុចូលដោយផ្ទាល់ និងប្រយោលទៅក្នុងថ្លៃដើមទំនិញ និងសេវា។ លទ្ធភាពអាចរកបានថាមពលអគ្គិសនីដែលមានតម្លៃថោកសមរម្យ ជាគ្រឿងផ្សំដ៏សំខាន់មួយនៃការអភិវឌ្ឍជនបទ ជាពិសេសក្នុងសកម្មភាពនានាដូចជា ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ការកែច្នៃកសិផលកសិកម្ម និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។[54]

ឧបសគ្គមួយនៃសេដ្ឋកិច្ចកម្ពុជា គឺទំហំនៃការប្រើប្រាស់អគ្គិសនីនៅតំបន់ជនបទនៅមានកម្រិតនៅឡើយ។ នៅឆ្នាំ២០១៨ ស្ទើរតែគ្រប់គ្រួសារ (៩៧,៦%នៃគ្រួសារទាំងអស់) ទទួលបានអគ្គិសនីប្រើប្រាស់យ៉ាងតិចមួយប្រភព (៧១,៥% ពីបណ្តាញអគ្គិសនីជាតិ និង ២៦,១% ពីប្រភពមិនមែនជាបណ្តាញជាតិ) ក្នុងនោះប្រហែល ១ភាគ៣ នៃគ្រួសារជនបទពឹងផ្អែកលើប្រភពអគ្គិសនីដែលមិនមែនជាបណ្តាញអគ្គិសនីជាតិដូចជា ថាមពលអគ្គិសនីពីព្រះអាទិត្យ និងអាគុយ។ល។ ការទទួលបានអគ្គិសនីប្រើប្រាស់របស់គ្រួសារជនបទបានកើនឡើងគួរឲ្យកត់សម្គាល់ ដែលបានកើនពី ៦,៥៦% ក្នុងឆ្នាំ២០០០ ទៅ ៨៦% ក្នុងឆ្នាំ២០១៧។ ប៉ុន្តែបើប្រៀបធៀបជាមួយប្រទេសជិតខាងកម្ពុជាហាក់ដូចជានៅមានកម្រិតទាប។ ក្នុងរយៈពេលដូចគ្នានេះ ប្រទេសឡាវបានបង្កើនការទទួលបានអគ្គិសនីប្រើប្រាស់របស់គ្រួសារជនបទពី ២៨% ទៅ ៩០%។ ការកើនឡើងនេះបណ្តាលមកពីការវិនិយោគដ៏សន្ធឹកសន្ធាប់ទៅលើទំនប់វារីអគ្គិសនី ដែលប្រែក្លាយពីប្រទេសកង្វះថាមពលអគ្គិសនីទៅជាអ្នកនាំចេញថាមពលអគ្គិសនី។ ចំណែកឯប្រទេសថៃ និងវៀតណាមប្រជាជននៅតំបន់ជនបទ ១០០% មានអគ្គិសនីប្រើប្រាស់តាំងពីឆ្នាំ២០១០ម្ល៉េះ។[55]

[54] ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ៣៣៩។

[55] វ.ស.ក, *Status and Challenges of Rural Electrification in Cambodia and Renewable Energy Option* [ស្ថានភាព និងបញ្ហាប្រឈមនៃការផ្តល់ថាមពលអគ្គិសនីជនបទ និងជម្រើសថាមពលកើតឡើងវិញ] (ភ្នំពេញ៖ វ.ស.ក, ២០១៩), ១-៥។

ថាមពលអគ្គិសនីកម្ពុជាជាមធ្យមមានតម្លៃ ៦៨០រៀល (០,១៧ដុល្លារ) ក្នុងមួយគីឡូវ៉ាត់ម៉ោង តម្លៃនេះខ្ពស់បន្តិចបើប្រៀបធៀបទៅនឹងប្រទេសជិតខាងកម្ពុជាំ (ថៃ ០,១៣ដុល្លារ ឡាវ ០,០៨ដុល្លារ និងវៀតណាម ០,១២ដុល្លារ) ដែលធ្វើឲ្យកម្ពុជាពិបាកប្រកួតប្រជែងលើគ្រប់វិស័យទាំងអស់។[56] មូលហេតុនៃតម្លៃអគ្គិសនីខ្ពស់បណ្តាលមកពីរោងចក្រផលិតថាមពលអគ្គិសនីតូច ការច្របាច់បញ្ចូលគ្នាមិនបានល្អប្រសើរ សមត្ថភាពទាប រោងចក្រផលិតថាមពលអគ្គិសនីមួយចំនួនប្រើប្រាស់ប្រេងម៉ាស៊ូត និងថ្លៃដើមគ្រប់គ្រងខ្ពស់។ តម្លៃអគ្គិសនីនេះអាចផ្គត់ផ្គង់សម្រាប់តែការប្រើប្រាស់សម្រាប់បំភ្លឺតាមគ្រួសារតែប៉ុណ្ណោះ មិនអាចផ្គត់ផ្គង់សម្រាប់សិប្បកម្ម និងឧស្សាហកម្មធុនតូច និងមធ្យម ដែលជាវិស័យមួយបង្កើតឱកាសការងារនៅតំបន់ជនបទបានទេ។ អគ្គិសនីដែលមានតម្លៃថ្លៃ និងមិនអាចទុកចិត្តបានធ្វើឲ្យវិនិយោគិនមានការរារែក។ យោងតាមការស្ទង់មតិដែលធ្វើឡើងដោយ ADB និង WB បានឲ្យដឹងថា វិនិយោគិននៅតែបញ្ជាក់ថាការចំណាយថាមពលអគ្គិសនីខ្ពស់ និងការដាច់ភ្លើងដោយមិនបានដឹងមុន គឺជាឧបសគ្គដ៏ធំក្នុងការប្រកបធុរៈកិច្ចនៅកម្ពុជា។[57] កម្ពុជាបន្តខ្វះថាមពលអគ្គិសនីនេះតទៅទៀត ដែលនាំឲ្យមានការដាច់ភ្លើងជារឿយៗ ហើយអ្នកប្រើប្រាស់ត្រូវទិញម៉ាស៊ីនភ្លើងដែលមានថ្លៃដើមផលិតខ្ពស់ និងប្រើប្រាស់ប្រេងម៉ាស៊ូតក្នុងគោលដៅទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីដោយមិនមានការរំខាន។ម្យ៉ាងទៀត ការប្រើប្រាស់ម៉ាស៊ីនភ្លើងមិនអាចផ្គត់ផ្គង់ថាមពលបានគ្រប់គ្រាន់សម្រាប់វិស័យឧស្សាហកម្មកម្មន្តសាលនោះបានដែរ ហើយក្នុងតម្លៃបែបបច្ចុប្បន្ននេះ ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មភាគច្រើនមិនមានប្រសិទ្ធភាព ជាពិសេសក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាងកម្ពុជា។ ចំពោះវិស័យកសិកម្ម អគ្គិសនីមានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងធនធានទឹក និងការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ។ ការកាត់បន្ថយថ្លៃថាមពលអគ្គិសនីនឹងជួយឲ្យកសិករអាចបង្កើនផលិតកម្មវិស័យកសិកម្មបានច្រើនជាងមុន។

ដូច្នេះ ថ្លៃអគ្គិសនីខ្ពស់នៅតាមជនបទ គឺជាឧបសគ្គដ៏ចម្បងដែលរារាំងការអភិវឌ្ឍដ៏យឺតយ៉ាវនៃសេដ្ឋកិច្ចជនបទនៅកម្ពុជា ជាពិសេសក្នុងគោលដៅបង្កើតឱកាសការងារ។ ក្នុងន័យនេះ រដ្ឋត្រូវសាងសង់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីឲ្យបានគ្រប់គ្រាន់ និងកែលម្អក្របខណ្ឌគតិយុត្តិ ដើម្បីរក្សាតម្លៃអគ្គិសនីឲ្យនៅទាប និងធ្វើឲ្យប្រសើរឡើងគុណភាពសេវា។

---

[56] ដូច៥៥, ទំព័រ ៥។

[57] ADB, *ធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា* (ភ្នំពេញ, ២០១២), ៦, https://think-asia.org/bitstream/handle/11540/94/adb-cambodia-20-yrs-anniversary-book-kh.pdf?sequence=2 ចូលទស្សនាថ្ងៃទី ០៨ មិថុនា ២០២០។

#### ៣.២.១.៤. ការបង្កើតផ្សារនៅជនបទ

ផ្សារនៅជនបទ គឺជាកន្លែងប្រកបមុខរបរលក់ដូរផលិតផលកសិកម្ម និងផលិតផលផ្សេងទៀតជាពិសេសបានបង្កើតការងារទៅដល់ប្រជាជននៅតំបន់ជនបទ។ ប៉ុន្តែ ផ្សារនៅតំបន់ជនបទមានការខ្វះខាត ហើយភាគច្រើនផ្សារមានតែនៅទីប្រជុំជនតែប៉ុណ្ណោះ ដូច្នេះឱកាសការងារសម្រាប់ប្រជាជននៅតំបន់ជនបទគឺមានតិចតួច។ មួយវិញទៀត ការខ្វះខាតផ្លូវថ្នល់ ប្រជាជននៅជនបទខ្វះខាតចំណេះដឹង និងការផ្គត់ផ្គង់ផលិតផលមិនគ្រប់គ្រាន់ក៏ជាបញ្ហាសម្រាប់ការបង្កើតផ្សារនៅជនបទ ដែលជាហេតុផលធ្វើឲ្យបាត់បង់ឱកាសការងាររបស់ប្រជាជននៅជនបទ។[58] ដូច្នេះតម្រូវឲ្យមានការបង្កើតផ្សារនៅជនបទ ពីព្រោះផ្សារអាចបង្កើតការងារជាច្រើនដល់ប្រជាជន ដូចជា ទី១៖ ផ្តល់ជាចំណុចកណ្តាលរវាងកសិករ និងកសិករក្នុងការជួបគ្នាសម្រាប់ដោះដូរទំនិញដោយប្រជាជនអាចលក់ផលិតផលកសិកម្មរបស់ខ្លួនក្នុងផ្សារបានយ៉ាងងាយស្រួល។ ទី២៖ កាត់បន្ថយការខាតបង់ទំនិញកសិកម្មដែលប្រជាកសិករផលិតបាន ពីព្រោះមានផ្សារសម្រាប់លក់ដូរទំនិញទាំងនេះ។ ទី៣៖ ជាទីផ្សារក្នុងការគាំទ្រផលិតកសិករ។

ដូច្នេះ យើងឃើញថាការបង្កើតឲ្យមានផ្សារនៅតំបន់ជនបទ គឺបានបង្កើតការងារយ៉ាងច្រើនជូនប្រជាជន ថែមទាំងជាកន្លែងផ្តល់ជាប្រាក់ចំណូលតាមរយៈការលក់ដូរផលិតផលកសិកម្ម ជាពិសេសជាទីផ្សារសម្រាប់ផលិតផលកសិកម្ម។

### ៣.២.២. ការផ្តល់កម្ចីកសិកម្មជាមួយអត្រាការប្រាក់ទាប

វិស័យហិរញ្ញវត្ថុបានបម្រើសេវាហិរញ្ញវត្ថុមួយផ្នែកធំដល់វិស័យជំនួញអាជីវកម្ម មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម(MSMEs) និងផ្គត់ផ្គង់ឥណទានសម្រាប់ប្រជាជននៅតំបន់ជនបទ ជាពិសេសក្នុងផលិតកម្មវិស័យកសិកម្មនៅកម្ពុជា។ វិស័យកសិកម្មមិនសូវទទួលបានសេវាហិរញ្ញវត្ថុពីធនាគារទេ ព្រោះថាធនាគារភាគច្រើនផ្តោតតែលើការបម្រើសេវាអាជីវកម្មនៅទីក្រុង។ ដូច្នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(MFIs) និងគ្រឹះស្ថានឥណទានជនបទ ជាអ្នកផ្តល់សេវាហិរញ្ញវត្ថុចម្បងសម្រាប់សេដ្ឋកិច្ចជនបទដូចជា ផ្តល់ប្រាក់កម្ចីជូនកសិករ និងអ្នកខ្ចីដទៃទៀត។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ ធនាគារពាណិជ្ជបានផ្តល់ឥណទានក្នុងវិស័យកសិកម្មត្រឹមតែ ០,៩% នៃប្រតិបត្តិការឥណទាននៃវិស័យធនាគារ និង MFIs ផ្តល់ឥណទានក្នុងវិស័យកសិកម្ម ១៩,៤% នៃប្រតិបត្តិការឥណទានក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានឥណទានជនបទ ជាគ្រឹះស្ថាន

[58] Jonh Tracey-White, *Planning and designing Rural markets* [ការរៀបចំផែនការ និងការរចនាផ្សារនៅជនបទ] (Rome: Food and Agriculture Organization of the United Nation, 2003), 6។

ដែលផ្តល់ឥណទានខ្នាតតូច និងតូចបំផុតដល់អតិថិជន ដែលក្នុងនោះមានកសិកម្ម ៣៥,៨% ពាណិជ្ជកម្ម ៣២,៣% គ្រួសារ ១៦,៣% សេវាកម្ម ១៣,៥% ដឹកជញ្ជូន ០,៤% សំណង់ ៥,៩% និងផ្សេងៗ ៦,៨%។[59] នៅមុនខែមេសា ២០១៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់កម្ចីដោយអត្រាការប្រាក់ចន្លោះ ២៥% ទៅ ៤៣% (សម្រាប់ប្រាក់រៀល) និង ១៨% ទៅ ៤១% (សម្រាប់ប្រាក់ដុល្លារ)។[60] ប៉ុន្តែនៅខែមេសា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា(NBC) បានកំណត់ពិដានអត្រាការប្រាក់ឥណទានចំពោះ MFIs និងប្រតិបត្តិករឥណទានជនបទ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ NBC មិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ។ បើទោះបីមានការកំណត់អត្រាការប្រាក់ពិដាន ក៏កម្ចីឥណទានមានអត្រាការប្រាក់នៅតែខ្ពស់សម្រាប់កសិករ និងភាគីពាក់ព័ន្ធក្នុងវិស័យកសិកម្មក្នុងការទទួលបានប្រភពទុនសម្រាប់បង្វិល។

គិតមកដល់ដំណាច់ឆ្នាំ២០១៩ ប្រព័ន្ធធនាគារនៅកម្ពុជា មានធនាគារពាណិជ្ជចំនួន៤៧ ធនាគារឯកទេសមានចំនួន១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន៨៣(គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន៧ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៧៦) និងគ្រឹះស្ថានឥណទានជនបទ ២៤៥ (ឧបសម្ព័ន្ធ៥)។[61] គ្រឹះស្ថានទាំងនេះមួយចំនួនត្រូវបានបង្កើតឡើងជា NGOs ដែលទទួលជំនួយឧបត្ថម្ភពីម្ចាស់ជំនួយ ប៉ុន្តែខ្លះទៀតបង្កើតឡើងជា MFIs ដើម្បីរកប្រាក់ចំណេញបែបពាណិជ្ជកម្ម។ សេវាដែលផ្តល់ដោយគ្រឹះស្ថានទាំងនេះអាចជួយដល់អ្នកជនបទ ជាពិសេសអ្នកក្រីក្រក្នុងការបង្កើនប្រាក់ចំណូល និងទ្រព្យសម្បត្តិ។

ប៉ុន្តែជាមួយនឹងការគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី និងវត្ថុបញ្ចាំផ្សេងៗធ្វើឲ្យកសិករគ្មានសមត្ថភាពក្នុងការទទួលបានឥណទាន។ ការមិនទទួលបានឥណទានសម្រាប់កសិករ និងអ្នកដទៃទៀតដែលស្ថិតក្នុងខ្សែស្រឡាយ ឬការទទួលបានឥណទានដែលមានអត្រាការប្រាក់មួយខ្ពស់ និងមានរយៈពេលខ្លី គឺជាឧបសគ្គចម្បងមួយដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា។ ភាគច្រើននៃដើមទុនរបស់កសិករ អាជីវកម្មកសិកម្មធុនតូចបានមកពីគ្រួសារ និងមិត្តភក្តិ ដែលកម្ចីទាំងនោះមានទំហំតូច និងមានរយៈពេលថេរ។ ក្នុងករណីដែលត្រូវទិញធាតុចូលក្នុងផលិតកម្មស្រូវ កម្ចីត្រូវមានរយៈពេលយ៉ាងតិចណាស់មួយរដូវដាំដុះ។ អត្រាការប្រាក់រមែងតែខ្ពស់ ប៉ុន្តែគ្មានរបស់បញ្ចាំ ឬ

[59] ធនាគារជាតិនៃកម្ពុជា, *របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១៩* (ភ្នំពេញ៖ ធនាគារជាតិនៃកម្ពុជា, ២០២០), ១០។

[60] ធនាគារពិភពលោក, *Microfinance and household welfare: Cambodia policy note* [មីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ៖ កំណត់សម្គាល់គោលនយោបាយកម្ពុជា] (Washington, DC: World Bank, 2019), 15។

[61] ដូច៥៩, ទំព័រ ១។

ក្រដាសស្នាម។ កម្ចីខ្លះខ្ចីពីអ្នកផ្គត់ផ្គង់វូបធាតុដើម និងឈ្មួញក្នុងលក្ខណៈជាប្រាក់សុទ្ធ ឬសម្ភារៈបរិក្ខារ។ ក្នុងករណីនេះ កម្ចីត្រូវទូទាត់នៅពេលប្រមូលផលពីកសិកម្ម។

ដូច្នេះ វិស័យកសិកម្មកម្ពុជា ជាពិសេសកសិករ និងភាគីពាក់ព័ន្ធត្រូវការគាំទ្រពីវិស័យហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ទាបអាចទទួលយកបានក្នុងការធ្វើទំនើបកម្មកសិកម្មដូចជា ការទិញថាមពលអគ្គិសនីសម្រាប់បូមទឹកស្រោចស្រព គ្រាប់ពូជ ព្រមទាំងឧបករណ៍ និងសម្ភារៈបរិក្ខារដែលទ្រទ្រង់ក្នុងវិស័យកសិកម្ម។ ការរីកចម្រើនខាងកសិករតូចតាច ក៏ដូចជារោងម៉ាស៊ីនកិនស្រូវ ជាការបង្កើតឱកាសការងារក្នុងវិស័យកសិកម្ម បង្កើនប្រាក់ចំណូល កាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយចំណាកស្រុកផងដែរ។

### ៣.២.៣. ការបង្កើតមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម(MSMEs)

MSMEs មានតួនាទីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់កម្ពុជា ដែលត្រូវបំពេញតម្រូវការមូលដ្ឋាននៃទំនិញ និងសេវាកម្មក៏ដូចជាការចូលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ។ សហគ្រាសបែបនេះមានជាង ៩០% នៃសហគ្រាសសរុបនៅកម្ពុជា និងចូលរួមចំណែកក្នុងការផលិត និងផ្តល់សេវានៅក្នុងប្រទេសកម្ពុជា។ វត្តមានរបស់ MSMEs នៅកម្ពុជាបានផ្តល់ឱកាសការងារសម្រាប់ប្រជាជនក្នុងប្រទេសគ្រប់ទិសទី ជាពិសេសនៅតាមទីជនបទដាច់ស្រយាល និងធ្វើឲ្យប្រសើរឡើងផងដែរនូវការបែងចែកប្រាក់ចំណូល។

ការចាត់ថ្នាក់ MSMEs ធ្វើឡើងដោយយោងតាមទំហំបុគ្គលិក ទំហំនៃទ្រព្យសកម្ម(ដោយមិនរាប់បញ្ចូលដី) និងទំហំនៃចំណូលប្រចាំឆ្នាំរបស់សហគ្រាស(តារាងទី៣.១)។

តារាងទី៣.១៖ ចំណាត់ថ្នាក់ MSMEs នៅកម្ពុជា[62]

| ចំណាត់ថ្នាក់ | បុគ្គលិក(នាក់) | ទ្រព្យសកម្ម(លានរៀល) | ចំណូលប្រចាំឆ្នាំ(លានរៀល) |
|---|---|---|---|
| មីក្រូសហគ្រាស | <១០ | <២០០ | <២៥០ |
| សហគ្រាសធុនតូច | ១១-៥០ | ចាប់ពី២០០-តិចជាង២៥០ | ចាប់ពី២៥០-តិចជាង៧០០ |
| សហគ្រាសធុនមធ្យម | ៥១-១០០ | ចាប់ពី២៥០-តិចជាង២.០០០ | ចាប់ពី៧០០-តិចជាង២.០០០ |
| សហគ្រាសធុនធំ | >១០០ | >២.០០០ | >២.០០០ |

ក្នុងវិស័យឧស្សាហកម្ម សហគ្រាសមីក្រូដែលមានបុគ្គលិកតិចជាង ១០នាក់ មានច្រើនជិត ៩៧,៣% សហគ្រាសធុនតូច និងមធ្យមដែលមានបុគ្គលិកចន្លោះ ១១ ដល់ ៥០នាក់ មានជាង

[62] ព្រុំ ទេវី, *ទស្សនៈទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា* (ភ្នំពេញ, ២០១៩), ៥, http://rac.gov.kh/royal-academy/research/attachments/original/21.pdf?1546423309 ថតចម្លងថ្ងៃទី ១៥ មិថុនា ២០២០។

២,២% និងសហគ្រាសធុនធំដែលមានបុគ្គលិកចាប់ពី ៥០នាក់ឡើងទៅមាន ០,៦%។ ក្នុងចំណោមសហគ្រាសទាំងនោះ ចំនួនសហគ្រាសកម្មន្តសាលមានដល់ទៅ ៩១,៧%។ បើគិតក្នុងបរិការណ៍នៃកម្លាំងពលកម្មវិញ សហគ្រាសធុនធំស្រូបយកកម្លាំងពលកម្ម ៦៣,៣% សហគ្រាសមីក្រូស្រូបយក ២៩,៣% និងសហគ្រាសធុនតូច និងមធ្យមស្រូបយក ៧,៤%។ លើសពីនេះសហគ្រាសកម្មន្តសាលនៅកម្ពុជាមានលក្ខណៈប្រមូលផ្តុំ ក្នុងនោះសហគ្រាសធុនមីក្រូរាយប៉ាយសឹងគ្រប់ទីកន្លែង និងគ្រប់ខេត្តទៅតាមដង់ស៊ីតេប្រជាជន។ ដោយឡែក សហគ្រាសធុនតូចនិងមធ្យមប្រមូលផ្តុំគ្នានៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ចាម។[63] ការប្រមូលផ្តុំគ្នានៅតែទីក្រុង និងទីប្រជុំជននេះកើតឡើងដោយសារតែមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បណ្តាញអគ្គិសនី និងសេវាសាធារណៈ ដែលបម្រើឲ្យដំណើរការនៃផលិតកម្មមានលក្ខណៈងាយស្រួល។ ការប្រមូលផ្តុំនៅតែ ទីក្រុង និងទីប្រជុំជន ជាកត្តារាំងខ្ទប់ក្នុងការអភិវឌ្ឍជនបទ ជាពិសេសធ្វើឲ្យមានការកើនឡើងការធ្វើចំណាកស្រុកពីជនបទមកទីក្រុងកាន់តែច្រើន។

លោក Uchikawa និង Keola បានបែងចែក MSMEs នៅកម្ពុជា វៀតណាម និងឡាវ ជា៤ក្រុមធំៗគឺ ក្រុមអ្នកផ្គត់ផ្គង់ឧស្សាហកម្ម ក្រុមឧស្សាហកម្មសម្រាប់នាំចេញ ក្រុមអ្នកផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងក្រុមមីក្រូសហគ្រាស។ MSMEs នៅកម្ពុជាមានតួនាទីមិនត្រឹមតែផលិតទំនិញ និងផ្តល់សេវាដល់ទីផ្សារប៉ុណ្ណោះទេ តែសហគ្រាសទាំងនេះភាគច្រើនប្រើវិធីសាស្ត្រផលិតតាមបែបប្រពៃណី ការកែច្នៃម្ហូបអាហារ ផលិតឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ វត្ថុអនុស្សាវរីយ៍ និងគ្រឿងអលង្ការ។ល។ ក្នុងន័យនេះ MSMEs មិនត្រឹមតែជាអ្នកបង្កើតការងារបន្ថែម និងជួយបង្កើនប្រាក់ចំណូលដល់ប្រជាជនតាមជនបទ តែបានរួមចំណែកក្នុងការថែរក្សាវិធីសាស្ត្រផលិតតាមបែបប្រពៃណី និងធ្វើឲ្យអ្នកប្រើប្រាស់ គេស្គាល់ពីប្រពៃណីរបស់ខ្មែរទៀតផង។[64]

ដូច្នេះ ការបង្កើត MSMEs នៅតំបន់ជនបទជាពិសេសសហគ្រាសធុនតូច និងមធ្យមមានគោលបំណង បង្កើតឱកាសការងារ បង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានចំណូលទាប និងប្រជាជនងាយរងគ្រោះ ជំរុញកំណើនសេដ្ឋកិច្ច ស្ថិរភាពសង្គម និងរួមចំណែកដល់កំណើនវិស័យឯកជនប្រកបដោយថាមពល។

---

[63] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០១៥), ៧។

[64] ដូច៦២, ទំព័រ ៥-៦។

### ៣.២.៤. ការបង្កើនការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាយុទ្ធសាស្រ្តសំខាន់ជាងគេដើម្បីសម្រេចបំណង នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ជាពិសេសការអប់រំ គឺជាឧបករណ៍ដ៏ចម្បងមួយដើម្បីបំបែក វដ្តនៃភាពក្រីក្រដែលកើតមានចំពោះប្រជាជននៅតាមជនបទ។[65] ប្រជាជនមានជំនាញ មានគុណតម្លៃ និងមានឥរិយាបទល្អពិតជាមានសារៈសំខាន់ណាស់ដើម្បីបង្កើតផលិតភាពការងារ។ ដូចគ្នានឹងវិស័យដទៃទៀតដែរ ការអភិវឌ្ឍជនបទទាមទារឲ្យមានបច្ចេកវិទ្យាទំនើប។ ប្រជាជនដែលប្រើប្រាស់បច្ចេកវិទ្យាទំនើបបានអាចទទួលបានការងារ និងរកប្រាក់ចំណូលបានល្អប្រសើរមានតែប្រជាពលរដ្ឋដែលមានការអប់រំ និងមានគុណសម្បត្តិគ្រប់គ្រាន់ខាងបច្ចេកទេស។ ដូច្នេះហើយដើម្បីឲ្យប្រជាជនមានការងារធ្វើបាន និងប្រកបដោយចីរភាពចាំបាច់ណាស់តម្រូវឲ្យមានការអភិវឌ្ឍការអប់រំជាពិសេសតំបន់ជនបទ ពីព្រោះប្រព័ន្ធអប់រំនៅតំបន់ជនបទនៅមានកម្រិតខ្សោយនៅឡើយដែលជាហេតុធ្វើឲ្យប្រជាជនងាយបាត់បង់ឱកាសការងារ និងមានការកើនឡើងភាពក្រីក្រ។ ម្យ៉ាងវិញទៀតការអប់រំផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសមានឱកាសច្រើនក្នុងការទទួលបានការងារធ្វើ។

ការបង្កើតភាពងាយស្រួលក្នុងការទទួលបាន និងការអប់រំប្រកបដោយគុណភាពនៅកម្រិតបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងការអភិវឌ្ឍបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពិតជាមានសារៈសំខាន់ណាស់សម្រាប់ជួយឲ្យយុវជនក្មេងៗ ដែលឈានចូលដល់វ័យគ្រប់អាយុធ្វើការជារៀងរាល់ឆ្នាំ និងត្រៀមខ្លួនសម្រាប់ការងារពេញមួយជីវិត។

#### ៣.២.៤.១. ការអប់រំ

##### ក. បឋមសិក្សា

ការអប់រំកម្រិតមូលដ្ឋាន គឺសម្រាប់ទាំងអស់គ្នាដែលជាកម្មវិធីសំខាន់បំផុតក្នុងវិស័យអប់រំ។ ការអប់រំកម្រិតមូលដ្ឋានរួមបញ្ចូល ការសិក្សាអប់រំបឋមសិក្សា ៦ឆ្នាំ និងការសិក្សាមធ្យមសិក្សា បឋមភូមិ ៣ឆ្នាំ។ កម្មវិធីអប់រំនៅកម្រិតមូលដ្ឋាន នឹងបញ្ចប់នៅពេលសិស្សបានចូលរៀនរយៈពេល ៩ឆ្នាំ។ ការអប់រំបឋមសិក្សាជាសាកលត្រូវបានតម្កល់ទុកក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជា។ ការវិនិយោគលើការអប់រំនៅបឋមសិក្សាអាចមានអត្ថប្រយោជន៍យ៉ាងច្រើនរួមបញ្ចូលទាំងផលិតភាពដែលមានអត្រាខ្ពស់ និងមានមូលដ្ឋានសម្រាប់ការសិក្សានៅកម្រិតលើបន្តទៀត។ ការដែលសិស្សឈប់រៀនក្រោយពីបានរៀនចប់ត្រឹមបឋមសិក្សា ឬឈប់កណ្តាល

[65] ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (ភ្នំពេញ, ២០១៥), ៣៧៧។

ទីត្រឹមថ្នាក់ទី១ ឬថ្នាក់ទី៣ គឺជាការព្រួយបារម្ភចំពោះអនាគតនៃបរិមាណធនធានមនុស្សនៅតាមតំបន់ជនបទ។ ក្នុងរយៈពេលម្ភៃឆ្នាំកន្លងមកនេះកម្ពុជាទទួលបានកំណើនខ្ពស់លើអត្រាចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា។ ទោះជាសម្រេចបានលទ្ធផលទាំងនេះក៏ដោយក៏គុណភាព និងប្រសិទ្ធភាពនៃវិស័យអប់រំទាំងមូលនៅតែជាបញ្ហាមួយដែលត្រូវដោះស្រាយ។ អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់នៅតែមានកម្រិតខ្ពស់នៅឡើយនៅក្នុងប្រព័ន្ធអប់រំ។[66]

### ខ. មធ្យមសិក្សា

ការអប់រំនៅមធ្យមសិក្សា ពិសេសមធ្យមសិក្សាទុតិយភូមិបំពេញតួនាទីចន្លោះពីការអប់រំនៅបឋមសិក្សា និងការអប់រំនៅឧត្តមសិក្សា និងទីផ្សារការងារ។ ការអប់រំកម្រិតនេះបានកំណត់ពីឱកាសអប់រំ និងឱកាសការងារនាពេលអនាគតសម្រាប់យុវជនវ័យក្មេង។ ការចូលរៀននៅមធ្យមសិក្សា ជាការកំណត់ពីបរិមាណធនធានមនុស្សដែលមានគុណវុឌ្ឍិ និងជំនាញដែលត្រូវការសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យជោគជ័យ។ បន្ទាប់ពីបញ្ចប់ការអប់រំនៅមធ្យមសិក្សាទុតិយភូមិសិស្សទទួលបានបំណិនផ្នែកអក្សរ និងលេខនព្វន្តជាមូលដ្ឋាន ក៏ដូចជាទទួលបានចំណេះដឹងខ្លឹមសារមុខវិជ្ជា និងបំណិនដែលពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត។ បំណិនទាំងអស់ដែលទទួលបានពីការអប់រំនៅមធ្យមសិក្សាទុតិយភូមិរបស់យុវជនវ័យក្មេង គឺជាអ្វីដែលសហគ្រិននៅក្នុងគ្រប់វិស័យចង់បាន។

### ៣.២.៤.២. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ភាពកង្វះខាតការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានបង្អាក់ការបង្កើនផលិតភាពការងារ។ ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ និងបច្ចេកវិទ្យាក៏កំពុងតែមានការកើនឡើងផងដែរ ដូច្នេះទីផ្សារពលកម្មត្រូវការកម្មករជំនាញក្នុងកម្រិតកណ្តាលជាច្រើនដូចជាជាងម៉ាស៊ីន អ្នកមេការ ជាងអគ្គិសនី ជាងម៉ូទ័រ ជាងជួសជុលម៉ាស៊ីន ជាងកំបោរ និងជាងផ្សេងទៀតជាដើម ប៉ុន្តែប្រជាជន ឬកម្មករមិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការបំពេញការងារ និងម្យ៉ាងទៀតសេចក្តីត្រូវការការងារធ្វើក៏ចេះតែមានការកើនជារៀងរាល់ឆ្នាំនៅកម្ពុជា ជាពិសេសតំបន់ជនបទ។ ឆ្នាំក្រោយៗទៅ យុវជនវ័យក្មេងជាង ២០០.០០០នាក់ តាមសហគមន៍ជនបទនានាប្រហែលនឹងចេះអក្សរ ឬទទួលបានការអប់រំផ្សេងៗហើយភាគច្រើននឹងស្វែងរកការងារធ្វើតាមជម្រើសផ្សេងៗក្រៅពីការងារកសិកម្ម។ ប៉ុន្តែគ្រាន់តែចេះអក្សរ ឬមានសញ្ញាបត្រពីសាលាបឋម

[66] ធនាគារអភិវឌ្ឍន៍អាស៊ី, *ធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា* (ភ្នំពេញ, ២០១២), ២៩។

សិក្សាមិនអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីរកការងារក្រៅពីកសិកម្មដែលបានកម្រៃថ្លៃបានឡើយ។ ដូច្នេះទាមទារឲ្យមានការបណ្តុះបណ្តាលបច្ចេកទេសឲ្យបានច្រើនបន្ថែមទៀត ព្រមទាំងដាក់បញ្ចូលការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរយៈដូចខាងក្រោម៖

១-ការដាក់បញ្ចូលកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមថ្នាក់រៀនដូចជាមធ្យមសិក្សាជាដើម។

២-ចំពោះសិស្សដែលបានឈប់រៀន គឺតម្រូវឲ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ដែលផ្តល់មុខវិជ្ជាផ្សេងៗ តាមតម្រូវការទីផ្សារការងារក្នុងរយៈពីមួយសប្តាហ៍ ដល់ប្រាំមួយខែនៅក្នុងតំបន់ជនបទ។

ដូចបានបង្ហាញខាងលើការអប់រំគ្រប់កម្រិតសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវតែពង្រីកឲ្យទូលំទូលាយតាមតំបន់ ដើម្បីបង្កលក្ខណៈឲ្យអ្នកជនបទអាចរៀនបាន និងមានឱកាសច្រើនក្នុងការរកការងារធ្វើ និងជាឫសគល់នៃការកាត់បន្ថយភាពក្រីក្រផងដែរ។

### ៣.២.៥. ការទាក់ទាញវិនិយោគិន

ការទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅស្រុក ជាការចូលរួមចំណែកមួយផងដែរក្នុងការបង្កើតឲ្យមានឱកាសការងារជាច្រើនសម្រាប់ប្រជាជននៅក្នុងប្រទេសកម្ពុជា ជាពិសេសសម្រាប់ប្រជាជននៅជនបទជាង ៨០% ដែលពឹងផ្អែកលើកសិកម្ម។ ការទាក់ទាញវិនិយោគិនឲ្យមកបណ្តាក់ទុនមាននៅក្នុងវិស័យចម្បងៗដូចជា វិស័យកសិកម្មរួមមានកសិកម្មកែច្នៃ កសិកម្មចិញ្ចឹមសត្វ និងការដាំដំណាំឧស្សាហកម្មជាដើម។ ចំណែកវិស័យឧស្សាហកម្មការវិនិយោគលើវិស័យមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម និងកម្មន្តសាល ព្រមទាំងវិស័យកាត់ដេរ។ បរិយាកាសទូទៅរបស់កម្ពុជាសម្រាប់ទាក់ទាញការវិនិយោគរួមមាន កំណើនសេដ្ឋកិច្ច ស្ថិរភាពនយោបាយ ស្ថាប័នរចនាសម្ព័ន្ធ ទីតាំងភូមិសាស្ត្រ កម្លាំងពលកម្ម និងទីផ្សារខាងក្រៅជាដើម។ ក្រៅពីបរិយាកាសទូទៅ កម្ពុជាមានការលើកទឹកចិត្តការវិនិយោគពីសំណាក់រាជរដ្ឋាភិបាលតាមរយៈវិធានផ្សេងៗ ជាពិសេសច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤ និងបានធ្វើវិសោធនកម្មច្បាប់ម្តងរួចមកហើយក្នុងឆ្នាំ២០០៣ ធ្វើឲ្យប្រសើរឡើងដល់អ្នកវិនិយោគទាំងអស់។

#### ៣.២.៥.១. កត្តាទាក់ទាញវិនិយោគិន

កម្ពុជានារយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ មានបរិយាកាសល្អពោរពេញទៅដោយឱកាសមាសយ៉ាងពិតប្រាកដក្នុងការទាក់ទាញវិនិយោគិនដូចជា៖

១-កំណើនសេដ្ឋកិច្ច៖ កម្ពុជាជាប្រទេសមានកំណើនសេដ្ឋកិច្ចរឹងមាំ ពោលគឺសម្រេចបានជាមធ្យមក្នុងរង្វង់ ៧% ជាងពីរទសវត្សរ៍មកហើយ ដែលធ្វើឲ្យប្រទេសកម្ពុជាបានឆ្លងផុតពីប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងឈានទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

២-ស្ថិរភាពនយោបាយ៖ ប្រទេសកម្ពុជាមានស្ថិរភាពនយោយបាយរឹងមាំ និងមានភាពចាស់ទុំក្នុងឆាកនយោបាយ ដែលបានឆ្លងកាត់ការបោះឆ្នោតជាតិជាច្រើនអាណត្តិរួចមកហើយ អាចឲ្យ វិនិយោគិនទាំងក្នុង និងក្រៅប្រទេសទុកចិត្តក្នុងការបណ្តាក់ទុននៅប្រទេសកម្ពុជា។

៣-កត្តាភូមិសាស្ត្រ៖ កម្ពុជាជាប្រទេសសមាជិក និងស្ថិតនៅចំកណ្តាលបេះដូងនៃបណ្តាប្រទេសអាស៊ានអាចគេចផុតពីគ្រោះមហន្តរាយផ្សេងៗ ដែលអំណោយផលល្អដល់ការវិនិយោគ និងការនាំចេញ ព្រមទាំងមានប្រព័ន្ធអនុគ្រោះពន្ធពីបណ្តាប្រទេសមហាអំណាចអាមេរិក និងសហគមន៍អឺរ៉ុប។

៤-កត្តាប្រជាសាស្ត្រ៖ កម្ពុជាសម្បូរទៅដោយកម្លាំងពលកម្មវ័យក្មេងជាច្រើន ពោលគឺមានប្រជាជនប្រហែល ៦៨% (ជាង ១១លាននាក់) ស្ថិតនៅក្រោមអាយុ ៤០ឆ្នាំ ដែលជាវ័យពេញកម្លាំងពលកម្ម។

៥-កត្តាហេដ្ឋារចនាសម្ព័ន្ធ៖ កម្ពុជាបាននឹងកំពុងកសាងទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ដូចជា ប្រព័ន្ធដឹកជញ្ជូន វិស័យអគ្គិសនី កម្លាំងជំនាញវិជ្ជាជីវៈ ដើម្បីសម្របសម្រួលឲ្យមានលក្ខណៈងាយស្រួលដល់ការវិនិយោគ និងការធ្វើពាណិជ្ជកម្ម។

៦-កត្តាពាក់ព័ន្ធផ្សេងៗ៖ ក្រៅពីកត្តាខាងលើ ក៏មានកត្តាជាច្រើនទៀតដូចជា ភាសាបរទេស រូបិយវត្ថុ(ដុល្លារ) អាកាសធាតុ។ល។[67]

កត្តាខាងលើទាំងអស់ គ្រាន់តែជាផ្នែកមួយក្នុងបរិយាកាសសម្រាប់ទាក់ទាញវិនិយោគិន តែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ទេ ការណ៍សំខាន់ត្រូវមានការលើកទឹកចិត្តការវិនិយោគពីសំណាក់រាជរដ្ឋាភិបាលមួយផ្នែកទៀត។

#### ៣.២.៥.២. ការលើកទឹកចិត្តការវិនិយោគ

រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើតនូវបរិយាកាសមួយ ដែលសម្រួលដល់ការចូលរួមពីសំណាក់វិស័យឯកជន ដើម្បីធ្វើឲ្យប្រសើរឡើង និងសម្របសម្រួលឲ្យមានការវិនិយោគក្នុង និង

[67] ដកស្រង់គេហទំព័រ https://kohsantepheapdaily.com.kh/article/666614.html ចូលទស្សនាថ្ងៃទី ១៧ មិថុនា ២០២០។

ក្រៅស្រុកតាមរយៈការអនុម័តដែលមានល្បឿនលឿន។ ការធ្វើវិសោធនកម្មលើច្បាប់ស្តីពីវិនិយោគឆ្នាំ២០០៣ ផ្តល់អត្ថប្រយោជន៍ដល់អ្នកវិនិយោគដែលមានសិទ្ធិទទួលៈ

១-ការរួចពន្ធរយៈពេល៣ឆ្នាំដោយស្វ័យប្រវត្តិហើយអាចបន្ថែម ៣ឆ្នាំទៀត ដោយចាប់ផ្តើមពីឆ្នាំទី១ដែលអាចរកប្រាក់ចំណេញបាន ឬ៣ឆ្នាំពីចំណូលដំបូង មួយណាក៏បានដែលមានមុនគេ។

២-ការលើកលែងពន្ធនាំចូលសម្រាប់សម្ភារៈសំណង់ គ្រឿងបរិក្ខារផលិតកម្ម និងវត្ថុធាតុដើមសម្រាប់គម្រោងវិនិយោគដើម្បីនាំចេញ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងថាមពល។

៣-ការធានាទប់ទល់នឹងជាតូបនីយកម្ម។

៤-កិច្ចសន្យាជួលដីដែលអាចបន្តថ្មីរហូតដល់រយៈពេល ៩៩ឆ្នាំលើដីសម្បទានសម្រាប់គោលបំណងកសិកម្ម។

៥-ការលើកលែងពន្ធនាំចេញ។

៦-ផ្តល់ការងារឲ្យជនបរទេសសម្រាប់ការងារ ដែលជនជាតិខ្មែរពុំមានសមត្ថភាពធ្វើបាន។

៧-ពុំមានជាតូបនីយកម្ម ដែលជះឥទ្ធិពលអវិជ្ជមានដល់ទ្រព្យសម្បត្តិវិនិយោគិន។

៨-ពុំមានការគ្រប់គ្រងថ្លៃដោយរដ្ឋ លើផលិតផល និងសេវាកម្ម ដែលផលិតដោយគម្រោងវិនិយោគ។

៩-ការផ្ទេររូបិយប័ណ្ណបរទេសទៅក្រៅប្រទេស។

## ៣.៣. ការបង្កើតការងារតាមវិស័យទេសចរណ៍ជនបទ

វិស័យទេសចរណ៍ ជាវិស័យមួយដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជា **មាសបៃតង** ដែលបានគាំទ្រក្នុងកំណើនសេដ្ឋកិច្ចប្រទេសជាតិ បង្កើតការងារ កាត់បន្ថយការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ។ ទេសចរណ៍ ជាឧស្សាហកម្មដែលត្រូវការកម្លាំងពលកម្មច្រើន។ ការផ្តល់សេវាកម្មដល់ភ្ញៀវទេសចរបានបង្កើតការងារជាច្រើនក្នុងវិស័យទេសចរណ៍ ព្រមទាំងជំរុញឲ្យមានការងារបង្កើតការងារនៅក្នុងវិស័យផ្សេងទៀតដូចជា វិស័យសំណង់ និងវិស័យដឹកជញ្ជូន ជាពិសេសវិស័យកសិកម្មដោយបានស្រូបយកកម្លាំងពលកម្មពីការងារតាមរដូវ(ការងារកសិកម្ម)ពោលគឺបានចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិក៏ដូចជាសេដ្ឋកិច្ចជនបទ។

ទេសចរណ៍ជនបទ សំដៅសកម្មភាពធ្វើដំណើរទាំងឡាយណា ដែលមានគោលបំណងស្វែងរកភាពទាក់ទាញនៃធម្មជាតិ និងមនុស្សសាស្រ្តនៅតំបន់ជនបទ។[68] ទេសចរណ៍ជនបទមាន

---

[68] ដកស្រង់គេហទំព័រ http://jfjm100.com/landscape-planning/definition-of-rural-tourism-and-its-types.html ចូលទស្សនាថ្ងៃទី ០៦ មិថុនា ២០២០។

ភាពទាក់ទាញយ៉ាងសម្បូរបែប ដែលរួមបញ្ចូលទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ឬទេសចរណ៍ធម្មជាតិ និងកសិទេសចរណ៍។ ប្រភេទទីមួយនៃទេសចរណ៍ជនបទ គឺទេសចរណ៍វប្បធម៌ដែលសំដៅលើការធ្វើដំណើរកម្សាន្តដែលមានគោលបំណងចម្បងគឺទស្សនាកន្លែងប្រវត្តិសាស្ត្រ និងសកម្មភាពផ្សេងៗដែលតំណាងឲ្យអតីតកាល។ ប្រភេទទីពីរនៃទេសចរណ៍ជនបទ គឺអេកូទេសចរណ៍ ឬទេសចរណ៍ធម្មជាតិដែលសំដៅលើដំណើរនៃការទស្សនាតំបន់ធម្មជាតិដូចជារុក្ខជាតិ និងសត្វព្រៃ។ ប្រភេទទីបីនៃទេសចរណ៍ជនបទគឺកសិទេសចរណ៍ ជាសកម្មភាពនៃការទស្សនាសកម្មភាពក្នុងកសិដ្ឋាន ឬកសិកម្ម សាកវប្បកម្ម និងកសិ-ពាណិជ្ជកម្មក្នុងគោលបំណងទស្សនាកម្សាន្ត។[69]

### ៣.៣.១. ការអភិវឌ្ឍតំបន់សហគមន៍អេកូទេសចរណ៍

ភ្ញៀវទេសចរភាគច្រើន តម្រង់គោលដៅទៅកម្សាន្តនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងតំបន់ឆ្នេរសមុទ្រ ដែលជាបណ្តុំនៃសេដ្ឋកិច្ច នយោបាយ និងវប្បធម៌របស់កម្ពុជា ប៉ុន្តែសក្តានុពលវិស័យទេសចរណ៍មិនមែនមានតែត្រឹមប៉ុណ្ណោះទេ ក៏មានផងដែរតំបន់សហគមន៍អេកូទេសចរណ៍ ឬតំបន់ទេសចរណ៍ធម្មជាតិ ដែលមាននៅរាយប៉ាយនៅទូទាំងប្រទេសកម្ពុជា ដែលមិនទាន់មានសន្ទុះខ្លាំងក្លានៅឡើយ។ អេកូទេសចរណ៍ ជាប្រភេទទេសចរណ៍ដែលធ្វើសកម្មភាពជាមួយធម្មជាតិដូចជាសម្រាកលំហែ ហើយភាគច្រើននៃអ្នកទេសចរជាអ្នកស្រឡាញ់ធម្មជាតិ បរិស្ថាន និងចូលរួមថែរក្សាធម្មជាតិ។ កាលពីឆ្នាំ២០១៦ កម្ពុជាមានសហគមន៍អេកូទេសចរណ៍ និងតំបន់អេកូទេសចរណ៍តែ ៥៦កន្លែង និងទទួលបានភ្ញៀវទេសចរបរទេសតែជាង ៦ម៉ឺននាក់ប៉ុណ្ណោះដែលបានទៅលេងកម្សាន្តនៅតំបន់សហគមន៍អេកូទេសចរណ៍ទាំងនោះ។ ក្នុងសកម្មភាពទេសចរណ៍របៀបនេះ ប្រជាពលរដ្ឋនៅតាមសហគមន៍ទទួលបានចំណូលតាមរយៈការទទួលភ្ញៀវទេសចរឲ្យស្នាក់នៅ ចម្អិនម្ហូបអាហារឲ្យភ្ញៀវទេសចរ ការលក់វត្ថុអនុស្សាវរីយ៍ និងជូនភ្ញៀវទេសចរទស្សនា ធម្មជាតិជាដើម។ តំបន់សក្តានុពលអេកូទេសចរណ៍ជាអាទិ៍ ព្រៃភ្នំ ព្រៃព្រឹក្សា ទឹកជ្រោះ ធម្មជាតិ សត្វព្រៃ ព្រមទាំងជីវៈចម្រុះដ៏ច្រើនសន្ធឹកសន្ធាប់មាននៅខេត្តចំនួន ៨ក្នុងភូមិភាគឦសាន ខេត្តចំនួន ៤នៅតំបន់មាត់សមុទ្រ និងខេត្ត ៦ផ្សេងទៀតនៅជុំវិញបឹងទន្លេសាប ប៉ុន្តែសហគមន៍អេកូទេសចរណ៍ និងតំបន់អេកូទេសចរណ៍ទាំងនោះមានតិចតួចណាស់ដែលត្រូវបានផ្សព្វផ្សាយ និងរៀបចំបានស្រួលបួល។ ចំណែកតំបន់មួយចំនួនធំទៀតមិនទាន់មានលក្ខណៈជា

[69] Humaira Irshad, *Rural Tourism* [ទេសចរណ៍ជនបទ] (២០១០), ៦, https://www1.agric.gov.ab.ca/$Department/deptdocs.nsf/all/csi13476/$FILE/Rural-Tourism.pdf ចតចម្លងថ្ងៃទី ០៦ មិថុនា ២០២០។

កន្លែងទេសចរណ៍នៅឡើយ ហើយក៏មិនសូវមានដៃរអ្នកទេសចរដែលស្គាល់ និងទៅលេងកម្សាន្ត ដល់ទីកន្លែងនោះ។ ការរៀបចំ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីសហគមន៍អេកូទេសចរណ៍ និងតំបន់អេកូទេសចរណ៍មិនត្រឹមតែបង្កើតឱកាសការងារ និងប្រាក់ចំណូលជូនប្រជាពលរដ្ឋ ប៉ុណ្ណោះទេ វាក៏អាចចូលរួមចំណែកថែរក្សាធនធានធម្មជាតិបានប្រកបដោយប្រសិទ្ធភាពផងដែរ។ ប្រជាពលរដ្ឋនៅជនបទដែលទទួលបានចំណូលពីសកម្មភាពទេសចរណ៍ ជាទូទៅលែងធ្វើការ ចំណាកស្រុក និងបញ្ឈប់រាល់ទង្វើបំផ្លាញធនធានធម្មជាតិ។

### ៣.៣.២. ការបង្កើតតំបន់កសិទេសចរណ៍

កសិទេសចរណ៍ភាគច្រើនមាននៅតាមកសិដ្ឋាន ដែលគេនាំភ្ញៀវទេសចរទៅទស្សនា កម្សាន្តកន្លែងកសិដ្ឋានចិញ្ចឹមសត្វ សួនបន្លែ ចម្ការដាំណាំផ្សេងៗ ជាពិសេសចម្ការម្រេច ទំពាំង បាយជូរ។ អ្នកទេសចរអាចចូលរួមសកម្មភាពផ្សេងៗ ដែលរៀបចំដោយកសិដ្ឋាន ឬទិញ ផលិតផលកសិកម្មទាំងនោះជាដើម។[70] កសិទេសចរណ៍ ជាការរួមបញ្ចូលគ្នារវាងទេសចរណ៍ និង កសិកម្មក្នុងគំរូច្នៃប្រឌិតនៃការអភិវឌ្ឍតំបន់មួយ ដោយបានរួមចំណែកក្នុងការលើកកម្ពស់វិស័យ កសិកម្ម និងសម្រេចបាននូវសេដ្ឋកិច្ច កសិកម្មចម្រុះនៅតាមតំបន់ជនបទ និងជាផ្នែកសំខាន់មួយ នៃការធ្វើឲ្យប្រសើរឡើងឧស្សាហកម្មទេសចរណ៍។ មិនខុសគ្នាពីតំបន់សហគមន៍អេកូទេសចរណ៍ ការបង្កើតតំបន់កសិទេសចរណ៍ ក៏មានតួនាទីក្នុងការបង្កើតប្រាក់ចំណូលបន្ថែមលើប្រជាជននៅ ជនបទដែរ។ តំបន់ជនបទរបស់កម្ពុជា ជាតំបន់មានសក្តានុពលយ៉ាងធំធេងដើម្បីបង្កើតតំបន់ កសិទេសចរណ៍ ដោយសារអាកាសធាតុក្តៅ ហើយសើម របស់កម្ពុជាជាលក្ខណៈមួយអំណោយ ផលដល់ដំណាំកសិកម្មគ្រប់ប្រភេទ។ កសិករគ្រាន់តែធ្វើកសិកម្មដូចជា ដាំផ្កា ដាំបន្លែជាសួន ចិញ្ចឹមសត្វ និងចម្ការដំណាំកៅស៊ូ ម្រេច ទំពាំងបាយជូរជាដើម និងរៀបចំឲ្យទៅជាកន្លែង ទេសចរណ៍កសិកម្ម។ ទោះបីជាកម្ពុជាមានលក្ខណៈអំណោយផលច្រើនដល់កសិទេសចរណ៍ក៏ ដោយក៏កសិទេសចរណ៍នៅទូទាំងប្រទេសមានបរិមាណតិចតួចនៅឡើយ។ ភ្ញៀវទេសចរដែល មកទស្សនាកសិទេសចរណ៍ភាគច្រើនជាភ្ញៀវទេសចរបរទេស និងមិនមានភាពទូលំទូលាយ ចំពោះភ្ញៀវក្នុងស្រុក។ ការទស្សនាតំបន់កសិទេសចរណ៍ ភ្ញៀវទេសចរនឹងបានឃើញនូវទិដ្ឋភាព គួរឲ្យចាប់អារម្មណ៍យ៉ាងច្រើននៃជីវិតពិតរបស់ប្រជាកសិករនៅតាមជនបទ ដោយភ្ជាប់ជាមួយ កសិកម្ម។

[70] អឿន លក្ខិណា និង រន កុសមា, "ជំរុញការអភិវឌ្ឍកសិទេសចរណ៍", (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧), ១៧។

ការអភិវឌ្ឍកសិទេសចរណ៍បានល្អប្រសើរនៅតំបន់ជនបទ ជាការរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជនបទ ពិពិធកម្មប្រាក់ចំណូលរបស់ប្រជាជននៅជនបទ និងបង្កើតឱកាសការងារទាំងផ្ទាល់ និងប្រយោលផងដែរ។

### ៣.៣.៣. ការបង្កើតរមនីយដ្ឋានទេសចរណ៍កែច្នៃ

រមនីយដ្ឋានទេសចរណ៍កែច្នៃបែបធម្មជាតិកំពុងតែពេញនិយម និងកំពុងទាក់ទាញភ្ញៀវទេសចរបរទេស និងភ្ញៀវទេសចរដែលរស់នៅទីក្រុងទៅទស្សនាកម្សាន្តក្នុងពេលសម្រាកកាយរបស់ពួកគេ។ រមនីយដ្ឋានទេសចរណ៍កែច្នៃ មិនត្រឹមតែផ្តល់ភាពរីករាយដល់ភ្ញៀវទេសចរប៉ុណ្ណោះទេ តែថែមទាំងជួយលើកកម្ពស់ជីវភាពប្រជាជននៅជនបទ និងបង្កើតការងារទាំងផ្ទាល់ និងប្រយោល។ រមនីយដ្ឋានទេសចរណ៍កែច្នៃ ជាការកែប្រែតំបន់ធនធានធម្មជាតិដែលមានស្រាប់ក្នុងតំបន់ជនបទដូចជាបឹង ព្រៃក ដងស្ទឹង ទឹកធ្លាក់ជ្រលងដងអូរ ព្រៃកោងកាង ព្រៃភ្នំព្រឹក្សាជាដើមឲ្យទៅជាតំបន់សក្តានុពលទេសចរណ៍ដែលមានទេសភាពស្រស់បំព្រង និងប្រកបដោយភាពទាក់ទាញភ្ញៀវទេសចរ។ ទេសចរណ៍កែច្នៃរីកចម្រើន ត្រូវមានការចូលរួមពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវជនបទ ទឹកស្អាត និងអគ្គិសនីផងដែរ។

ការបង្កើត និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មី គឺជាកត្តាចាំបាច់ដើម្បីគាំទ្រផង និងដោះស្រាយផងជាមួយនឹងផលិតផលដែលមានស្រាប់ ព្រមទាំងបំពេញយុទ្ធសាស្ត្រស្តីពីការផ្តល់ជម្រើសឱកាសទស្សនារបស់ភ្ញៀវឲ្យបានច្រើន និងពន្យាពេលស្នាក់នៅ ការចំណាយរបស់ភ្ញៀវដើម្បីជំរុញការងារ។ ការពឹងផ្អែកតែលើភាពល្បីល្បាញនៃតំបន់អង្គរ ឬរាជធានីភ្នំពេញមួយមុខមិនគ្រប់គ្រាន់ឡើយ។ តំបន់អង្គរដែលមានភ្ញៀវទេសចរប្រមាណ ២លាននាក់ទស្សនាក្នុងមួយឆ្នាំៗកាន់តែដាក់សម្ពាធខ្លាំងឡើងៗទាំងបរិស្ថាន និងវប្បធម៌ ហើយរយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរក៏មិនបានយូរប៉ុន្មានឡើយ។

### ៣.៣.៤. ការងារក្នុងវិស័យទេសចរណ៍ជនបទ

ទេសចរណ៍ជនបទ ជាស្ថានភាពមួយដែលតំបន់ជនបទផ្តល់ឲ្យ។ ទេសចរណ៍ជនបទត្រូវបានគេឃើញថាបានក្លាយជាប្រភពចំណូលដ៏សំខាន់សម្រាប់សហគមន៍ជនបទ។ សកម្មភាពការងារជាច្រើនក្នុងទេសចរណ៍ជនបទ មិនទាមទារការបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់ដល់ប្រជាជនដោយគ្រាន់តែបណ្តុះបណ្តាលបន្តិចបន្តួចលើការអភិវឌ្ឍជំនាញវិជ្ជាជីវៈនៃការផ្តល់សេវាកម្ម។ ជាការពិតណាស់ វិស័យទេសចរណ៍បានផ្តល់ការងារជូនប្រជាជនជនបទប្រមាណ ២៦,៣% (ប្រហែល១,៧៩លាននាក់) នៃប្រជាជនជនបទសរុប(កសិកម្ម ៨៦,៥% ឧស្សាហកម្ម ២៧,២%)

នៅឆ្នាំ២០១៧។ ការងារដែលបានបង្កើតដោយវិស័យនេះមានចំពោះស្ត្រីច្រើនជាងបុរស ពោលគឺ ស្ត្រី ២៦,៧% (៨៩៩ពាន់នាក់) និងបុរស ២៥,៨% (៨៥១ពាន់នាក់)។

គោលបំណងចម្បងរបស់ទេសចរណ៍ជនបទ ដើម្បីបង្កើតគំរូសហគមន៍ទេសចរណ៍ជនបទ ដោយធ្វើឲ្យជីវភាពរស់នៅរបស់សហគមន៍ប្រសើរឡើងប្រកបដោយចីរភាពក្នុងទិសដៅអភិរក្ស និងការអភិវឌ្ឍធនធានក្នុងស្រុក។ ប្រភពចំណូលផ្តល់ដោយទេសចរណ៍ជនបទមានដូចខាងក្រោម៖

ការងារដោយការលក់ផលិតផលកសិកម្ម និងសិប្បកម្ម៖ ប្រជាជនជនបទទទួលបានការងារជាច្រើនតាមរយៈការលក់ផលិតផលកសិកម្ម ផលិតកម្មសត្វផ្សេងៗ។ ទេសចរណ៍ជនបទផ្តល់ឱកាសដ៏ល្អដល់សិប្បករក្នុងការតាំងបង្ហាញ និងលក់ផលិតផលសិប្បកម្មដែលបង្ហាញពីវប្បធម៌ និងកេរ្តិ៍ដំណែលទៅកាន់អ្នកទេសចរ។ ម្យ៉ាងទៀតវត្ថុដែលអ្នកទេសចរទិញភាគច្រើនជាផលិតផលសិប្បកម្មមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ការចំណាយរបស់អ្នកទេសចរបានបង្កើតការងារដោយផ្ទាល់ក្នុងវិស័យទេសចរណ៍ និងបង្កើតការងារដោយប្រយោលក្នុងសណ្ឋាគារ។ ការបង្កើតការងារដោយប្រយោល ជាការបង្កើតការងារក្នុងវិស័យផ្សេងតាមរយៈតម្រូវការទំនិញ និងសេវាកម្ម។

ការងារតាមរយៈអាជីវកម្មជនបទ៖ ទេសចរណ៍ជនបទមានឥទ្ធិពលដ៏ច្រើនទៅលើសេដ្ឋកិច្ចជនបទ។ ក្រៅពីផលិតផលទេសចរណ៍ ឱកាសការងារជាច្រើនសម្រាប់ប្រជាជនត្រូវបានបង្កើតឡើងដូចជា កន្លែងស្នាក់នៅ ភោជនីយដ្ឋាន ហាងលក់ទំនិញ។ល។

ផ្តល់ឱកាសការងារដល់ស្ត្រី៖ មួយក្នុងចំណោមទិដ្ឋភាពនៃទេសចរណ៍ជនបទ គឺតួនាទីរបស់ស្ត្រីក្នុងសង្គម។ ការលើកកម្ពស់ និងការផ្តល់ឱកាសការងារស្ត្រីជនបទធ្វើឲ្យពួកគេក្លាយជាប្រជាជនដែលមានផលិតភាពក្នុងសេដ្ឋកិច្ច ជាគោលដៅចម្បងនៃទេសចរណ៍ជនបទ ពីព្រោះទេសចរណ៍ជនបទបានផ្តល់ឱកាសឲ្យស្ត្រីក្នុងការបង្កើតប្រាក់ចំណូល។ ស្ត្រីទទួលបានឱកាសការងារតាមរយៈការងារក្នុងភោជនីយដ្ឋាន ការងារតម្បាញ ការងារការថែទាំសុខភាពជាដើម។

ការដឹកជញ្ជូន៖ គ្រប់ទម្រង់ការដឹកជញ្ជូនអ្នកទេសចរ ជាការបង្កើតការងារ និងទទួលបានចំណូលមួយផងដែរ។

មគ្គុទ្ទេសក៍៖ ជាផ្នែកមួយនៃទេសចរណ៍។ ការងារសម្រាប់យុវជនជាមគ្គុទ្ទេសក៍បាននឹងកំពុងផ្តល់ការងារដល់អ្នកគ្មានការងារបានមួយចំនួនធំ។

# ជំពូកទី៤

# ការសិក្សាលើចំណុចខ្លាំង

# បញ្ហាប្រឈម

# និងដំណោះស្រាយ

# ជំពូកទី៤

# ការសិក្សាលើចំណុចខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ

## ៤.១. ចំណុចខ្លាំង

លក្ខណៈប្រជាសាស្ត្រនៃប្រទេសកម្ពុជាពេលបច្ចុប្បន្ន គឺមានប្រជាជនវ័យកម្លាំងពលកម្មច្រើន។ នៅឆ្នាំ១៩៩៨ ប្រជាជនអាយុក្រោម ១៥ឆ្នាំមាន ៤២,៨% បានថយចុះគួរឲ្យកត់សម្គាល់មក ២៨,៧% ឆ្នាំ២០១៦ ហើយព្យាករណ៍ថានឹងថយមកនៅ ២៥,៩% នៅឆ្នាំ២០២៨។ ប្រជាជនក្នុងវ័យធ្វើការ(១៥-៦៤ឆ្នាំ) បានកើនឡើងពី ៥៣,៧% ទៅ ៦២% អំឡុងពេល ១៩៩៨-២០០៨ ហើយអាចកើនឡើងដល់ ៦៧,៣% នៅឆ្នាំ២០២៨។[71] ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុពីវ័យក្មេងទៅវ័យធ្វើការ និងអត្រាកំណើនមនុស្សក្នុងវ័យធ្វើការនៅមានកម្រិតខ្ពស់ជាងអត្រាកំណើនប្រជាជនសរុបបានផ្តល់ជាកាលានុវត្តភាពសម្រាប់កម្ពុជា។ កម្លាំងពលកម្មវ័យក្មេងទាំងអស់នេះភាគច្រើននៅជនបទ ជាសក្តានុពលដល់កម្ពុជាទទួលបានប្រយោជន៍សេដ្ឋកិច្ច ប្រសិនបើមានការវិនិយោគលើការអប់រំ និងសុខភាពបានគ្រប់គ្រាន់។ មួយវិញទៀត លក្ខណៈអំណោយផលពីធម្មជាតិ ដែលសម្បូរដោយធនធាន ពិសេសធនធានព្រៃឈើ ធនធានរ៉ែក្រោមដី ទឹកសាប ទឹកប្រៃ និងបរិមាណដីធ្លីក៏នៅមានច្រើនដែលមិនទាន់អភិវឌ្ឍន៍។ ទន្លេមេគង្គ ទន្លេសាប និងដៃទន្លេ ស្ទឹងនានា ផ្តល់នូវប្រភពទឹកដ៏ច្រើនលើសលុបដែលចាំបាច់សម្រាប់ការដាំដុះនៅរដូវប្រាំង ជាប្រភពក្នុងការទាញយកថាមពលអគ្គិសនី(វារីអគ្គិសនី) និងជាប្រភពសម្រាប់យកទៅអភិវឌ្ឍន៍វិស័យផ្សេងទៀតដូចជាទេសចរណ៍ ឧស្សាហកម្ម។ល។ ចំណែកសកម្មភាពកសិឧស្សាហកម្មនៅជនបទកំពុងតែអភិវឌ្ឍន៍ដែលតម្រូវឲ្យមានការចូលរួមអភិវឌ្ឍន៍ដើម្បីបង្កើតសក្តានុពលបន្ថែមទៀត និងជាជំហានសំខាន់សម្រាប់បង្កើតការងារនៅជនបទ។

## ៤.២. បញ្ហាប្រឈម

### ៤.២.១. បញ្ហាប្រឈមការបង្កើតការងារនៅជនបទក្នុងវិស័យកសិកម្ម

#### ៤.២.១.១. កង្វះដី

ដី គឺជាបញ្ហាចម្បងក្នុងការបង្អាក់ចង្វាក់ការងាររបស់ប្រជាកសិករក្នុងការផលិតកសិកម្ម។ ការកើនឡើងអ្នកដែលគ្មានដី ហើយអ្នកដែលខ្វះខាតដីក្នុងចំណោមប្រជាជនក្រីក្រនៅជនបទមានការកើនឡើង។ គ្រួសារដែលមានកម្មសិទ្ធិផ្ទៃដីដាំដុះតិចជាង ១ហិកតា បានកើនឡើងពី ៥៦%

[71] ក្រសួងអប់រំ យុវជន និងកីឡា, *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០* (ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩), ៦។

(ឆ្នាំ២០០៩) ដល់ ៧៣% (ឆ្នាំ២០១១)។ គ្រួសារកសិករខ្លះបានលក់ដីរបស់ខ្លួន ពីព្រោះទំហំដីគ្មានលក្ខណៈសេដ្ឋកិច្ច និងបូករួមជាមួយទំហំដីតូចហើយការដាំដុះផលិតផលក៏បានតិចផងដែរ ដែលជាហេតុទៅរកការងារក្រៅពីវិស័យកសិកម្ម ទាំងនេះសបញ្ជាក់ថាបញ្ហាកង្វះដីបានធ្វើឲ្យបាត់បង់ឱកាសការងាររបស់ប្រជាជនក្នុងវិស័យកសិកម្ម។

**៤.២.១.២. បញ្ហាទីផ្សារ**

ទីផ្សារកសិកម្ម គឺបានដើរតួនាទីសំខាន់ណាស់សម្រាប់ប្រជាកសិករនៅជនបទ ប៉ុន្តែក៏មានបញ្ហាមួយចំនួនដែលបានបង្អាក់ដំណើរការផលិតកម្មកសិកម្មរបស់ប្រជាកសិករ។ កសិករភាគច្រើនតែងតែជួបបញ្ហាដូចជា៖

- ការលក់ផលដំណាំរបស់កសិករទទួលតម្លៃទាបក្នុងទីផ្សារ៖ បញ្ហានេះបានធ្វើឲ្យកសិករជួបការលំបាកយ៉ាងខ្លាំងក្រោយពីបានធ្វើការដាំដុះដំណាំ ឬការចិញ្ចឹមសត្វជាដើម កសិករខ្លះគាត់បានខ្ចីដើមទុនគេមកធ្វើកសិកម្ម ដោយពួកគាត់មានការរំពឹងទុកពីការទទួលបានតម្លៃសមរម្យ ឬក៏ខ្ពស់ពីការទទួលទិន្នផល តែបើតម្លៃក្នុងទីផ្សារទាប ធ្វើឲ្យមានការខាតបង់ជាដើម។
- ការចំណាយថ្លៃដើមខ្ពស់ក្នុងការផលិត៖ ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វនៅមានកម្រិតទាបនៅឡើយ ដែលប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ ម្យ៉ាងវិញទៀត ធាតុចូលកសិកម្ម ពិសេសជីគីមី ថ្នាំកសិកម្ម ចំណីសត្វ ថ្នាំព្យាបាលសត្វជាដើម ត្រូវបាននាំចូលពីបរទេស ដោយសារឧស្សាហកម្មក្នុងស្រុកគ្មានការផលិត ម្យ៉ាងទៀតផ្នែកនេះមិនទាន់មានការរីកចម្រើនគ្រប់គ្រាន់នៅឡើយ ដែលធ្វើឲ្យថ្លៃដើមខ្ពស់។
- កង្វះខាតព័ត៌មានក្នុងទីផ្សារ៖ នេះបើយោងតាមការអង្កេតរបស់ EIC បានឲ្យដឹងថាមានកសិករតែ ១០% ប៉ុណ្ណោះដែលទទួលបានព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

ទាំងនេះជាបញ្ហាក្នុងទីផ្សារកសិកម្ម ហើយបញ្ហាតម្លៃទីផ្សារឡើងចុះ ដែលមិនអាចកំណត់បាន ជាពិសេសពេលប្រមូលផល តម្លៃផលិតផលបែរជាមានតម្លៃថោក ដែលជាឧបសគ្គដ៏ធំក្នុងការធ្វើឲ្យកសិកម្មមានភាពរីកចម្រើនទៅមុខ។

**៤.២.១.៣. ការប្រែប្រួលអាកាសធាតុ**

ការប្រែប្រួលអាកាសធាតុ ជាកត្តាដែលនាំឲ្យពិបាកដល់ប្រជាកសិករនៅតំបន់ជនបទ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើកម្ពុជា ជាពិសេសផលិតផលកសិកម្ម ដែលធ្វើឲ្យ

ជះឥទ្ធិពលអវិជ្ជមានមកលើផលិតកម្មស្បៀង និងសន្តិសុខស្បៀងនៅតាមជនបទ។ ការប្រែប្រួលអាកាសធាតុកំពុងគំរាមកំហែង ដែលអាចធ្វើឲ្យខូចសមិទ្ធផលនៃកសិកម្មនៅជនបទដែលប៉ះពាល់ការងារជាច្រើនរបស់ប្រជាកសិករ។ បញ្ហាទាំងនេះរួមមាន របាយទឹកភ្លៀង ទឹកជំនន់ ភាពរាំងស្ងួត ជីជាតិដី កត្តាសត្វល្អិតចង្រៃ និងជំងឺដែលបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ផលិតកម្មកសិកម្ម។ ក្នុងចំណោមការប្រែប្រួលអាកាសធាតុទាំងនេះ កសិករមានការព្រួយបារម្ភខ្លាំងអំពីផលប៉ះពាល់នៃគ្រោះរាំងស្ងួត ដែលកើតមានកាន់តែញឹកញាប់ និងអូសបន្លាយពេលកាន់តែវែង ព្រមទាំងការបំផ្លាញដោយទឹកជំនន់កាន់តែខ្លាំងឡើង។ មុខសញ្ញាគ្រោះថ្នាក់នៃអាកាសធាតុទាំងនេះបន្តធ្វើឲ្យគ្រួសារបាត់បង់ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ ជាពិសេសបាត់បង់ការងារនៅក្នុងវិស័យកសិកម្មថែមទៀត។

### ៤.២.២. កង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ភាពកង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាឧបសគ្គដ៏ធំធេងនៅក្នុងការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ជាពិសេសបង្អាក់ភាពរីកលូតលាស់នៃវិស័យជនបទក្នុងការលើកកម្ពស់ជីវភាពប្រជាជន ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតឲ្យមានឱកាសការងារក្នុងគ្រប់សកម្មភាពសេដ្ឋកិច្ចជាច្រើនទាំងក្នុងវិស័យកសិកម្ម និងវិស័យមិនមែនកសិកម្ម។ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងប្រទេស ជាពិសេសនៅតំបន់ជនបទទាមទារឲ្យមានការអភិវឌ្ឍ និងធ្វើការវិនិយោគបន្ថែមទៀតដើម្បីចូលរួមក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការនៃផលិតកម្មនានា ក៏ដូចជាធានាបាននូវខ្សែចង្វាក់ផលិតកម្មនៃការផ្គត់ផ្គង់ដែលអាចទទួលយកបាន និងរហ័សទាន់ពេលវេលា។

#### ៤.២.២.១. ប្រព័ន្ធធារាសាស្ត្រ

ប្រព័ន្ធធារាសាស្ត្រនិងការគ្រប់គ្រងធនធានទឹកមានសារៈសំខាន់ណាស់សម្រាប់ផលិតកម្មពិពិធកម្មដំណាំកសិកម្ម និងវិស័យដទៃទៀតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះហើយក្នុងនោះដែរ ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកត្រូវបានយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្តារ និងកសាងបន្ថែម ដោយបានដាក់បញ្ចូលជាវិស័យអាទិភាពទាំង៤ (ទឹក ភ្លើង ផ្លូវ និងមនុស្ស) ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ។ ទន្ទឹមគ្នានេះ ប្រព័ន្ធធារាសាស្ត្រកម្ពុជានៅតែជាបញ្ហាប្រឈម និងកង្វះខាតនៅពេលមានការប្រែប្រួលអាកាសធាតុ កសិករតែងតែជួបប្រទះនូវបញ្ហាកង្វះខាតទឹកនៅរដូវប្រាំង និងកូនរដូវប្រាំងនៅក្នុងរដូវវស្សា និងបញ្ហាផ្សេងទៀតដូចជា ទឹកជំនន់ជន់លិចដំណាំរបស់កសិករដោយសារតែប្រព័ន្ធធារាសាស្ត្រសម្រាប់រំដោះទឹកនៅមានកម្រិត។ បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ៖

- ការផ្តល់ថវិកាលើការងារស្តារ និងការកសាងប្រព័ន្ធធារាសាស្ត្រមានការយឺតយ៉ាវ និងនៅមានកម្រិតដែលមិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។
- ការចូលរួមរបស់កសិករលើការងារសាងសង់ ការគ្រប់គ្រង ការប្រើប្រាស់ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធរំដោះទឹក ទំនប់ការងារទឹកជំនន់នៅមានកម្រិត។

**៤.២.២.២. ផ្លូវជនបទ**

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសផ្លូវជនបទ ជាការចូលរួមដោយផ្ទាល់ផង និងដោយប្រយោលផងក្នុងការអភិវឌ្ឍតំបន់ជនបទ ក៏ដូចជាការបង្កើតការងារដោយយកចិត្តទុកដាក់ពីក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ និងដោយមានការចូលរួមពីសំណាក់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាតែទោះជាយ៉ាងណាភាពកង្វះខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសផ្លូវជនបទនៅតែជាកម្មវត្ថុចម្បង។

- ថវិកាសម្រាប់យកទៅអភិវឌ្ឍន៍ជនបទនៅមានកម្រិតនៅឡើយ សម្រាប់ការ ស្ថាបនាសាងសង់ផ្លូវជនបទដែលជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនជនបទទូទាំងប្រទេស។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ នៅមិនទាន់ឆ្លើយតបពេញលេញទៅនឹងសេចក្តីត្រូវការនៅឡើយ ហើយការថែទាំ និងការប្រើប្រាស់ផ្លូវជនបទដែលមានស្រាប់ ក៏មិនទាន់បានដោះស្រាយបានល្អដែរ។
- ការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់សាងសង់ផ្លូវជនបទ និងសំណង់សិល្បការ្យកំពុងចោទឡើងច្រើនជាបញ្ហា។
- ការប្រែប្រួលអាកាសធាតុ និងការមិនចូលរួមថែទាំរបស់ប្រជាជននៅជនបទក៏រួមចំណែកក្នុងការធ្វើឲ្យផ្លូវជនបទឆាប់ខូចខាតផងដែរ។

**៤.២.២.៣. អគ្គិសនី**

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅសំខាន់ៗដូចជា ធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងតាមថ្លៃសមល្មម ធានាការផ្គត់ផ្គង់អគ្គិសនីគួរឲ្យទុកចិត្ត និងសុវត្ថិភាព និងលើកកម្ពស់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការផ្គត់ផ្គង់អគ្គិសនីនៅតែមានបញ្ហាប្រឈមដូចជា៖

- វត្ថុធាតុដើមសម្រាប់ផលិតអគ្គិសនីដូចជាប្រេងឥន្ធនៈ និងធ្យូងថ្មឡើងថ្លៃជាបន្តបន្ទាប់ដោយឡែកប្រភពថាមពលអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម និងប្រទេសថៃក៏ឡើងថ្លៃជារៀងរាល់ឆ្នាំ។

- ការផ្តល់អនុភាពអគ្គិសនីមិនគ្រប់តាមទំហំកំណត់ ក្នុងកិច្ចព្រមព្រៀងទិញលក់ថាមពលអគ្គិសនីរបស់វៀតណាម។
- កង្វះខាតធនធានមនុស្សសម្រាប់គ្រប់គ្រងការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ព្រោះសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីនៅមានកម្រិត។
- មិនមានកញ្ចប់ថវិកាសម្រាប់ប្រមូលទិន្នន័យថាមពល ដើម្បីព្យាករណ៍តម្រូវការថាមពល និងស្ថិតិថាមពល។
- ការផ្គត់ផ្គង់ថាមពលអគ្គិសនីមិនទាន់តម្រូវការ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ (ឡើងកម្តៅ) ធ្វើការប្រើប្រាស់ថាមពលអគ្គិសនីកើនឡើង។

### ៤.២.៣. បញ្ហាប្រឈមក្នុងវិស័យមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម

MSMEs បានដើរតួក្នុងការជំរុញកំណើនសេដ្ឋកិច្ច ទោះជាយ៉ាងណាវិស័យនេះមានបញ្ហាប្រឈមមួយចំនួនត្រូវការដោះស្រាយពីគ្រប់ភាគីពាក់ព័ន្ធ។ បញ្ហាប្រឈមទាំងនោះរួមមាន៖

- **ការចុះបញ្ជីប្រើរយៈពេលយូរ និងមានតម្លៃខ្ពស់**

មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមប្រឈមនឹងបរិយាកាសច្បាប់ បទបញ្ញត្តិដ៏ស្មុគស្មាញ និងប្រើពេលវេលាយូរ និងចំណាយថវិកាច្រើនក្នុងការចុះបញ្ជី។ ដូច្នេះសហគ្រាសទាំងនោះមួយចំនួនធ្វើប្រតិបត្តិការដោយពុំមានការចុះបញ្ជី។ ទោះ MSMEs បានចុះបញ្ជីក្តី មិនបានចុះបញ្ជីក្តី ស្ថិតនៅក្រោមការប្រកួតប្រជែងដណ្តើមអតិថិជនជាមួយគ្នា។ ចំពោះ MSMEs បានចុះបញ្ជីហើយគឺជារឿងមិនស្មើភាពក្នុងការប្រកួតប្រជែង។

- **កង្វះខាតគោលនយោបាយគ្រប់គ្រង និងទីផ្សារច្បាស់លាស់**

រាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់មានស្ថាប័នណាមួយច្បាស់លាស់ទេ សម្រាប់គ្រប់គ្រង MSMEs បើទោះបីបានបង្កើតអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យមបានបង្កើតក៏ពិតមែន តែសិទ្ធិអំណាចក្នុងការបំពេញការងារ ហាក់ដូចជាមានដែនកំណត់ទាំងធនធានមនុស្ស ទាំងធនធានសម្ភារៈ ព្រោះគ្រាន់ជាផ្នែកមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មប៉ុណ្ណោះ។ ផែនការយុទ្ធសាស្ត្រដោយឡែកសម្រាប់ MSMEs មិនទាន់មានទេ តែមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មជារួម ហើយមានផ្នែកខ្លះសម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមប៉ុណ្ណោះ។ ក្រសួងជំនាញផ្សេងទៀត មានផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍសម្រាប់អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមរៀងខ្លួន។ ដោយសារការគ្រប់គ្រង MSMEs មិនទាន់មានភាពច្បាស់លាស់ MSMEs ភាគច្រើនអាចបញ្ចូលទំនិញរបស់ខ្លួនបានត្រឹមទីផ្សារក្នុងស្រុកប៉ុណ្ណោះ។

- **លទ្ធភាពទទួលបានហិរញ្ញវត្ថុ**

បើទោះបីវិស័យហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាក៏ដោយ តែ MSMEs នៅតែមានឧបសគ្គក្នុងការទទួលបានហិរញ្ញវត្ថុសម្រាប់ជាដើមទុន ឬសម្រាប់ពង្រីកប្រតិបត្តិការ ដោយសារមិនមានហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចព្រមព្រៀងកម្ចីឥណទាន និងការដាក់ទ្រព្យបញ្ចាំមានទំហំធំ។ កង្វះព័ត៌មានហិរញ្ញវត្ថុដែលបណ្តាលមកពីភាពទន់ខ្សោយនៃស្តង់ដាគណនេយ្យ និងកង្វះព័ត៌មានហិរញ្ញវត្ថុធ្វើឲ្យធនាគារ និង MFIs ពិបាកវាយតម្លៃពីភាពស្មោះត្រង់របស់សហគ្រាស។ អត្រាការប្រាក់ឥណទានខ្ពស់ និងការខ្វះខាតគម្រោងអភិវឌ្ឍន៍សហគ្រាសក៏ជាមូលហេតុនៃការទទួលបានឥណទានផងដែរ។

- **ផលិតភាពទាប និងតម្លៃផលិតកម្មខ្ពស់**

ការប្រកួតប្រជែងក្នុងទីផ្សារ កម្ពុជាមានភាពលំបាកដោយអត្រាផលិតភាពរបស់កម្ពុជាទាបជាងប្រទេសជិតខាង (ថៃ និងវៀតណាម) រីឯថ្លៃដើមនៃផលិតកម្មនៅកម្ពុជានៅមានកម្រិតខ្ពស់ ដែលបណ្តាលមកពី តម្លៃអគ្គិសនី ថ្លៃដឹកជញ្ជូនខ្ពស់។

### ៤.២.៤. កម្ចីឥណទានមានអត្រាការប្រាក់ខ្ពស់

ការចូលរួមរបស់វិស័យហិរញ្ញវត្ថុ បានជំរុញឲ្យមានកំណើនក្នុងវិស័យកសិកម្ម MSMEs និងវិស័យពាក់ព័ន្ធមួយចំនួនទៀត។ ការពង្រីកបណ្តាញប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ និងMFIs បានផ្តល់ភាពងាយស្រួលក្នុងការទទួលបាន និងប្រើប្រាស់ សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយទៅដល់ប្រជាជននៅតាមរាជធានី-ខេត្ត។ ទោះយ៉ាងណាក៏ដោយវិស័យកសិកម្ម MSMEs និងវិស័យពាក់ព័ន្ធទាំងនោះនៅតែមានភាពរាំងស្ទះក្នុងការទទួលបានឥណទាន។

ករណីអត្រាការប្រាក់ ជាបញ្ហាចម្បងមួយដែលវិស័យកសិកម្ម MSMEs និងវិស័យពាក់ព័ន្ធទាំងនោះត្រូវប្រឈម។ កន្លងមក អត្រាការប្រាក់ឲ្យខ្ចីក្នុងវិស័យហិរញ្ញវត្ថុ ជាបញ្ហាត្រូវលើកយកមកពិភាក្សាដោយសារ អត្រាការប្រាក់នេះមានកម្រិតខ្ពស់ជាងអត្រាការប្រាក់ឲ្យខ្ចីរបស់ធនាគារពាណិជ្ជ ក៏ប៉ុន្តែនៅទាបជាងអត្រាការប្រាក់ក្រៅផ្លូវការ។ កត្តាដែលធ្វើឲ្យអត្រាការប្រាក់របស់ MFIs មានកម្រិតខ្ពស់៖

១-ប្រភពមូលនិធិដែលជាកម្ចីបរទេស៖ ប្រភពមូលនិធិមួយផ្នែករបស់ MFIs ជាកម្ចីបរទេស ហើយកម្ចីនេះមានអត្រាការប្រាក់ខ្ពស់ស្រាប់ដោយសារកត្តាពីរគឺ កត្តាហានិភ័យដែលប្រទេសកម្ពុជាប្រឈម (Country risk) និងកាតព្វកិច្ចក្នុងការបង់ពន្ធកាត់ទុក (Withholding tax) នៃការចំណាយលើការប្រាក់នៃមូលនិធិដែលជាកម្ចីពីបរទេស។ ចំណុចអសកម្ម ដែលធ្វើឲ្យការវាយតម្លៃ

នៃហានិភ័យប្រទេសកម្ពុជាមិនបានល្អប្រសើរ នៅត្រង់កង្វះប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់រដ្ឋាភិបាលកម្ពុជា ភាពមិនពេញលេញនៃនីតិរដ្ឋ និងលទ្ធភាពក្នុងការកាត់បន្ថយអំពើពុករលួយ។

២-ប្រភពមូលនិធិពីប្រាក់បញ្ញើក្នុងស្រុកៈ ប្រាក់បញ្ញើ ឬប្រាក់សន្សំរបស់ប្រជាពលរដ្ឋជាមូលនិធិរបស់ MFIs។ ដើម្បីជាទំនុកចិត្តចំពោះវិស័យហិរញ្ញវត្ថុ ជាហេតុធ្វើឲ្យ MFIs ត្រូវផ្តល់អត្រាការប្រាក់ខ្ពស់ ដើម្បីទាក់ទាញការសន្សំប្រាក់ពីសាធារណៈជនទូទៅ។

៣-ថ្លៃដើមប្រតិបត្តិការៈ ការផ្តល់កម្ចីខ្នាតតូចទៅដល់មូលដ្ឋានដាច់ស្រយាលទាមទារឲ្យមានការចំណាយប្រតិបត្តិការខ្ពស់។

ក្រៅពីកត្តាខាងលើ ក៏មានកត្តាដែលអត្រាការប្រាក់ឲ្យខ្ចីខ្ពស់មួយចំនួនទៀតរួមមាន កត្តាអតិផរណាលើទីផ្សារ ហានិភ័យនៃការមិនសងប្រាក់ និងប្រាក់ចំណេញសមស្របក្នុងកម្រិតមួយដែលអាចទ្រទ្រង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានដំណើរការដោយនិរន្តរភាព។ កម្ពុជាក៏នៅមានច្រើនផងដែរ ចំនួនអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រង NBC បាន នឹងកំពុងផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ខ្ពស់។

### ៤.២.៥. ការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនាប

#### ៤.២.៥.១. បញ្ហាប្រឈមក្នុងវិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រមិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឲ្យពួកគេអាចអភិវឌ្ឍន៍ខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ ទោះជាយ៉ាងនេះក៏ដោយ នៅប្រទេសកម្ពុជាមានកុមារជាច្រើននាក់ពុំបានរៀនសូត្រគ្រប់គ្រាន់ ជាពិសេសកុមារនៅក្នុងតំបន់ក្រីក្រនៅជនបទ ដែលបណ្តាលមកពីបញ្ហាប្រឈមដូចជាៈ

- កុមារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ជាពិសេសកុមារមេត្រីក្រីក្រ និងកុមារជួបការលំបាក មានលទ្ធភាពចូលរៀនតិចតួចប៉ុណ្ណោះ។
- គុណភាពអប់រំកុមារនៅមានកម្រិត ដោយសារកង្វះគ្រូបង្រៀន កង្វះសម្ភារៈសិក្សា។
- អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ព្រោះមានកត្តាជាច្រើនដូចជា សាលារៀននៅឆ្ងាយពីផ្ទះ ជីវភាពគ្រួសារក្រីក្រ។ល។

#### ៤.២.៥.២. បញ្ហាប្រឈមនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងការទទួលបានសេវាគុណភាព និងសមត្ថភាពស្ថាប័នដូចជាៈ

- គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារនៅឡើយ។
- ការមិនសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- ថវិកាមានកម្រិតសម្រាប់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- ជំនាញមូលដ្ឋាន និងជំនាញទន់នៅមានកម្រិត។
- កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សា និងថវិកាសម្រាប់សិក្ខាកាម សិស្ស-និស្សិត។
- កម្រិតនៃអភិបាលកិច្ច និងការសម្របសម្រួលនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

#### ៤.២.៦. បញ្ហាប្រឈមនៃការវិនិយោគ

ការវិនិយោគ បានដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ជាពិសេសបានបង្កើតការងារទាំងផ្ទាល់ និងប្រយោលដល់ប្រជាជននៅតំបន់ជនបទជាច្រើនទាំងមានជំនាញ និងគ្មានជំនាញ។ តាមការបកស្រាយនៅជំពូកទី៣ កម្ពុជាមានភាពទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅស្រុក ២ចម្បង១គឺ បរិយាកាសទូទៅ និងការលើកទឹកចិត្តវិនិយោគ។ ភាពទាក់ទាញទាំងពីរនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការទាក់ទាញវិនិយោគិន ប៉ុន្តែបញ្ហាប្រឈមនៅតែមានចំពោះបរិយាកាសវិនិយោគនៅកម្ពុជា។ ប្រព័ន្ធតុលាការ និងអំពើពុករលួយ ជាឧបសគ្គចម្បងរាំងស្ទះដល់ការវិនិយោគ។ យោងតាមអង្គការតម្លាភាពអន្តរជាតិនៅឆ្នាំ២០១៩ កម្ពុជាឈរលេខរៀងទី១៦២ ក្នុងចំណោមប្រទេស១៨០ នេះមានន័យថាកម្ពុជានៅតែមានកម្រិតអំពើពុករលួយខ្ពស់។[72] ក្រៅពីនេះ កត្តាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អគ្គិសនី ក៏ជាកត្តាទាក់ទាញវិនិយោគមួយដែរ។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងអគ្គិសនីធ្វើឲ្យវិនិយោគិនរារែកក្នុងការវិនិយោគ ព្រោះរាល់ការវិនិយោគត្រូវការដឹកជញ្ជូនវត្ថុធាតុដើមចំណាយពេលវេលា និងថវិកាតិច។

### ៤.៣. ដំណោះស្រាយ

#### ៤.៣.១. ដំណោះស្រាយការបង្កើតការងារក្នុងវិស័យកសិកម្ម

##### ៤.៣.១.១. ដំណោះស្រាយកង្វះដី

គ្រួសារនៅតំបន់ជនបទដែលខ្វះខាតដី ឬគ្មានដីក្នុងការធ្វើកសិកម្ម គឺជាការបង្អាក់ដំណើរក្នុងការបង្កើតឱកាសការងាររបស់ប្រជាជន។ ដូច្នេះសម្បទានដី គឺជាគន្លឹះដ៏ប្រសើរបំផុតក្នុងការដោះស្រាយពីបញ្ហានេះ ពីព្រោះដំណោះស្រាយបែបនេះអាចធ្វើឲ្យប្រជាជនក្រីក្រដែលគ្មានដី ឬ

[72] ដកស្រង់គេហទំព័រ http://www.ticambodia.org/kh/cpi2019/ ចូលទស្សនាថ្ងៃទី ២៨ មិថុនា ២០២០។

ខ្វះខាតដីសម្រាប់សាងសង់លំនៅឋាន និងសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារអាចមានឱកាសការងារ និងទទួលបានប្រាក់ចំណូល។ មុខសញ្ញាសមស្របក្នុងការទទួលបានដីសម្បទាន៖

- គ្រួសារក្រីក្រដែលគ្មានដីសម្រាប់សាងសង់លំនៅឋាន
- គ្រួសារក្រីក្រដែលគ្មាន ឬខ្វះខាតដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅ ដែលបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានជាថ្មី។

មួយវិញទៀត ចំពោះប្រជាជនដែលមានដីធ្វើកសិកម្មតិចត្រូវជំរុញឲ្យមានការដាំដុះជាលក្ខណៈចម្រុះជាដើម និងត្រូវមានការរួមចំណែក និងយកចិត្តទុកដាក់ពីរដ្ឋាភិបាលគ្រប់រូបភាពជាច្រើនក្នុងការផ្តល់ដីសម្បទានដល់ប្រជាជននៅតំបន់ជនបទ និងត្រូវធ្វើការផ្តល់ឲ្យស្មើភាពគ្នាតាមតែអាចធ្វើទៅបាន។

### ៤.៣.១.២. ដំណោះស្រាយទីផ្សារ

ដើម្បីឲ្យទីផ្សារផលិតផលកសិកម្មមានការរីកចម្រើន ចំណុចសំខាន់ត្រូវស្វែងរក និងពង្រីកទាំងទីផ្សារក្នុងស្រុក និងក្រៅស្រុកឲ្យខានតែបាន។ ជាក់ស្តែងទីផ្សារក្នុងស្រុកសំខាន់ៗ គឺភាគច្រើនជាតំបន់ទីប្រជុំជនធំៗដូចជា ទីក្រុងភ្នំពេញ ក្រុងតាខ្មៅ ក្រុងសៀមរាប ខេត្តព្រះសីហនុ ដែលក្នុងនោះទីក្រុងភ្នំពេញ ជាទីផ្សារក្នុងស្រុកធំជាងគេបំផុតក្នុងប្រទេស។ ចំណែកឯទីផ្សារបរទេសសម្រាប់ផលិតផលកសិកម្ម ដែលកម្ពុជាបាននាំចេញទៅកាន់តែមានការរីកចម្រើនគួរសមដែរព្រោះបានសហការជាមួយប្រទេសក្រៅជាច្រើន។ មួយវិញទៀតការចំណាយទៅលើវត្ថុធាតុដើមក្នុងផលិតកម្មកសិកម្ម គឺមានការចំណាយខ្ពស់នៅឡើយ។ ដូច្នេះតម្រូវមានតម្លៃមួយខ្ពស់តាមតែអាចធ្វើបានជូនទៅដល់ប្រជាកសិករ ដើម្បីលើកទឹកចិត្តបន្ថែមក្នុងការប្រកបរបរកសិកម្ម ដែលជាផ្នែកមួយសម្រាប់ការងារប្រកបដោយចីរភាព និងត្រូវផ្តល់ព័ត៌មានអំពីទីផ្សារកសិកម្មទៅដល់កសិករឲ្យបានច្បាស់លាស់ និងទាន់ពេលវេលាដើម្បីឲ្យពួកគាត់យល់ដឹងកាន់តែច្បាស់ពីទីផ្សារលក់ដូរទិន្នផល។ កសិករអាចប្រើប្រាស់មធ្យោបាយ ៥ជម្រើសក្នុងការរក្សាលំនឹងថ្លៃលក់៖

- **ជម្រើសទី១៖ បង្កើតក្រុមជាឃ្លាំងស្តុកផលិតផលកសិកម្ម**

កសិករម្នាក់ៗ មិនអាចធ្វើអ្វីកើតទេទៅលើតម្លៃលក់ផលិតផលរបស់ខ្លួន ប៉ុន្តែបើមានការរួមកម្លាំងគ្នា គេអាចលក់ផលិតផលទាំងនោះបាននូវតម្លៃខ្ពស់។ ក្នុងនេះមានន័យថា ត្រូវបង្កើតឃ្លាំងស្តុកស្រូវរួមមួយ ដើម្បីកសិករអាចខ្ចីលុយបានដោយផ្អែកលើចំនួនស្រូវរបស់ខ្លួនជាជាងការលក់ស្រូវទាំងបង្ខំចិត្ត ហើយទុកស្រូវគាត់លក់នៅពេលឡើងថ្លៃខ្ពស់បំផុត។

- **ជម្រើសទី២៖ បង្កើតតំណាងក្រុមផលិតផលកសិកម្ម**

កសិករច្រើននាក់រួមគ្នាចុះកិច្ចសន្យាជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់គ្នាដែរ ក្នុងតម្លៃមួយដែលបានចរចា និងព្រមព្រៀងគ្នា ហើយត្រូវគោរពតាមកិច្ចសន្យាដែលបានកំណត់។

- **ជម្រើសទី៣៖ កិច្ចព្រមព្រៀងផ្លូវការជាមួយក្រុមហ៊ុន**

កិច្ចព្រមព្រៀងនេះកាន់តែប្រិតប្រៀងជាងមុន ពោលគឺជាកិច្ចព្រមព្រៀងផ្លូវការមួយរវាងកសិករជាច្រើន និងក្រុមហ៊ុនកែច្នៃផលិតផលកសិកម្មធ្វើម្ហូបអាហារ។ ទ្រង់ទ្រាយកសិករក្នុងកិច្ចសន្យាមានដូចតទៅ៖

១-ក្រុមហ៊ុនកែច្នៃកសិផលធំមួយ ចុះកិច្ចសន្យាទិញកសិផលពីកសិករតូចតាចជាច្រើនក្នុងតម្លៃ និងចំនួនដែលបានកំណត់ជាមុន។

២-ត្រូវមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់លើគុណភាព និងសម្ភារៈបរិក្ខារដែលប្រើការផលិតផលកសិផល។

៣-កសិផលត្រូវតែមានក្នុងបរិមាណក្នុងកម្រិតអតិបរមាមួយជាដាច់ខាត បើពុំនោះសោតក្រុមហ៊ុននឹងមិនឃើញផលប្រយោជន៍អ្វីក្នុងការចុះកិច្ចសន្យាជាមួយកសិករទេ។

៤-កសិករអាចចុះកិច្ចសន្យាព្រមព្រៀងជាមួយក្រុមហ៊ុនផ្ទាល់ ឬកសិករបង្កើតសហករណ៍ធំៗជាមុន ហើយឲ្យសហករណ៍ទាំងនោះចុះកិច្ចសន្យាជាមួយក្រុមហ៊ុន(ជំនួសកសិករទាំងអស់)។

- **ជម្រើសទី៤៖ លក់ក្នុងតម្លៃណាមួយជាកំហិតទៅឈ្មួញដោយធានាពីរដ្ឋ**

ក្នុងនេះគឺតម្រូវឲ្យមានការអន្តរាគមន៍ពីរដ្ឋាភិបាលក្នុងការរក្សាថ្លៃលំនឹងទីផ្សារ។ ដូច្នេះមានបណ្តាប្រទេសជាច្រើន ជាពិសេសអាស៊ីអាគ្នេយ៍ អាស៊ីបូព៌ា និងអឺរ៉ុបភាគច្រើនមានការគាំទ្រពីរដ្ឋយ៉ាងហោចណាស់ក៏គេប្រើប្រព័ន្ធថ្លៃគាំទ្រអប្បបរមា (MSP) ប្រព័ន្ធនេះមិនចាំបាច់ឲ្យរដ្ឋាភិបាលទិញទាំងអស់នោះទេ ប្រព័ន្ធនេះ គ្រាន់តែកំណត់ថ្លៃកម្រិតមួយដើម្បីការពារកសិករទប់ទល់នឹងការធ្លាក់ចុះថ្លៃប្រចាំរដូវតែប៉ុណ្ណោះ។

#### ៤.៣.១.៣. ដំណោះស្រាយការប្រែប្រួលអាកាសធាតុ

ការកាត់បន្ថយពីការខូចខាតមកលើផលិតផលកសិកម្មរបស់ប្រជាកសិករ តាមរយៈដំណោះស្រាយការប្រែប្រួលអាកាសធាតុគឺវាល្អប្រសើរបំផុតទៅដល់កសិករ។ កសិកម្មកម្ពុជាត្រូវទប់ទល់ជាមួយគ្រោះធម្មជាតិក្នុងកម្រិតមួយដែលអាចធ្វើបានតាមវិធានការមួយចំនួនដូចជា៖

១-ការបន្សាំ ឬភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តោតលើការផលិតពូជដំណាំ និងដាំដំណាំដែលធន់កម្តៅ ឬទឹកជំនន់។

២-ការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយបង្កើតសកម្មភាពនានាពាក់ព័ន្ធដល់ការបង្កើតប្រព័ន្ធដាំដុះ ការចិញ្ចឹមសត្វដែលមានលក្ខណៈទប់ទល់ជាមួយអាកាសធាតុ (ប្រព័ន្ធកសិដ្ឋានទំនើប សន្សំសំចៃទឹក គ្រប់គ្រងបានលើកម្តៅ/ទឹកភ្លៀង)។

៣-ផ្តល់ព័ត៌មានតាមតែអាចធ្វើបាន អំពីការប្រែប្រួលអាកាសធាតុទៅដល់ប្រជាកសិករដើម្បីឲ្យពួកគាត់យល់ដឹងពីការប្រែប្រួលកាន់តែច្បាស់ និងត្រៀមលក្ខណៈទុកជាដើម។

### ៤.៣.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាផ្នែកមួយដ៏សំខាន់ដែលជួយដល់វិស័យកសិកម្ម និងវិស័យផ្សេងទៀត។ ប៉ុន្តែកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតែជាក្តីកង្វល់សម្រាប់កម្ពុជា ពិសេសនៅតំបន់ជនបទ ដែលទាមទារឲ្យមានការអភិវឌ្ឍ និងវិនិយោគបន្ថែម ដើម្បីកាត់បន្ថយការចំណាយប្រតិបត្តិការ ធានាបាននូវការផ្គត់ផ្គង់ធាតុចូលក្នុងគ្រប់វិស័យ។ ខាងក្រោមនេះជាវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើមានដូចជា៖

#### ៤.៣.២.១. ប្រព័ន្ធធារាសាស្ត្រ

- ការពង្រីកប្រព័ន្ធធារាសាស្ត្រ ដើម្បីកាត់បន្ថយការពឹងផ្អែកលើទឹកភ្លៀងក្នុងវិស័យកសិកម្មដោយការសាងសង់ទំនប់ ប្រឡាយមេនិងប្រឡាយបង្ហូរ ការស្តារ និងសាងសង់ឡើងវិញនូវបណ្តាញធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាបន្ទាន់នៃវិស័យកសិកម្ម។
- ពង្រីកការស្តុកទឹកនៅលើដីដូចជា អាងស្តុកទឹក បឹងប្រឡាយដែលសមស្រប។
- ពង្រឹងសមាគមអ្នកប្រើប្រាស់ទឹក ដើម្បីធានាបានប្រសិទ្ធភាពនៃការបែងចែក ការប្រើប្រាស់ទឹក និងការថែទាំប្រព័ន្ធធារាសាស្ត្រ។
- លើកទឹកចិត្តឲ្យ NGOs និងសប្បុរសជន ជាពិសេសវិស័យឯកជនក្នុងការចូលរួមកសាងបណ្តាញធារាសាស្ត្រខ្នាតតូច។
- ក្រសួងធនធានទឹក និងឧតុនិយមបន្តអនុវត្តការគ្រប់គ្រងច្បាប់ថវិកាក្នុងការវិនិយោគនិងជួសជុលប្រព័ន្ធធារាសាស្ត្រឲ្យមានតម្លាភាព។

#### ៤.៣.២.២. ផ្លូវជនបទ

- ចំពោះថវិកាសម្រាប់យកទៅអភិវឌ្ឍន៍នៅជនបទ គួរតែមានកម្រិតខ្ពស់តាមតែអាចធ្វើបានសម្រាប់ការស្ថាបនាសាងសង់ផ្លូវជនបទដែលជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនជនបទទូទាំងប្រទេស។

- បង្កើត និងជំរុញការផ្តល់អាទិភាពខ្ពស់ដល់ការស្ថាបនា ការស្តារ ការកែលម្អផ្លូវជនបទជាជំហានៗពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ ឬផ្លូវបេតុង និងជួសជុលថែទាំជាប់ជាប្រចាំ ដើម្បីធានាការប្រើប្រាស់បានគ្រប់រដូវកាល និងធន់នឹងការប្រែប្រួលអាកាសធាតុ។
- រៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន។
- ការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់សាងសង់ផ្លូវជនបទ និងសំណង់សិល្បការឲ្យបានទាន់ពេលវេលាដែលបានកំណត់។

**៤.៣.២.៣. អគ្គិសនី**

- ត្រូវពង្រីកឲ្យមានអគ្គិសនីគ្រប់តំបន់ជនបទ ដើម្បីឲ្យប្រជាពលរដ្ឋងាយស្រួលសម្រាប់ជីវភាព និងការធ្វើអាជីវកម្ម។
- កាត់បន្ថយតម្លៃអគ្គិសនីឲ្យមកត្រឹមកម្រិតអប្បបរមា តាមតែអាចធ្វើបានក្នុងការជួយគាំទ្រដល់ការរស់នៅ និងការប្រកបអាជីវកម្ម។
- បង្កើតសាលាបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់គ្រប់គ្រងការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ព្រោះបើសមត្ថភាពទាបវានឹងពិបាកដល់ការធ្វើឲ្យប្រសើរឡើងនូវវិស័យអគ្គិសនី។
- ផ្តល់ជាថវិកាខ្ពស់តាមតែអាចធ្វើបានសម្រាប់ប្រមូលទិន្នន័យថាមពលដើម្បីព្យាករណ៍តម្រូវការថាមពល និងស្ថិតិថាមពល។
- ត្រូវសិក្សាឲ្យច្បាស់ពីការប្រែប្រួលអាកាសធាតុ ដើម្បីឆ្លើយតបនឹងតម្រូវការអគ្គិសនីរបស់ប្រជាពលរដ្ឋ។
- ជំរុញឲ្យមានការស្រាវជ្រាវ និងបង្កើនការផ្គត់ផ្គង់អគ្គិសនីក្នុងស្រុកដើម្បីកាត់បន្ថយពីការនាំចូលរបស់បណ្តាប្រទេសជិតខាង ពីព្រោះងាយស្រួលក្នុងការបន្ទាបតម្លៃ។

**៤.៣.៣. ដំណោះស្រាយ MSMEs**

ការបង្កើត MSMEs នៅតំបន់ជនបទជាពិសេសសហគ្រាសធុនតូច និងមធ្យមមានគោលបំណងបង្កើតការងារ បង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានចំណូលទាប និងប្រជាជនងាយរងគ្រោះ និងជំរុញកំណើនសេដ្ឋកិច្ច ស្ថិរភាពសង្គម និងរួមចំណែកដល់កំណើនវិស័យ

ឯកជនប្រកបដោយថាមពល ប៉ុន្តែការបង្កើត MSMEs បានប្រឈមនឹងបញ្ហាជាច្រើន។ វិធានការដែលឆ្លើយតបនឹងបញ្ហាមានដូចជា៖

**ក. កាត់បន្ថយឧបសគ្គនៃការចុះបញ្ជី**

- ក្រសួងពាណិជ្ជកម្មត្រូវកាត់បន្ថយថ្លៃចំណាយសម្រាប់ការចុះបញ្ជី កាត់បន្ថយដើមទុនចុះបញ្ជីអប្បបរមា កាត់បន្ថយឯកសារដែលស្នើសុំចុះបញ្ជី។
- រាជរដ្ឋាភិបាលត្រូវលើកទឹកចិត្តឲ្យសហគ្រិនចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។
- កាត់បន្ថយអំពើពុករលួយ និងធ្វើឲ្យមានតម្លាភាពខណៈពេលចុះបញ្ជី។
- ព័ត៌មាននៃដំណើរការចុះបញ្ជី និងស្នើសុំអាជ្ញាបណ្ណចាំបាច់ត្រូវសម្របសម្រួលឲ្យបានងាយស្រួលដល់ម្ចាស់អាជីវកម្ម។

**ខ. ការបង្កើនការទទួលបានហិរញ្ញវត្ថុ**

- កាត់បន្ថយវត្ថុបញ្ចាំដោយពង្រឹងប្រព័ន្ធច្បាប់ឲ្យមានប្រសិទ្ធភាព ដែលធ្វើឲ្យអ្នកផ្តល់កម្ចីមានទំនុកចិត្តកាន់តែខ្លាំង។
- ពង្រឹងប្រព័ន្ធតុលាការ ដើម្បីដោះស្រាយក្តីពាណិជ្ជកម្ម។
- MSMEs ត្រូវផ្តល់ព័ត៌មានហិរញ្ញវត្ថុឲ្យបានទូលំទូលាយ ដើម្បីឲ្យអ្នកផ្តល់កម្ចីងាយស្រួលវាយតម្លៃក្នុងការផ្តល់ឥណទាន។

**គ. បង្កើនស្តង់ដាគណនេយ្យ**

- ក្រុមប្រឹក្សាជាតិគណនេយ្យ(NAC) ត្រូវសម្របសម្រួលការណែនាំរបាយការណ៍ ដើម្បីបង្កើនការលើកទឹកចិត្តដល់ MSMEs ក្នុងការអនុវត្តតាមបទបញ្ញត្តិ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តកម្មវិធីបណ្តុះបណ្តាលមូលដ្ឋានគណនេយ្យ និងជំនាញគ្រប់គ្រងសម្រាប់អ្នកគ្រប់គ្រងសហគ្រាសទាំងអស់។

**ឃ. សកម្មភាពគាំទ្រ** MSMEs

- បង្កើតពិព័រណ៍ពាណិជ្ជកម្មដើម្បីឲ្យ MSMEs តាំងបង្ហាញផលិតផល និងផ្សព្វផ្សាយព័ត៌មានពីផលិតផលទៅប្រជាជន។
- រដ្ឋត្រូវផ្តល់ព័ត៌មានឲ្យបានទូលំទូលាយអំពីពិព័រណ៍ពាណិជ្ជកម្ម និងបង្ហាញពីអត្ថប្រយោជន៍នៃការទិញទំនិញក្នុងស្រុក។
- បង្កើនទំនាក់ទំនងរវាងរដ្ឋនិងMSMEs និងពី MSMEs ទៅវិស័យដទៃ ដើម្បីបង្កើនការផ្គត់ផ្គង់សម្រាប់ការនាំចេញជាដើម។

- បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ផ្លូវថ្នល់ ផ្លូវជនបទ អគ្គិសនី ដើម្បីកាត់បន្ថយការចំណាយថ្លៃដើម។

**ង. អភិវឌ្ឍន៍ធនធានមនុស្ស និងបច្ចេកវិទ្យា**

- បង្កើនលទ្ធភាពទទួលឥណទាន(បកស្រាយខាងលើ) ព្រោះវាជាផ្នែកមួយចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យា។
- ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ បង្កើនការបណ្តុះបណ្តាលវគ្គខ្លីៗឲ្យសមស្របដល់សហគ្រិនឲ្យបានច្រើនអំពីផលិតកម្មផលិត ប្រតិបត្តិការ ទីផ្សារ និងការគ្រប់គ្រងធនធានមនុស្ស។
- ក្រសួងស្ថាប័នសាធារណៈ គួរផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកទាំងអស់នៅក្នុងវិស័យ MSMEs។

**៤.៣.៤. វិធានការធ្វើឲ្យអត្រាការប្រាក់ធ្លាក់ចុះ**

វិស័យហិរញ្ញវត្ថុ បានបម្រើសេវាហិរញ្ញវត្ថុមួយផ្នែកធំដល់វិស័យជំនួញអាជីវកម្ម មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម(MSMEs) និងផ្គត់ផ្គង់ឥណទានសម្រាប់ប្រជាជននៅតំបន់ជនបទ ជាពិសេសក្នុងផលិតកម្មវិស័យកសិកម្មនៅកម្ពុជា។ ក្នុងគោលបំណងឲ្យវិស័យទាំងនេះមានលទ្ធភាពទទួលបានឥណទានដោយអត្រាការប្រាក់ទាប យើងមានវិធានការខាងក្រោម៖

- ការកំណត់ពិដានអត្រាការប្រាក់ឲ្យឋិតនៅអត្រាមួយទាបដោយរដ្ឋអំណាចហិរញ្ញវត្ថុ។
- កាត់បន្ថយការចំណាយក្នុងការទទួលបាននូវប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីឲ្យធនាគារ និង MFIs អាចប្រើប្រាស់បានកាន់តែទូលំទូលាយជាវត្ថុបញ្ចាំក្នុងការផ្តល់ជាឥណទាន។
- លើកទឹកចិត្តឲ្យអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការមកចុះបញ្ជីនៅ NBC។
- ពង្រឹងប្រព័ន្ធតុលាការ និងនីតិវិធីក្នុងការប្តឹងរកយុត្តិធម៌ ដោយដាក់ឲ្យដំណើរការនូវប្រព័ន្ធតុលាការពាណិជ្ជកម្ម ជាផ្នែកមួយនៃវិធានការធ្វើឲ្យប្រតិបត្តិការពាណិជ្ជកម្មគួរឲ្យទុកចិត្តបាន។

ការដាក់កំហិតពិដានអត្រាការប្រាក់ មិនអាចធ្វើឲ្យអត្រាការប្រាក់ចុះទាបប្រកបដោយប្រសិទ្ធភាពនោះឡើយ។ ការធ្វើបែបនេះនាំឲ្យអ្នកវិនិយោគលើវិស័យហិរញ្ញវត្ថុមានការរារែកអាចនឹងមិនធ្វើការវិនិយោគ ឬដកទុនវិនិយោគរបស់គេទៅវិញដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋ និង MSMEs បាត់បង់ឱកាសទទួលបានសេវាឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ មធ្យោបាយដែលធ្វើឲ្យអត្រាការប្រាក់ចុះទាប គឺការបង្កបរិយាកាសអំណោយផលឲ្យប្រតិបត្តិការហិរញ្ញវត្ថុកាន់តែ

កុះករឡើងឲ្យវិនិយោគិនហ៊ានមកបណ្ដាក់ទុនវិនិយោគដោយមិនមានការព្រួយបារម្ភអំពីការគៀបសង្កត់ណាមួយ និងការពង្រីកដែនប្រតិបត្តិការរបស់គេឲ្យកាន់តែទូលំទូលាយ។ ដូច្នេះ វានឹងនាំឲ្យមានការប្រកួតប្រជែងលើទីផ្សាររវាង MFIs ទាំងនោះដែលជាហេតុនាំឲ្យអត្រាការប្រាក់ចុះទាប។

### ៤.៣.៥. ការបង្កើនការអប់រំ និងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ

ការបង្កើតភាពងាយស្រួលក្នុងការទទួលបាន និងការលើកកម្ពស់គុណភាពការអប់រំនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងការអភិវឌ្ឍបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈអាចជួយឲ្យយុវជនក្មេងៗ ដែលឈានចូលដល់វ័យគ្រប់អាយុធ្វើការជារៀងរាល់ឆ្នាំ និងត្រៀមខ្លួនសម្រាប់ការងារពេញមួយជីវិត។ ការសិក្សាជាច្រើនបានបង្ហាញថាកម្លាំងពលកម្មភាគច្រើននៅមានកម្រិតអប់រំ និងកម្រិតជំនាញទាបនៅឡើយ។ ដើម្បីដោះស្រាយប្រឈមទាំងអស់នេះ វិធានការជាច្រើនត្រូវបានលើកឡើងដូចខាងក្រោមៈ

#### ៤.៣.៥.១. ដំណោះស្រាយការអប់រំ

- **លុបបំបាត់ឧបសគ្គរាំងដល់ការទទួលបានការអប់រំ**

ការលុបឧបសគ្គរាំងដល់ការទទួលបានការអប់រំ ត្រូវផ្ដល់អាហារូបករណ៍ដល់កុមារមកពីគ្រួសារក្រីក្រជួបការលំបាក ដើម្បីឲ្យពួកគេអាចបន្តទៅរៀនបានជាជាងបោះបង់ចោលការសិក្សាទៅរកការងារធ្វើ ការធ្វើឲ្យការទទួលបានសេវាអប់រំប្រកបដោយគុណភាព ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល និងការផ្ដល់នូវសម្ភារៈរូបវន្តក្នុងសាលារៀនទាំងកុមារពិការភាព ទាំងគ្មានពិការភាព ងាយស្រួលប្រើប្រាស់។

- **ការយកចិត្តទុកដាក់ចំពោះគុណភាពបង្រៀន និងរៀន**

ការបង្កើនគុណភាពអប់រំ ដើម្បីឲ្យកុមារអាចចាប់ផ្ដើមដំណើរផ្លូវរៀនសូត្រពេញមួយជីវិតបាន។ ការស្វែងរកការគាំទ្រដើម្បីឲ្យមានការវិនិយោគផ្នែកហិរញ្ញវត្ថុ និងផ្ដល់ការបណ្ដុះបណ្ដាលកាន់តែល្អប្រសើរដល់គ្រូបង្រៀនចាប់ពីកម្រិតអប់រំកុមារតូចរហូតដល់មធ្យមសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡាត្រូវកែសម្រួលកម្មវិធីសិក្សាជាតិ រួមទាំងលម្អិតស្តង់ដានៃការរៀនសូត្រ ការបណ្ដុះបណ្ដាលគ្រូ និងសៀវភៅសិក្សា ដើម្បីបញ្ចូលបំណិនសតវត្សរ៍ទី២១ ក្នុងប្រព័ន្ធអប់រំ។

- **ការសាងភាពជាអ្នកដឹកនាំ និងផ្ដល់ការគាំទ្រ**

កសាងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីអប់រំ។ ការបណ្ដុះបណ្ដាលបច្ចេកទេសដើម្បីបង្កើតសេវាអប់រំដែលមានគុណភាព បរិយាបន្ន សមធម៌ និងឆ្លើយតប

នឹងតម្រូវការ។ ប៉ុន្តែត្រូវមានការជំរុញពីគ្រួសារ សហគមន៍ និងលើកទឹកចិត្តដល់ឪពុកម្តាយឲ្យស្គាល់ពីតម្លៃនៃការអប់រំ។

**៤.៣.៥.២. ដំណោះស្រាយការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យសមស្របតាមតម្រូវការទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។
- បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយសមធម៌សម្រាប់បង្កើតការងារ។
- លើកទឹកចិត្តភាពជាដៃគូ រដ្ឋនិងឯកជន និងកៀរគរធនធានថវិកាពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

### ៤.៣.៦. ការបង្កើតបរិយាកាសអំណោយផលដល់វិនិយោគ

ការបង្កើតបរិយាកាសអំណោយផលដល់វិនិយោគ ជាវិធានការសម្រាប់ដោះស្រាយបញ្ហាប្រឈមដែលរាំងស្ទះដល់ការវិនិយោគ និងធ្វើឲ្យវិនិយោគិនទាំងក្នុង និងក្រៅស្រុកកាន់តែមានទំនុកចិត្តកាន់តែខ្លាំងលើការបណ្តាក់ទុកវិនិយោគរបស់ពួកគេ។ វិធានការទាំងនោះរួមមានៈ

- ពង្រឹងប្រព័ន្ធច្បាប់ ប្រព័ន្ធតុលាការ និងអភិបាលកិច្ចល្អ ដើម្បីឲ្យវិនិយោគិនមានទំនុកចិត្ត។
- កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ឲ្យមានគុណភាពប្រសើរឡើង។
- អភិវឌ្ឍន៍វិស័យអគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានតម្លៃថោកសមរម្យ។
- ពង្រឹងសមត្ថភាពរបស់មន្ត្រីរាជរដ្ឋាភិបាល ដើម្បីផ្តល់សេវាអតិបរមាដល់វិនិយោគិន និងវិស័យឯកជន។
- រាជរដ្ឋាភិបាលត្រូវត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធលើកទឹកចិត្ត ពិសេសច្បាប់វិនិយោគដែលជាផ្នែកមួយសំខាន់នៃការទាក់ទាញវិនិយោគ។

# សេចក្ដីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការបង្កើតការងារនៅជនបទ**" ក្រុមខ្ញុំបាទបានសង្កេតឃើញថា ប្រទេសកម្ពុជាមានកម្លាំងពលកម្មវ័យក្មេងនៅតំបន់ជនបទជាច្រើនចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ ប៉ុន្តែកំណើនការងារធ្វើ និងកំណើនកម្លាំងពលកម្មចំណូលថ្មីមិនទាន់មានតុល្យភាពគ្នានៅឡើយ ខណៈពេលដែលអត្រានិកម្មភាពនៅតំបន់ជនបទហាក់ស្ថិតនៅកម្រិតមួយទាប ដោយសារតែការកំណត់និយមន័យនៃភាពមានការងារធ្វើមានភាពធូររលុង។ កំណើនយឺតនៃវិស័យកសិកម្មបានធ្វើឲ្យបាត់បង់ឱកាសការងារធ្វើនៅតំបន់ជនបទ និងអាចទាញឲ្យកម្ពុជាធ្លាក់ចុះទៅកាន់ភាពក្រីក្រវិញ។ ទោះបីជាយ៉ាងណា វិស័យឧស្សាហកម្ម និងសេវាកម្មនៅទីក្រុង និងទីប្រជុំជនបានស្រូបយកមួយផ្នែកធំនៃកម្លាំងពលកម្ម។ ការស្រូបយកនេះក៏មានផលវិជ្ជមាន ហើយក៏មានផលអវិជ្ជមានដែរ។ ផលវិជ្ជមាន គឺផ្តល់ការងារឲ្យប្រជាជនដែលបាត់បង់ក្នុងវិស័យកសិកម្ម និងផលអវិជ្ជមានគឺធ្វើឲ្យមានចំណាកស្រុកមកកាន់ទីក្រុងកាន់តែច្រើនឡើងៗក្នុងគោលបំណងស្វែងរកការងារធ្វើ។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ភាពក្រីក្រនៅកម្ពុជាបានកាត់បន្ថយយ៉ាងរហ័សប៉ុន្តែអត្រានៃភាពក្រីក្រមានកម្រិតខ្ពស់នៅឡើយ។ ប្រជាជនវ័យក្មេង និងវ័យកណ្តាលដែលជាកម្លាំងពលកម្មចំណូលថ្មីភាគច្រើនមានកម្រិតនៃការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទាប ជាហេតុមួយបង្អាក់ការធ្វើឲ្យប្រសើរឡើងសុខុមាលភាពរបស់ពួកគេ។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ គោលនយោបាយជាតិជាច្រើនត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញសេដ្ឋកិច្ច ក៏ដូចជាអភិវឌ្ឍន៍តំបន់ជនបទ បង្កើតការងារ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព និងបរិយាបន្ន តែការអនុវត្តគោលនយោបាយទាំងនោះហាក់មានល្បឿនយឺតមិនទាន់សភាពការណ៍ទូទៅជាក់ស្តែង និងត្រូវការឲ្យមានការអនុវត្តឲ្យប្រសើរជាងនេះ។ ការអនុវត្តគោលនយោបាយមានប្រសិទ្ធភាព នឹងជួយឲ្យរីកចម្រើនលើគ្រប់វិស័យ ហើយបង្កើតឲ្យមានឱកាសការងារកាន់តែច្រើនថែមទៀត។

ការបង្កើតការងារនៅជនបទតាមរយៈវិស័យកសិកម្ម វិស័យក្រៅកសិកម្ម និងតាមរយៈវិស័យទេសចរណ៍ជនបទ ជាកត្តាចាំបាច់មួយរបស់កម្ពុជាសម្រាប់រុញច្រានឲ្យមានកំណើនសេដ្ឋកិច្ចជនបទឡើងវិញ។ កត្តាចាំបាច់នៃការបង្កើតការងារនៅតាមទីជនបទ ជាឧបករណ៍មួយសម្រាប់ការចាកចេញពីភាពក្រីក្ររបស់ប្រជាជនវ័យក្មេង ជាពិសេសស្ត្រីដែលនៅតែបន្តរាំងដោយវប្បធម៌ បទដ្ឋានសង្គម និងមានចំណេះដឹងទាប និងមនុស្សជាច្រើនទៀតដែលកំពុងរស់នៅ

តំបន់ជនបទដែលមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានគ្រប់គ្រាន់នៅឡើយ។ ជាមួយគ្នានេះ ក៏មានបញ្ហាចម្បងៗដែលរាំងស្ទះដល់ការបង្កើតការងារនៅជនបទជាច្រើន ធ្វើឲ្យបង្អាក់សកម្មភាពមួយចំនួនដែលចូលរួមក្នុងការលើកកម្ពស់ការបង្កើតការងារនៅជនបទដូចជា ដីកសិកម្មមានទំហំតូច កង្វះទីផ្សារ កង្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ការផ្តល់ឥណទានក្នុងវិស័យកសិកម្ម វិស័យពាក់ព័ន្ធនឹងកសិកម្ម សហគ្រាសមីក្រូ សហគ្រាសធុនតូច និងមធ្យមមានកម្រិតនិងមានអត្រាការប្រាក់ខ្ពស់ កម្រិតអប់រំនៃកម្លាំងពលកម្មទាប និងភាពមិនគ្រប់គ្រាន់នៃសេវាគាំទ្រផ្សេងទៀត ជាពិសេសគឺការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយសមត្ថភាពរបស់មន្ត្រីថ្នាក់ក្រោមនៅមានកម្រិត។ ចំណែកការដោះស្រាយ ការចូលរួមពីសំណាក់រាជរដ្ឋាភិបាលតែមួយមិនគ្រប់គ្រាន់ឡើយ តែត្រូវមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជុំវិញទាំងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល សហគ្រិន ព្រមទាំងប្រជាជននៅជនបទមូលដ្ឋានផ្ទាល់ចូលរួមដោះស្រាយជាមួយគ្នា។

## ២. អនុសាសន៍

ដើម្បីចូលរួមជំរុញការបង្កើតការងារនៅជនបទ ដែលជាកត្តាមួយសម្រាប់បង្កើនប្រាក់ចំណូល ចូលរួមលើកកម្ពស់ជីវភាពប្រជាជន កាត់បន្ថយភាពក្រីក្រ និងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្រុមខ្ញុំបាទចូលរួមផ្តល់ជាអនុសាសន៍ដូចតទៅ៖

